# ការវាយតម្លៃពាក់កណ្តាលត្រីមាសលើយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស

ខែសីហា ឆ្នាំ២០០៧

## ប្រទេសកម្ពុជា

ឆ្នាំ២០០៥-២០០៩

ធនាគារអភិវឌ្ឍន៍អាស៊ី

អត្រាប្តូរប្រាក់

(គិតត្រឹមថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៧)

ឯកតារូបិយប័ណ្ណ - រៀល (KR)

១.០០ ដុល្លា = ៤០១០.០០រៀល

## អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADF | មូលនិធិអភិវឌ្ឍន៍អាស៊ី |
| ADTA | ជំនួយក្រុមប្រឹក្សាបច្ចេកទេស |
| AFD | ទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍ |
| ASDP | កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម |
| AusAID | ទីភ្នាក់ងារអូស្ត្រាលីដើម្បីការអភិវឌ្ឍអន្តរជាតិ |
| CAER | របាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយនៅកម្ពុជា |
| CARM | បេសកកម្មប្រចាំកម្ពុជា |
| CBDMS | ប្រព័ន្ធគ្រប់គ្រងបំណុលតាមប្រព័ន្ធកុំព្យូទ័រ |
| CCDP | គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ/សង្កាត់ |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDCF | វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា |
| CDRI | វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងចំពោះស្ត្រី |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| CPA | ការវាយតម្លៃការអនុវត្តតាមប្រទេស |
| CPP | គណបក្សប្រជាជនកម្ពុជា |
| CPPR | ការពិនិត្យឡើងវិញពីការអនុវត្តនៅក្នុងប្រទេស |
| CSP | យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស |
| CSP MTR | ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ CSP |
| DEMD | នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច |
| DFIN | នាយកដ្ឋានចក្រភពអង់គ្លេសដើម្បីការអភិវឌ្ឍអន្តរជាតិ |
| DSA | ការវិភាគនិរន្តរភាពបំណុល |
| EDC | អគ្គិសនីកម្ពុជា |
| ESDP | គម្រោងអភិវឌ្ឍន៍វិស័យអប់រំ |

| | |
|---|---|
| EU | សហភាពអឺរ៉ុប |
| FDIs | ការវិនិយោគផ្ទាល់ពីបរទេស |
| FUNCIPEC | ពាក្យកាត់ជាភាសាបារាំង ៖រណសិរ្សរួបរួមជាតិដើម្បីកម្ពុជាឯករាជ្យ អព្យាក្រិត្យ សន្តិភាព និងសហប្រតិបត្តិការ |
| GDCC | គណៈកម្មការសម្របសម្រួលការអភិវឌ្ឍរបស់រដ្ឋាភិបាល |
| GDI | សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GMS | មហាអនុតំបន់ទន្លេមេគង្គ |
| HDI | សន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្ស |
| IDA | សមាគមអភិវឌ្ឍន៍អន្តរជាតិ ( ធនាគារពិភពលោក) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| IRC | គណៈកម្មការដោះស្រាយជម្លោះអន្តរក្រសួង |
| IRI | វិទ្យាស្ថានសាធាណរដ្ឋអន្តរជាតិ |
| JCPPR | ការពិនិត្យឡើងវិញលើការអនុវត្តរវាងធនាគារអភិវឌ្ឍន៍អាស៊ី |
| LMAP | គម្រោងរដ្ឋបាល និងរៀបចំដែនដី |
| MAFF | ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MOC | ក្រសួងពាណិជ្ជកម្ម |
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MOLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MOU | អនុសារណៈនៃការយោគយល់គ្នា |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NAA | អាជ្ញាធរសវនកម្មជាតិ |
| NBC | ធនាគារជាតិនៃកម្ពុជា |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| OAG | ការិយាល័យអគ្គសវនករ |
| OCR | ធនធានមូលធនធម្មតា |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ |

| | |
|---|---|
| PFM | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PPTA | គម្រោងជំនួយបច្ចេកទេស |
| PRC | សាធារណរដ្ឋប្រជាមានិតចិន |
| PWSS | ការផ្គត់ផ្គង់ និងអនាម័យទឹកនៅតាមជនបទ |
| SMART | ជាក់លាក់ អាចវាស់វែងបាន អានសម្រេចបាន ប្រាកដនិយម និងទាន់ពេលវេលា |
| SME | សហគ្រាសខ្នាតតូច និងមធ្យម |
| SMEDF | គម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម |
| TSI | គំនិតផ្តួចផ្តើមតាមតំបន់ទន្លេសាប |
| TWG | ក្រុមការងារ |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| US | សហរដ្ឋអាមេរិក |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

**កំណត់ចំណាំ:**

នៅក្នុងរបាយការណ៍នេះ " $" តំណាងឱ្យដុល្លាសហរដ្ឋអាមេរិក

| | |
|---|---|
| អនុប្រធាន | L. Greenwood ក្រុមទីពីរ |
| អគ្គនាយក | A. Thapan អគ្គនាយក នាយកដ្ឋានអាស៊ីអាគ្នេយ៍ (SERD) |
| ប្រធានក្រុម | A. Goswami នាយកបេសកម្មប្រចាំប្រទេសកម្ពុជា (SERD) |
| សមាជិកក្រុម | ក្រុមការងារប្រចាំប្រទេសកម្ពុជា |

# មាតិកា


| | ទំព័រ |
|---|---|
| **I. បញ្ហា និងនិន្នាការអភិវឌ្ឍបច្ចុប្បន្ន** | ១ |
| ក. ការអភិវឌ្ឍនយោបាយ និងសង្គមបច្ចុប្បន្ន | ១ |
| ខ. ការវាយតម្លៃសេដ្ឋកិច្ច និងទស្សនៈវិស័យ | ១ |
| គ. ការរីកចម្រើនក្នុងការកាត់បន្ថយភាពក្រីក្រ | ៣ |
| ឃ. ការវាយតម្លៃហានិភ័យ | ៤ |
| ង. ការពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្ររបស់ប្រទេស | ៥ |
| **II. ការអនុវត្តយុទ្ធសាស្ត្រ** | ៦ |
| ក. វឌ្ឍនភាពនៅក្នុងយុទ្ធសាស្ត្រជាតិ | ៦ |
| ខ. ការបង្ហាញត្រួស១ពីការសម្របសម្រួលមូលនិធិបរទេស និងការរៀបចំដៃគូ | ៨ |
| **III. ការគ្រប់គ្រងផលប័ត្រ និងបញ្ហាតាមដានត្រួតពិនិត្យការអនុវត្ត** | ៩ |
| ក. ការអនុវត្តផលប័ត្រ | ៩ |
| ខ. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការងារអនុវត្ត | ១០ |
| **IV. យុទ្ធសាស្ត្រប្រចាំប្រទេស និងគម្រោងការលទ្ធផលរបស់កម្មវិធី** | ១០ |
| **ឧបសម្ព័ន្ធ** | |
| ១. ការវិភាគប្រចាំប្រទេស | ១១ |
| ២. ការធ្វើចំណាត់ថ្នាក់លើការវាយតម្លៃការអនុវត្តប្រចាំប្រទេស | ២០ |
| ៣. វិស័យ និងប្រធានបទអាទិភាពដែលត្រូវធ្វើបច្ចុប្បន្នភាព | ២១ |
| ៤. ម៉ាទ្រីកសម្របសម្រួលការអភិវឌ្ឍ | ២៧ |
| ៥. សូចនាកររបស់គម្រោង | ៣៦ |
| ៦. ផែនការអាជីវកម្មប្រតិបត្តិការប្រចាំប្រទេស ២០០៧-២០០៩ | ៥៣ |
| ៧. សកម្មភាព និងស្ថានភាពអនុវត្តផលប័ត្រ | ៥៦ |
| ៨. យុទ្ធសាស្ត្រប្រចាំប្រទេស និងក្របខណ្ឌលទ្ធផលកម្មវិធី | ៦២ |
| **ឧបសម្ព័ន្ធបន្ថែម** ( អាចស្នើសុំបាន) | |
| ក. ការវាយតម្លៃលើហានិភ័យ : ក្រសួងអភិវឌ្ឍន៍ជនបទ | |
| ខ. ការវាយតម្លៃលើហានិភ័យ : ក្រសួងធនធានទឹក និងឧតុនិយម | |
| គ. ផែនទីផ្លូវតាមវិស័យ | |
| ឃ. ការវាយតម្លៃលើយេនឌ័រ | |
| ង. ការវាយតម្លៃលើការការពារសង្គម | |
| ច. ប៉ារ៉ាម៉ែត្រហិរញ្ញប្បទាន | |

# I. បញ្ហា និងនិន្នាការអភិវឌ្ឍបច្ចុប្បន្ន

## ក. ការអភិវឌ្ឍនយោបាយ និងសង្គមបច្ចុប្បន្ន

**១. ការអភិវឌ្ឍនយោបាយ :** នៅពេលដែលយុទ្ធសាស្រ្ត និងកម្មវិធីអភិវឌ្ឍន៍កម្ពុជាសម្រាប់ឆ្នាំ២០០៥-២០០៩ (CSP)[១] ត្រូវបានបង្កើតឡើង ហេតុការណ៍នយោបាយមានលក្ខណៈមិនច្បាស់លាស់ ដោយសារការចរចាអូសបន្លាយ រវាងគណបក្សប្រជាជន (CPP) និងគណបក្សរាជានិយមហ៊្វុនស៊ីនប៉ិច[២] ក្នុងការបង្កើតរដ្ឋាភិបាលចម្រុះនៅឆ្នាំ២០០៤។ ចាប់ពីពេលនោះមក សាមគ្គីភាព និង ស្ថេរភាពផ្នែកនយោបាយមានភាពរឹងមាំ CPP ជាដៃគូមានប្រៀបជាងក្នុងរដ្ឋាភិបាល និងទទួលអាណត្តិគ្រប់គ្រងអំណាចពេញលេញ នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០៧។ បន្ទាប់ពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញស្របតាមសមាជិកភាគច្រើនរបស់រដ្ឋសភា ដើម្បីបង្កើតរដ្ឋាភិបាល ហើយភាពយឺតយ៉ាវក្នុងការបង្កើតរដ្ឋាភិបាលក្រោយការបោះឆ្នោតឆ្នាំ២០០៨ មិនទំនងជាកើតមានទេ។

**២. ការអភិវឌ្ឍសង្គម :** នៅពេលដែលគណបក្សនយោបាយទាំងអស់បានខិតខំឃោសនាសម្រាប់ការបោះឆ្នោត ដែលនឹងប្រព្រឹត្តទៅនៅខែកក្កដា ឆ្នាំ២០០៨ (ដែលជាការបោះឆ្នោតថ្នាក់ជាតិលើកទី៤ ចាប់តាំងពីកិច្ចព្រមព្រៀងសន្តិភាពប៉ារីស ឆ្នាំ១៩៩១ មក) ពួកគេនឹងជួបប្រទះស្ថានភាពថ្មីៗ។ ប្រហែលជាមួយភាគបួននៃអ្នកបោះឆ្នោតទាំងអស់បានកើតក្រោយសម័យប៉ុលពតនៅក្នុងទសវត្សឆ្នាំ១៩៧០។ ទោះបីជាមានការកើនឡើងនៃការធ្វើចំណាកស្រុកពីតំបន់ជនបទមករកការងារធ្វើតាមទីក្រុង និកម្មភាពនៅតាមតំបន់ជនបទនឹងក្លាយជាបញ្ហាដែលកំពុងតែកើតឡើង ពីព្រោះពុំមានការងារគ្រប់គ្រាន់សម្រាប់ផ្តល់ឱ្យប្រជាពលរដ្ឋកម្ពុជាវ័យក្មេង ដែលមានចំនួនរហូតដល់៣០០.០០០នាក់ ដែលជាកម្លាំងពលកម្មនៅក្នុងតំបន់ជនបទ ហើយតែងតែប្រឈមមុខនឹងបញ្ហាសេដ្ឋកិច្ច និងឧស្សាហកម្មជារៀងរាល់ឆ្នាំ ដែលពុំមានការរីកចម្រើនខ្លាំង។ លទ្ធផលនៃការធ្វើអង្កេត[៣] បង្ហាញថា អ្នកបោះឆ្នោតនឹងធ្វើការវាយតម្លៃសមត្ថភាពដឹកនាំរបស់គណបក្សនយោបាយទាំងអស់ ដោយផ្តល់លទ្ធផលជាក់លាក់ដល់គណបក្សនយោបាយ ដូចជាការកែលំអហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមភូមិ។

## ខ. ការវាយតម្លៃសេដ្ឋកិច្ច និងទស្សនៈវិស័យ

**៣. ការវាយតម្លៃសេដ្ឋកិច្ច :** នៅក្នុងអំឡុងឆ្នាំ២០០៥-២០០៦ ការងារសេដ្ឋកិច្ចមានលក្ខណៈគួរឱ្យកត់សម្គាល់។ នៅក្នុងឆ្នាំ២០០៥ និង២០០៦ កំណើន GDP បានកើនឡើងលើសពីការព្យាករណ៍របស់រដ្ឋាភិបាល។ នៅក្នុងឆ្នាំ២០០៥ សេដ្ឋកិច្ចកើនឡើងដល់១៣.៥% (ដែលផ្ទុយពីការព្យាករណ៍របស់រដ្ឋាភិបាល ៧%) និងនៅក្នុងឆ្នាំ២០០៦ កើនឡើងដល់១០.៨% (ដែលផ្ទុយពីការព្យាករណ៍ ៦%)។ កំណើនក្នុងអំឡុងឆ្នាំ២០០៥-២០០៦ មានសន្ទុះយ៉ាងឆាប់រហ័ស និងកាន់តែមានកំណើនជាងនៅឆ្នាំ១៩៩៦-២០០៤ នៅពេលដែលកំណើនប្រចាំឆ្នាំជាមធ្យម គឺ៧.៨%។ កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០០៦ បានកើនឡើងដោយសារការរីកចម្រើនយ៉ាងខ្លាំង នៅក្នុងវិស័យកសិកម្ម កំណើននៅក្នុងសេវាកម្ម ដោយពឹងផ្អែកលើចំនួនទេសចរកើនឡើងយ៉ាងខ្លាំងក្លា និងកំណើនប្រកបដោយនិរន្តរភាពនៅក្នុងផលិតផលឧស្សាហកម្ម ដោយសារកំណើនបន្តបន្ទាប់នៅក្នុងការនាំចេញផលិតផលសម្លៀកបំពាក់។

---

[1] ADB. 2005. Country Strategy and Program (2005-2009): Cambodia. Manila.

[2] ហ៊្វុនស៊ីនប៉ិច ជាពាក្យកាត់ជាភាសាបារាំងសម្រាប់ការឈានទៅមុខរបស់អង្គការសហប្រជាជាតិដើម្បី ឯករាជ្យភាព អនុក្រិត្យាភាព សន្តិភាព និងកិច្ចសហប្រតិបត្តិការ នៅក្នុងប្រទេសកម្ពុជា។

[3] International Republican Institute. 2007. Survey of Cambodian Public Opinion. Cambodia. Available: http://www.iri.org/cambodia/pdfs/2007-06-12-Cambodia.pdf

៤. ចំពោះសេចក្តីត្រូវការ កំណើនសេដ្ឋកិច្ចពឹងផ្អែកលើការប្រើប្រាស់ផលិតផលតិចតួច ដែលនេះជាសញ្ញាបញ្ជាក់ថា មានកំណើនកាន់តែខ្ពស់ និងមាននិរន្តរភាព ការវិនិយោគឯកជនបានកើនឡើង ដោយសារតែមានបរិស្ថានវិនិយោគល្អប្រសើរជាងមុន និង មានការរីកចម្រើនឡើងវិញទាំងស្រុងនៅក្នុងឆ្នាំ២០០៦ បន្ទាប់ពីការធ្លាក់ចុះនៅក្នុងឆ្នាំ២០០៤ ជំនឿទុកចិត្តទៅលើប្រព័ន្ធហិរញ្ញវត្ថុ ដែលទើបតែចាប់កំណើតនៅក្នុងប្រទេសកម្ពុជាបានកើនឡើង ចំនួនសាច់ប្រាក់៣៨% (M2) នៅក្នុងឆ្នាំ២០០៦ ភាគច្រើនជាទឹកប្រាក់ ឥណទាន៥៤% ដែលផ្តល់ទៅឱ្យអោយវិស័យឯកជន និងកំណើន៣២% ជាទ្រព្យបរទេសសុទ្ធរបស់ធនាគារកណ្តាល និងធនាគារ ទទួលប្រាក់បញ្ញើ ។

៥. អតិផរណាជាមធ្យម គឺ៤.៧% នៅក្នុងឆ្នាំ២០០៦ និងធ្លាក់ចុះប្រហែល១% ចាប់ពីឆ្នាំ២០០៥ ម្យ៉ាងដោយសារមានកំណើនជាមធ្យមនៅក្នុងថ្លៃចំណីអាហារ និងប្រេង ដោយអត្រាអតិផរណាចុងឆ្នាំ ២.៨% អតិផរណានឹងធ្លាក់ចុះ ជាលំដាប់ ។

៦. ការគ្រប់គ្រងបំណុលបរទេសមានលក្ខណៈល្អប្រសើរ ។ បំណុលសាធារណៈមកពីខាងក្រៅ នៅចុងឆ្នាំ២០០៦ ដែលមានចំនួនប្រហែល៤៥,៤%នៃ GDP [4] ។ រយៈពេលដំបូង ADB បានចូលរួមជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ IMF និងធនាគារពិភពលោកនៅក្នុងការវិភាគបំណុលប្រកបដោយនិរន្តរភាព (DSA) សម្រាប់ប្រទេសកម្ពុជា [5] លទ្ធផលដំបូងបានបង្ហាញថា បច្ចុប្បន្នបំណុលរបស់ប្រទេសកម្ពុជា ស្ថិតនៅក្នុងស្ថានភាពបិតថេរមួយ និងបំណុលអាចប្រឈមមុខនឹងហានិភ័យនៅក្នុងកម្រិត មធ្យម ថ្មីៗនេះ ប្រទេសកម្ពុជាបានទទួលនូវឥណទានអាទិភាព ដោយមានការចាត់ថ្នាក់លំដាប់ $B^+$ ពី Standard and Poor's និងទទួលបានចំណាត់ថ្នាក់ B2 ពី Moody's ដែលអាចត្រួសត្រាយផ្លូវសម្រាប់បំណុលពាណិជ្ជកម្ម និងការបោះផ្សាយសញ្ញាប័ណ្ណទ្រព្យរបស់រដ្ឋាភិបាល ពីរយៈពេលមធ្យម ទៅរយៈពេលវែង ។ សូចនាករសេដ្ឋកិច្ចត្រូវបានភ្ជាប់នៅក្នុងតារាង ក ១.១ ។

៧. **ទស្សនវិស័យសេដ្ឋកិច្ច** : គេរំពឹងថាកំណើន GDP មានជាមធ្យមប្រហែល ៩.៣ % នៅឆ្នាំ ២០០៧ និង២០០៨ ដោយសារកំណើនជាបន្តបន្ទាប់នៅក្នុងផលិតផលកសិកម្ម និងសកម្មភាពទ្រទ្រង់ការនាំចេញសម្លៀកបំពាក់ វិស័យទេសចរណ៍ សំណង់ ការដឹកជញ្ជូន និងគមនាគមន៍ និងអចលនទ្រព្យ ។ កំណើនផ្អែកគម្រោងនាពេលឆាប់ៗនេះ ផ្អែកទៅលើសេចក្តីសន្និដ្ឋានសំខាន់ៗមួយចំនួន ដូចជា : ការថែរក្សាការត្រួតពិនិត្យម៉ាក្រូសេដ្ឋកិច្ច និងវិស័យសារពើពន្ធ ការគ្រប់គ្រងធនាគារប្រកបដោយភាពជាប់លាប់ និងប្រសិទ្ធភាពពីសំណាក់អាជ្ញាធររូបិយវត្ថុ ដើម្បីធានាឱ្យមានការអនុវត្តប្រព័ន្ធធនាគារមានលក្ខណៈល្អប្រសើរ ដោយសារកំណើនឥណទានក្នុងស្រុកលឿន ការអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធដើម្បីលើកទំនុកចិត្តលើអាជីវកម្ម និងលើកតំកើងការវិនិយោគ និងលំហូរចូលនៃកម្ចីសម្បទាន និងជំនួយឥតសំណងតាមរយៈការវិនិយោគបរទេសផ្ទាល់ (FDI) ។ ហានិភ័យមានការប្រកួតប្រជែងក្នុងវិស័យកាត់ដេរពីសាធារណរដ្ឋប្រជាមានិតចិន (PRC) វិធានការការពាររបស់សហភាពអឺរ៉ុប (EU) និងសហរដ្ឋអាមេរិក (US) ប្រឆាំងនឹងការនាំចេញសម្លៀកបំពាក់ ពីសាធារណរដ្ឋប្រជាមានិតចិន និងពីប្រទេសវៀតណាម បន្ទាប់ពីការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក អាកាសធាតុមិនអំណោយផល ដែលអាចជះផលប៉ះពាល់ដល់វិស័យកសិកម្ម និងគ្រោះមហន្តរាយ អាចមានដូចជា ជំងឺគ្រុនផ្តាសាយដែលអាចជះឥទ្ធិពលដល់បសុបក្សី និងទេសចរណ៍ ។

---

[4] បន្ទាប់ពីការពិចារណារួចមក បំណុលពីមូលនិធិអន្តរជាតិត្រូវបានបន្ធូរបន្ថយចំនួន៨២ លានដុល្លារអាមេរិក នៅឆ្នាំ២០០៦ និងចុះអប្បហារ ៧០%ដោយផ្ទាល់ទៅលើបំផុតដែលបានកំណត់ឡើងវិញជាមួយសហរដ្ឋអាមេរិក និងសភាពអឺរ៉ុប ដោយរាប់បញ្ចូលនៅក្នុងការវិភាគប្រកបដោយនិរន្តរភាពលើបំណុលដែលមិនទាន់សង ។ តួលេខនេះអាចបន្ថយរហូតដល់៣១%នៃ GDP ។

[5] សកម្មភាពនេះត្រូវបានចាប់ផ្តើមអនុវត្តនៅក្នុងខែឧសភា និងមិថុនា ឆ្នាំ២០០៧ និងរបាយការណ៍ចុងក្រោយនឹងត្រូវបានបញ្ចប់នៅចុងខែកក្កដា ឆ្នាំ២០០៧ ។

៨. របកគំហើញប្រេង និងឧស្ម័ននៅពេលថ្មីៗនេះអាចផ្លាស់ប្តូរទិសដៅកំណើន និងសុខមាលភាពរបស់ប្រជាជនកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារភាពមិនច្បាស់លាស់នៅជុំវិញការកំណត់ពេលវេលា និងទំហំរបស់ប្រេង និងឧស្ម័នដែលអាចប្រើប្រាស់បាន គេត្រូវវាយតម្លៃដោយប្រុងប្រយត្ន័ចំពោះការផលិតប្រេង និងឧស្ម័ន ខ្លាចមានផលប៉ះពាល់ ចាប់ពីដើមឆ្នាំ២០១១។ ការអនុវត្តនូវផែនការរបស់រដ្ឋាភិបាលនៅក្នុងការធ្វើឱ្យសេដ្ឋកិច្ចមានភាពសម្បូរបែប ដោយមិនចាំបាច់ពឹងផ្អែកលើប្រេង និង ឧស្ម័ន គឺជាគន្លឹះសំខាន់ចំពោះទស្សនវិស័យសេដ្ឋកិច្ចរបស់ប្រទេស។

## គ. ការរីកចម្រើនក្នុងការកាត់បន្ថយភាពក្រីក្រ

៩. នៅខែមិថុនា ឆ្នាំ២០០៦ រដ្ឋាភិបាលបានអនុម័តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៏ជាតិ (NSDP) សម្រាប់ឆ្នាំ២០០៦-២០១០ ដែលមានរៀបរាប់ពីយុទ្ធសាស្រ្តរបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រយ៉ាងបានឆាប់រហ័ស និងដើម្បីសម្រេចទុកគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏កម្ពុជា (CMDGs)។ លទ្ធផលនៃការស្ទាបស្ទង់ បានបង្ហាញថាភាពក្រីក្របានធ្លាក់ចុះជាលំដាប់ ចាប់តាំងពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់មក ភាគរយនៃប្រជាជនកម្ពុជាដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្របានធ្លាក់ចុះពីប្រហែល៤៧% នៅក្នុងឆ្នាំ១៩៩៤ មកត្រឹមប្រហែល៣៥% នៅឆ្នាំ២០០៤។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលភាពក្រីក្រត្រូវបានកាត់បន្ថយគម្លាតរវាងអ្នកមាន និងអ្នកក្រនៅតែកើនឡើង។[6] នេះជាករណីពិសេសមួយដែលកើតមាននៅក្នុងអំឡុងពេលឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ១៩៩៧ បន្ទាប់ពីនោះមក គម្លាតវិសមភាពមានលក្ខណៈថេរ។ លទ្ធផលការស្ទាបស្ទង់មតិដដែលបានបង្ហាញថា ភាពក្រីក្រ មានសភាពធ្ងន់ធ្ងរជាងមុននៅតាមតំបន់ជនបទ ភាពក្រីក្រថ្មីទូទាំងប្រទេសមាន៣៥% ភាពក្រីក្រនៅក្រុងភ្នំពេញមាន៤.៦% និង៣៩% នៅតាមតំបន់ជនបទ (តារាង ក១.២)។ ការស្ទាបស្ទង់មតិនៅក្នុងឆ្នាំ២០០៧ បានបង្ហាញថា ភាពក្រីក្រត្រូវបានកាត់បន្ថយនៅក្នុងសហគមន៏មួយចំនួន នៅតាមអាងបឹងទន្លេសាបចាប់តាំងពីឆ្នាំ១៩៩៧ ប៉ុន្តែការរីកចម្រើននេះ នឹងក្លាយជាការប្រឈមមួយនៅក្នុងតំបន់មួយដែលមានភាពក្រីក្រថ្មីខ្លាំងជាងគេនៅក្នុងប្រទេស។ មូលហេតុមួយដែលនៅតែធ្វើឱ្យភាពក្រីក្រកើនឡើងថ្មីៗក្នុងកម្រិតខ្ពស់នៅតាមតំបន់ជនបទនោះ គឺដោយសារកំណើនសេដ្ឋកិច្ចបានពឹងផ្អែកយ៉ាងខ្លាំងទៅលើការនាំចេញសម្លៀកបំពាក់ វិស័យទេសចរណ៏ និងការសាងសង់ (ជាវិស័យដែលរីកចម្រើននៅតែក្នុងទីក្រុង និងមិនមានទំនាក់ទំនងជាមួយនឹងសេដ្ឋកិច្ចនៅ តាមតំបន់ជន)។

១០. វិសាសភាពការងាររបស់រដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងភាពក្រីក្រ បញ្ហាប្រឈមរបស់សង្គម ត្រូវបានបង្ហាញតាមរយៈការអនុវត្តការងាររួមក្នុងការសម្រេចគោលដៅរបស់ CMDG (តារាង ក១៣ និងក១.៤)។ មរណភាពកុមារត្រូវបានកាត់បន្ថយ ហើយរដ្ឋាភិបាលបានបោះជំហានទៅមុខជាលំដាប់នៅក្នុងការលើកម្ពស់សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្រ្តី។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានអនុវត្តឱ្យបានល្អប្រសើរនៅក្នុងគោលដៅនៃការកាត់បន្ថយភាពក្រីក្រ និងភាពអត់ឃ្លានខ្លាំងបំផុត ការសម្រេចបានការអប់រំថ្នាក់បឋមសិក្សាជាសាកល ការលើកកម្ពស់សុខភាពមាតា និងធានាឱ្យបានប្រកបដោយបរិយាកាសនិរន្តរភាព ។ មានបញ្ហាជាច្រើនដែលត្រូវយកចិត្តទុកដាក់។ ទីមួយ ការចំណាយទៅលើការអប់រំ កើនឡើងប្រាំដងចាប់ពីឆ្នាំ១៩៩៤ រហូតដល់ឆ្នាំ២០០៧ រដ្ឋាភិបាលមិនបានសម្រេចទិសដៅរបស់ខ្លួន តាមគោលដៅសម្រេចឱ្យបាននូវការអប់រំថ្នាក់បឋមសិក្សាជាសាកល។ ទីពីរ អត្រាមរណភាពមាតាមានសភាពធ្ងន់ធ្ងរជាងមុន ទោះបីជា មានការចំណាយទៅលើវិស័យសុខាភិបាល

---

[6] ការប្រៀបធៀបការប្រើប្រាស់ក្នុងម្នាក់ជាមធ្យម នៅឆ្នាំ២០០៤ ដែលផ្ទុយពីឆ្នាំ១៩៩៤ បានបង្ហាញថាការប្រើប្រាស់របស់អ្នកក្រជាងគេលំដាប់ទី៥ បានកើនឡើងត្រឹមតែ៨% ប៉ុន្តែសម្រាប់អ្នកមានជាងគេលំដាប់ទី៥ បានកើនឡើងរហូតដល់៤៥%។

កើនឡើងប្រាំពីរដងក៏ដោយ។ ទីបី មានការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់អភិរក្សព្រៃឈើ និងការដាំដើមឈើឡើងវិញ[៧] ។ ទីបួន រដ្ឋាភិបាល ដើរនៅលើមាគារបស់ខ្លួនដើម្បីផ្តល់ទឹកស្អាតដល់ប្រជាជន និងបញ្ហាទឹកស្អាតផ្តល់ដល់ប្រជាជននៅជនបទ នៅតែជាបញ្ហាធ្ងន់ធ្ងរ។[៨]

**ឃ. ការវាយតម្លៃហានិភ័យ**

១១. **សេចក្តីសង្ខេប :** ទោះបីជាមានការលើកកម្ពស់អភិបាលកិច្ចក៏ដោយ[៩] អំពើពុករលួយនៅតែរីករាលដាល។ ការអនុវត្តច្បាប់ ដែលមានស្រាប់នៅតែមានភាពមិនរលូន និងច្បាប់ប្រឆាំងអំពើពុករលួយមានការរីកចម្រើនតិចតួចណាស់។ ដូច្នេះជាលទ្ធផល ការអនុវត្តការងាររបស់កម្ពុជាក្នុងគម្រោង ADB ឆ្នាំ២០០៥ និង២០០៦ ការវាយតម្លៃការអនុវត្តការងារឆ្នាំ២០០៦ (CPAs) ស្ថិតនៅក្រោមកម្រិតមធ្យមរបស់ប្រទេសដែលទទួលចំណាត់ថ្នាក់ A[១០] ។ ជាលទ្ធផលការពិនិត្យឡើងវិញពាក់កណ្តាលអណត្តិ ផ្តោតសំខាន់ទៅលើប្រសិទ្ធភាពនៃផែនការគ្រប់គ្រងហានិភ័យ ជាពិសេសចំពោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) លទ្ធកម្ម និងការខំប្រឹងប្រែងដទៃទៀតដើម្បីកាត់បន្ថយហានិភ័យនៃអំពើពុករលួយ ដែលជះឥទ្ធិពលមកលើប្រតិបត្តិការរបស់ ADB នៅប្រទេសកម្ពុជា។

១២. **ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ :** ឯការប្រជុំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាខែមេសា ឆ្នាំ២០០៧ ម្ចាស់ជំនួយបានធ្វើការសន្និដ្ឋានថា មានការរីកចម្រើនគួរឱ្យកត់សម្គាល់នៅក្នុងការរកថវិកាសម្រាប់កម្ចី និងបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រដ្ឋបាភិបាល ដើម្បីដាក់ចេញនូវកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទៅកាន់ក្រសួងពាក់ព័ន្ធទាំងអស់។ ទោះបីជា យ៉ាងណាក៏ដោយ ម្ចាស់ជំនួយក៏បានយល់ស្របថា ក្រសួងពាក់ព័ន្ធចាំបាច់ត្រូវតែធានា (១) ការរួមបញ្ចូលទូលំទូលាយនៃការប្រើ ប្រាស់ធនធានសាធារណៈ សម្រាប់ការបង្កើតគម្រោងថវិកា និងគោលបំណងធ្វើផែនការ (២) ការអនុវត្តតាមគោលនយោបាយ និងនីតិវិធីស្តីពីថវិកា និង (៣) ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ជាមួយការបណ្តុះបណ្តាលបុគ្គលិកយ៉ាងត្រឹមត្រូវ ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ។

១៣. **លទ្ធកម្ម :** ការពិនិត្យឡើងវិញនូវការអនុវត្តការងាររួមប្រចាំប្រទេស ដែលមានការសហការរវាង ADB និងធនាគារពិភពលោក (JCPPR) នៅក្នុងឆ្នាំ២០០៦ បាននាំទៅរកការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) នៅខែ

---

7 ទំហំនៃដីដែលគ្របដណ្តប់ដោយព្រៃឈើកាន់តែរួមតូចពី៦០% នៅឆ្នាំ២០០២ រហូតដល់៥០% នៅឆ្នាំ២០០៥ ប៉ុន្តែនៅមានការបារម្ភច្រើនទៀតទៅលើគុណភាពនៃព្រៃឈើការពារ។

8 មានត្រឹមតែ៤២ ក្នុងចំនោម១០០នាក់ ដែលរស់នៅតាមតំបន់ជនបទ អាចបាននូវទឹកបរិភោគដែលមានសុវត្ថិភាព ដោយប្រៀបធៀបជាមួយនឹងប្រហែលជា៧៦ ក្នុងចំនោម១០០នាក់ដែលរស់នៅក្នុងទីក្រុង។

9 មានការវិវត្តន៍នៅក្នុងឆ្នាំ២០០៧ នៅក្នុងចំនុច (១) គោលនយោបាយការអនុវត្តវិមជ្ឈការ និងវិសហជ្ឈការដែលបានកំណត់ ដើម្បីជំរុញឱ្យមានការចូលរួមពីប្រជាជនសម្រាប់អភិបាលកិច្ចប្រចាំតំបន់ដែលមានទំនួលខុសត្រូវ (២) ការបង្កើតទម្រង់ការស្របច្បាប់ទំនើប (ឧទាហរណ៍ ក្រមនីតិវិធីប្បវេណី ច្បាប់សេដ្ឋកិច្ច) និងច្បាប់ស្តីពីធនធានធម្មជាតិសំខាន់ៗ និង (៣) ការសម្រេចចិត្តលើបញ្ហាទាំងឡាយណាដែលទាក់ទងនឹងនីតិវិធី នៅក្នុងការប្រតិបត្តិការរបស់អង្គការសហប្រជាជាតិដែលបានជួយគាំទ្រដល់អង្គជំនុំជម្រះវិសាមញ្ញកម្ពុជា (ECCC)។

10 ប្រទេសកម្ពុជា សាធារណៈរដ្ឋ Kyrgyz សាធារណៈរដ្ឋប្រជាមានិតឡាវ ម៉ុងកូលី នេប៉ាល់ Taíkistan និង ADB នៃ DMCs។ ការចាត់ថ្នាក់របស់ CPA សម្រាប់ ឆ្នាំ២០០៦ នឹងមានភ្ជាប់នៅឧបសម្ព័ន្ធ ២។ ការអនុវត្ត CPA នៅក្នុងឆ្នាំ២០០៧ នៅប្រទេសកម្ពុជានៅនឹងត្រូវអនុវត្តនៅត្រីមាសទី៣ ឆ្នាំ២០០៧។

មករា ឆ្នាំ២០០៧ ជាមួយនឹងរដ្ឋាភិបាល។ នៅក្នុង MOU នេះ រដ្ឋាភិបាលបានប្ដេជ្ញាចិត្តអនុវត្តនូវផែនការសកម្មភាពរួមជាមួយ អនុសាសន៍ ដែលបានមកពីការពិនិត្យឡើងវិញរួមគ្នារវាង ADB និង WB មានគូសបញ្ជាក់ហានិភ័យ ប្រកបដោយទុកចិត្ត[១១] ។

១៤. **ការកាត់បន្ថយហានិភ័យអំពើពុករលួយ :** ដើម្បីជាទិន្នន័យសម្រាប់ការត្រួតពិនិត្យឡើងវិញនូវពាក់កណ្ដាលអាណត្តិ ការវាយតម្លៃហានិភ័យអភិបាលកិច្ច ត្រូវបានអនុវត្តដោយក្រសួងពីរ គឺក្រសួងអភិវឌ្ឍន៍ជនបទ (MRD) និងក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ការប៉ាន់ប្រមាណស្វែងចំណុចខ្សោយរបស់ស្ថាប័ន និងចំណុចពិសេសរបស់អំពើពុករលួយ។ នៅពេលដែលមានការគាំទ្រការកែទម្រង់ PFM ក្រសួងទាំងពីរនេះផ្ដល់អនុសាសន៍ភ្លាមៗ អំពីវិធានការកាត់បន្ថយអំពើពុករលួយ ដោយទទួលស្គាល់ថា កំណែទម្រង់ប្រពន្ធ័រដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងពាក់ ពន្ធ័ភារកិច្ចរយៈពេលមធ្យមរហូតដល់រយៈពេលវែង។ របាយការណ៍ទាំងនេះ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធបន្ថែម ក និង ខ។

**ង. ការពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្ររបស់ប្រទេស**

១៥. **ទំនាក់ទំនងបន្តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ :** យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅក្នុង CSP របស់ ប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០០៥-២០០៩ តាមរយៈកំណើនដ៏លើសលុបនាំមុខលើវិស័យឯកជន ការអភិវឌ្ឍសង្គមរួម និងអភិបាលកិច្ច ដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅតែមានទំនាក់ទំនងគ្នា។ ទោះបីយ៉ាងណាក៏ដោយ ភាពក្រីក្រនៅតាមតំបន់ជនបទដែលមានកម្រិតខ្ពស់ មានការពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ CSP ។

១៦. **ការសង្កត់ធ្ងន់ទៅលើផ្នែកកសិកម្ម និងការអភិវឌ្ឍជនបទ :** ទំនាក់ទំនងទីមួយ គឺត្រូវការវិស័យមួយផ្ដោតទៅលើកសិកម្ម ការអភិវឌ្ឍតំបន់ជនបទ ដើម្បីឆ្លើយតបទៅនឹងអាទិភាពរបស់រដ្ឋាភិបាល[១២] ។ ជំនួយរបស់ ADB សម្រាប់គម្រោង CSP ដែលនៅសល់ គួរតែបន្តការយកចិត្តទុកដាក់ឱ្យខ្លាំងជាងនេះទៅលើផ្នែកកសិកម្ម និងតំបន់ជនបទ ដោយរួមមានទាំងគម្រោងអភិវឌ្ឍន៍នៅតាមតំបន់ជនបទ ពង្រីកផ្នែកហិរញ្ញវត្ថុនៅតាមតំបន់ជនបទ ពង្រីកលទ្ធភាពក្នុងការទទួលប្រាក់កម្ចី ធ្វើវិមជ្ឈការទៅលើការចុះបញ្ជីអាជីវកម្មនៅតាមតំបន់ជនបទ បង្កើនចំណេះដឹង (ឧទាហរណ៍ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបច្ចេកទេស) សម្រាប់កសិករ និងឧស្សាហកម្មនៅតាមតំបន់ជនបទ និងគំនិតផ្ដួចផ្ដើមនៅតាមតំបន់ទន្លេមេគង្គ (TSI) ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនរស់នៅតាមតំបន់ទន្លេមេគង្គ។

១៧. **ជំរុញកំណើនវិស័យឯកជន :** ទំនាក់ទំនងទីពីរ គឺយុទ្ធសាស្ត្ររបស់ ADB ជំរុញកំណើន ចាប់តាំងពីឆ្នាំ២០០៤ វិស័យឯកជនជាចម្បង។ ការកសាងស្ថិតក្នុងបរិបទអភិវឌ្ឍន៍ប្រកបដោយថាមវន្តនៅកម្ពុជា ហើយ ADB នឹងបង្កើនការចូលរួមនៅក្នុងវិស័យឯកជន ដើម្បីបំលែងភាពជឿនលឿន គោលនយោបាយសាធារណៈ ទៅជាការវិនិយោគប្រកបដោយនិរន្តរភាព នៅក្នុងខឿនសេដ្ឋកិច្ច។ ការអភិវឌ្ឍអាជីវកម្មនៅតាមសហគមន៍ នឹងជួយទ្រទ្រង់ដល់កំណែទម្រង់នៅក្នុងប្រទេស។

១៨. **ការបង្កើនការគ្រប់គ្រងហានិភ័យ :** ទំនាក់ទំទងទីបី គឺតម្រូវការក្នុងការបង្កើនការគ្រប់គ្រងហានិភ័យ ។ នៅក្នុង

---

[11] ទាំងនេះមានដូចជា : ការពិនិត្យឡើងវិញដែលមានទំនុកចិត្ត របស់គម្រោងដែលបានពន្យារពេលទាំងបីរបស់ធនាគារពិភពលោក និងការិយាល័យអគ្គសវនករ របស់ ADB និងនីតិវិធីរបស់អាជ្ញាធរសវនកម្មជាតិ (NAA) ដែលទាក់ទងនឹងគម្រោងអភិវឌ្ឍន៍តំបន់ជនបទភាគពាយ័ព្យ។

[12] ដូចដែលបានបញ្ជាក់ដោយលោកនាយករដ្ឋមន្ត្រីនៅក្នុងវេទិកាសេដ្ឋកិច្ចកម្ពុជាលើកទី២ ដែលប្រារព្ធឡើងនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៧ ស្ដីពីការបង្កើនល្បឿននៅក្នុងការអភិវឌ្ឍផ្នែកកសិកម្ម និងតំបន់ជនបទនៅក្នុងប្រទេសកម្ពុជាតម្រូវឱ្យមានជំនួយពីវិស័យផ្សេងៗ និងពីគ្នាទៅវិញទៅមក។ លោកបានបង្ហាញពីផ្នែកដែលជាអាទិភាពទាំងប្រាំមួយដែលមានដូចជា : ហេដ្ឋារចនាសម្ព័ន្ធនៅតាមតំបន់ជនបទ ហិរញ្ញនៅតាមតំបន់ជនបទ ធនធាន និងការអនុវត្តនៅក្នុងផ្នែកកសិកម្ម ការគ្រប់គ្រងដីធ្លី ការចូលរួមពីសំណាក់វិស័យឯកជន និងតួនាទីរបស់រដ្ឋដើម្បីសម្របសម្រួលសេដ្ឋកិច្ចនៅតាមតំបន់ជនបទប្រកបដោយនិរន្តរភាព និងចលករ។

ប្រទេសកម្ពុជា មានហានិភ័យបីប្រភេទធំៗ។ ទីមួយ ហានិភ័យដែលបណ្តាលមកពីការប្រើប្រាស់មូលនិធិសាធារណៈមិនអស់លទ្ធភាព។ នៅពេលដែលស្ថាប័នសាធារណៈនៅតែទន់ខ្សោយ ប្រាក់ចំណូលខ្ពស់ដែលនឹងកើនឡើងដោយសារកំណើនសេដ្ឋកិច្ច ដ៏ខ្លាំងក្លានោះ អាចបញ្ចប់ ដោយសារការបែងចែកខុស និងការចំណាយគ្មានប្រសិទ្ធភាព។ ទីពីរ ស្ថាប័នខ្សោយអាចបណ្តាលឱ្យបរាជ័យនៅក្នុងការធ្វើឱ្យសេដ្ឋកិច្ចមានលក្ខណៈសម្បូរបែប។ ទីបី លទ្ធផលនៃការវាយតម្លៃស្ថានភាពហានិភ័យនៃអភិបាលកិច្ចរបស់ MRD និង MOWRAM បានបង្ហាញថា ភាពទន់ខ្សោយរបស់ស្ថាប័ន នាំឱ្យមានហានិភ័យខ្ពស់នៃអំពើពុករលួយ ដែលចាំបាច់ត្រូវមានកំណើនសេដ្ឋកិច្ចជាមូលដ្ឋាន។ តម្រូវការជំនួយ ដើម្បីកសាង និងពង្រឹងសមត្ថភាពសវនកម្មផ្ទៃក្នុង ដើម្បីអភិវឌ្ឍន៍ជនបទជាមួយក្រសួងពាក់ព័ន្ធ។ ការធ្វើរបៀបនេះ អាចជួយឱ្យការគ្រប់គ្រងហិរញ្ញវត្ថុមានប្រសិទ្ធភាព និងការឆ្លើយតបដល់ស្ថាប័នដែលឃ្លាំមើល ដូចជាអាជ្ញាធរសវនកម្មជាតិ ដែលត្រូវមានសមត្ថភាព ដើម្បីអនុវត្តសវនកម្មគ្រប់ប្រភេទទាំងអស់ នៅក្នុងក្រសួងដែលពាក់ព័ន្ធ និងដាក់ចេញនូវទណ្ឌកម្មរដ្ឋបាលនៅពេលដែលចាំបាច់។

## II. ការអនុវត្តយុទ្ធសាស្ត្រប្រចាំប្រទេស

### ក. វឌ្ឍនភាពនៅក្នុងយុទ្ធសាស្ត្រជាតិ[១៣]

១៩. **វិស័យទេសចរណ៍ :** តាមការពិនិត្យឡើងវិញ វិស័យទេសចរណ៍បានក្លាយជាវិស័យដ៏សំខាន់មួយដែលធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ដែលមានចំនួនភ្ញៀវមកដល់ប្រហែលជា១.៧លាននាក់ នៅក្នុងឆ្នាំ២០០៦ និងត្រូវបានរំពឹងថាមានការកើនឡើងលើសពី២លាននាក់ នៅឆ្នាំ២០០៧។ ទេសចរណ៍ធម្មជាតិមានការគាំទ្រដោយប្រយោល ដូច្នេះអត្ថប្រយោជន៍ទេសចរណ៍ អាចនាំមកដល់អ្នកក្រីក្រនៅតាមតំបន់ជនបទ។ ទោះបីយ៉ាងណាក៏ដោយ គម្រោងទេសចរណ៍ថ្មីៗ មិនទទួលបានការគាំទ្រទេ។

២០. **ការដឹកជញ្ជូន ថាមពល និងសុខាភិបាល :** ចំពោះវិស័យទាំងនេះ ADB បានសម្រេចចិត្តបញ្ឈប់ការផ្តល់ជំនួយបន្តិចម្តងៗ និងងាកទៅជួយគាំទ្រដល់ការងារវិភាគថ្មីៗ និងគម្រោងផ្តួចផ្តើមនៅតាមអនុតំបន់។ នៅក្នុងការដឹកជញ្ជូន មានការរីកចម្រើនលើការរៀបចំច្បាប់ និងស្ថាបន័សំខាន់ៗជំហានចាប់ផ្តើមសំខាន់ៗ ការប្រកួតប្រជែងនៅក្នុងការដឹកជញ្ជូនរវាងតំបន់នីមួយៗ និងការទាក់ទាញចំណាប់អារម្មណ៍ម្ចាស់ជំនួយទៅលើវិស័យដឹកជញ្ជូនជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារមានប្រឈមបន្តបន្ទាប់ក្នុងការផ្តល់លទ្ធភាពទៅកាន់ជនបទ និងស្តង់ដាអនុវត្ត ADB នឹងបង្វែរការផ្តល់កម្ចីសាធារណៈខ្នាតធំ សម្រាប់ការសាងសង់ផ្លូវជាតិ និងផ្លូវរថភ្លើង ទៅ (១) ពង្រីកសហប្រតិបត្តិការផ្នែកបច្ចេកទេស ការកំណត់បទដ្ឋាន និងការវិនិយោគឯកជន នៅក្នុងវិស័យដឹកជញ្ជូនជាតិ និង (២) គាំទ្រគម្រោងនៅតាមអនុតំបន់ ដែលបង្កើនលទ្ធភាពក្នុងការទៅដល់តំបន់ជនបទដាច់ស្រយាល ប្រតិបត្តិកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនឆ្លងព្រំដែន បង្កើតមូលដ្ឋានសម្រាប់ពាណិជ្ជកម្មនៅតាមមហាអនុតំបន់មេគង្គ GMS នៅជំនាន់ទីពីរ និងគាំទ្រឧបត្ថម្ភសម្រាប់តំណាក់កាលអនុវត្តយុទ្ធសាស្ត្រភាពជាដៃគូលើកក្រោយទៀត។ នៅក្នុងវិស័យថាមពល បណ្តាញចែកចាយ និងការប្រើប្រាស់អគ្គិសនីក្នុងម្នាក់ ត្រូវបានពង្រីក ហើយមានការកែលំអជាលំដាប់ នៅសុខមាលភាពហិរញ្ញវត្ថុ នៅអគ្គិសនីកម្ពុជា (EDC) និងធ្វើឱ្យមានការរំពឹងទុកថា គេនឹងអាចស្រង់ដើមនៅឆ្នាំ២០០៨ និងបង្កើនអត្ថប្រយោជន៍ នៅក្នុងវិស័យឯកជនដែលធ្វើអាជីវកម្មនៅក្នុងវិស័យនេះ។ ប៉ុន្តែការបង្កើតលទ្ធភាពប្រើប្រាស់ថាមពល បង្កើនលទ្ធភាពប្រើប្រាស់អគ្គិសនី នៅតាមតំបន់ជនបទ និងការបំពេញតម្រូវការខ្ពស់ក្នុងការប្រើបាស់ថាមពលនៅក្នុងខឿនសេដ្ឋកិច្ច ដែលកំពុងលូតលាស់ធ្វើឱ្យមានបញ្ហាប្រឈមជាច្រើន។ ដូច្នេះ ADB នឹងបង្វែរការផ្តល់កម្ចីវិស័យសាធារណៈសម្រាប់អគ្គិសនី ទៅជា (១) ការអនុវត្តប្រកបដោយប្រសិទ្ធភាពលើ

---

[13] វិស័យអាទិភាពថ្មីៗ និងប្រធានបទសំខាន់ៗនឹងមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ៣។ គម្រោងផែនការយ៉ាងលម្អិតស្តីពីការអនុវត្តវិស័យនីមួយៗនឹងមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធបន្ថែម គ។ ការវាយតម្លៃរវាងវិស័យ លើបញ្ហាយេនឌ័រ និងការការពារសង្គម នៅក្នុងឧបសម្ព័ន្ធបន្ថែម ឃ និង ង។

គម្រោងវិស័យសាធារណៈ ដែលកំពុងដំណើរការ (២) គាំទ្រលើប្រតិបត្តិការរបស់វិស័យឯកជន និង (៣) គាំទ្រលើការងារវិភាគគោលនយោបាយ និងបច្ចេកទេសប្រេង និងឧស្ម័ន និងការរុករកថាមពលថ្មីៗ នៅតាមអនុតំបន់។ នៅវិស័យសុខាភិបាល ដោយមានការវិវត្ត នៅក្នុងសូចនាករក្នុងវិស័យសុខាភិបាល មានការចូលរួមយ៉ាងខ្លាំងក្លាពីសំណាក់ម្ចាស់ជំនួយ និងការបែងចែកសំខាន់ៗលើជំនួយរបស់ម្ចាស់ផ្តល់ជំនួយ ដែលឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ស្តីពីប្រសិទ្ធិភាពជំនួយប្រចាំឆ្នាំ២០០៧[14] ADB នឹងបញ្ឈប់អន្តរាគមន៍លើវិស័យសុខាភិបាលបន្តិចម្តងៗ និងខំបង្វែរការខំប្រឹងប្រែងទៅរកការគាំទ្រសុខាភិបាលប្រយោល តាមរយៈការផ្តល់ទឹក និងអនាម័យ និងគំនិតផ្តួចផ្តើមអនុតំបន់ស្តីពីការទប់ស្កាត់ជំងឺឆ្លង ការពិចារណាយកចិត្តទុកដាក់ដើមហេតុជំងឺឆ្លង និងយកចិត្តទុកដាក់លើការប្រឈមទាំងនេះ ជាពិសេសជម្ងឺឆ្លងដែលមានសភាពធ្ងន់ធ្ងរនៅតំបន់ជនបទដាច់ស្រយាល និងលក្ខណៈអនុតំបន់។ ការបង្វែរទិសដៅប្រតិបត្តិការស្របទៅនឹងការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិនៃគម្រោងយុទ្ធសាស្រ្ត GMS[15] នៅខែមិថុនា ឆ្នាំ២០០៧ ដែលបានធ្វើការសន្និដ្ឋានថា វឌ្ឍនភាពមានលក្ខណៈល្អប្រសើរនៅក្នុងទិដ្ឋភាពរូបវន្តនៃសហប្រតិបត្តិការ វឌ្ឍនភាពតិចតួចក្នុងការកសាងសមត្ថភាព ដែលវឌ្ឍនភាពនេះមិនត្រឹមតែមានសារៈសំខាន់ណាស់សម្រាប់កម្មវិធី GMS ប៉ុណ្ណោះទេ ប៉ុន្តែក៏សំខាន់នៅក្នុងការអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍប្រទេស និងសម្រេចឱ្យបាននូវ CMDGs ផងដែរ។

២១. **វិស័យហិរញ្ញវត្ថុ សហគ្រាសខ្នាតតូច និងមធ្យម និងវិស័យអប់រំ :** នៅក្នុងវិស័យទាំងនេះ ចាំបាច់ត្រូវមានជំនួយពី ADB លើកទីពីរ ដើម្បីឆ្លើយតបទៅនឹងសេដ្ឋកិច្ចដែលកំពុងតែលូតលាស់។ ជំនឿទុកចិត្តទៅលើវិស័យហិរញ្ញវត្ថុដ៏ក្មេងខ្ចីបានកើនឡើង ប៉ុន្តែនៅតែប្រឈមមុខនឹងហានិភ័យ និងការចំណាយដែលបញ្ជាក់យ៉ាងច្បាស់ពីកំណើនសេដ្ឋកិច្ចមានល្បឿនលឿន។ ជាលទ្ធផលប្រតិបត្តិការនៅក្នុងវិស័យហិរញ្ញវត្ថុរបស់ ADB នឹងផ្តោតសំខាន់ទៅលើការគ្រប់គ្រងហានិភ័យ និងចំណាយតាមរយៈផែនការអភិវឌ្ឍតាមវិស័យជាបន្តបន្ទាប់ នៅក្រោមយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងការអនុម័តសេចក្តីព្រាងច្បាប់សេដ្ឋកិច្ច ដែលពាក់ព័ន្ធនឹង WTO។ វិធីសាស្រ្តនេះ នឹងជំរុញឱ្យមានកំណែទម្រង់ទីផ្សារមូលធន និងទស្សនៈវិស័យសម្រាប់ ឱកាសពាណិជ្ជកម្មនាពេលអនាគត។ ចំពោះ SMEs ការអនុម័តលើគម្រោងអភិវឌ្ឍន៍ SMEs (SMEDF) ជាតិនៅចុងឆ្នាំ២០០៥ គឺត្រូវធ្វើឡើងដោយគោរពទៅតាមអភិបាលកិច្ចសាជីវកម្ម SME។ សិទ្ធិទទួលបានហិរញ្ញវត្ថុ មានការកែលំអ និងការធ្វើវិមជ្ឈការទៅលើការចុះបញ្ជី។ ជំនាញសហគ្រិន បច្ចេកវិទ្យា ធនធានមនុស្ស និងប្រព័ន្ធតម្លៃចាំបាច់ត្រូវតែពង្រឹង។ ចំពោះវិស័យអប់រំ ទោះបីមានការបង្កើតផែនការទូលំទូលាយច្បាស់លាស់ ភាពរីកចម្រើនក្នុងការរៀបចំទម្រង់ច្បាប់ និងកំណើនការបែងចែកថវិកាក៏ដោយ ក៏ការឆ្លើយតបតាមទិសដៅ CMDG ក្នុងការអប់រំជាសកលនៅតែលំបាក។ អត្រានៃការបោះបង់ការសិក្សាត្រូវតែថយចុះ អត្រានៃការចុះឈ្មោះសរុបនៅកម្រិតបឋមសិក្សាដែលជួបឧបសគ្គ ត្រូវបានដោះស្រាយ កុមារពុំមានលទ្ធភាពចូលរៀននៅក្នុងការអប់រំក្នុងប្រព័ន្ធត្រូវបានដោះស្រាយ។ ទី(១) ការផ្តោតសំខាន់ទៅលើគុណភាព ដើម្បីកែលំអស្តង់ដា និងការផ្តល់សិទ្ធិចូលរៀន ទី (២) ការគាំទ្របន្ថែមទៀតពីម្ចាស់ជំនួយសម្រាប់កំណែទម្រង់គ្រឹះស្ថានសិក្សានៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរដ្ឋបាលអប់រំផ្តល់លើការលើកទឹកចិត្ត និងទី (៣) ទំនាក់ទំនងរវាងការអប់រំ និងការអភិវឌ្ឍជនបទ ដើម្បីពង្រឹងជំនាញកម្លាំងពលកម្មនៅតាមតំបន់ជនបទដែលកំពុងតែលូតលាស់ រួមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេសដែលមានលក្ខណៈជឿនលឿន។

២២. **កសិកម្ម និងធនធានធម្មជាតិ ហេដ្ឋារចនាសម្ព័ន្ធនៅតាមតំបន់ជនបទ :** ADB ទទួលស្គាល់ថា សេដ្ឋកិច្ចនៅតាមតំបន់ជនបទចាំបាច់ត្រូវតែមានការពង្រីក។ ភាពក្រីក្រដែលនៅតែមានកម្រិតខ្ពស់ នៅតាមជនបទត្រូវតែធ្វើការកាត់បន្ថយ និង

---

[14] Royal Government of Cambodia. 2007. The Aid Effectiveness Report. Phnom Penh.
[15] Mid-term Review of the 10 years GMS Strategic Framework (2002-2012): GMS Unit SERD, ADB.

វឌ្ឍនភាពយឺតៗ នៅក្នុងកសិកម្ម និងធនធានធម្មជាតិត្រូវតែពន្លឿន ទោះបីជាកំណើនយ៉ាងខ្លាំងក្លានៅក្នុងឆ្នាំ២០០៥ និង២០០៦ក៏ដោយ។ រដ្ឋាភិបាលបានស្នើសុំឱ្យ ADB ដើរតួនាំមុខនៅក្នុងកសិកម្ម និងការអភិវឌ្ឍជនបទ។ ដូច្នេះ ADB នឹងផ្តោតទៅលើ (១) បង្កើនផលិតភាពកសិកម្មដែលមានលក្ខណៈប្រពលវប្បកម្ម និងការចិញ្ចឹមជីវិតដោយរុងរឿង (២) គាំទ្រគោលនយោបាយអភិវឌ្ឍន៍ពហុវិស័យនៅតាមតំបន់ជនបទ និងការរៀបចំស្ថាប័នដើម្បីសម្របសម្រួលការងារអន្តរាគមន៍នៅតាមវិស័យ រួមមានការតាំងចិត្តរយៈពេលមធ្យមចំពោះការផ្គត់ផ្គង់ទឹក និងអនាម័យនៅតាមតំបន់ជនបទ (៣) លើកកម្ពស់ការអភិវឌ្ឍពហុវិស័យ នៅតាមតំបន់ជនបទតាមរយៈគំនិតផ្តួចផ្តើមតំបន់ទន្លេសាប (៤) ពង្រឹងធនធានទឹក និងការគ្រប់គ្រងអាងទន្លេចម្រុះ ចំពោះការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព (៥) គាំទ្រ PFM ដល់ក្រសួងអភិវឌ្ឍន៍ជនបទ[១៦] និង (៦) ទ្រទ្រង់ការចិញ្ចឹមជីវិតនៅ តាមតំបន់ជនបទតាមរយៈដំណោះស្រាយ "កសិកម្មថ្មី" អនុតំបន់ដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមនឹងបរិស្ថានបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងការកើនឡើងផលប៉ះពាល់ទៅលើជីវចម្រុះ ទឹក និងដី ព្រមទាំងការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះទឹកជំនន់ និងរាំងស្ងួត។ វិធីសាស្ត្រនេះ នឹងត្រូវតម្រង់ទិសតាមការសិក្សា ដី ទឹក បច្ចេកវិទ្យា ហិរញ្ញវត្ថុ និងទីផ្សារនៅក្នុងវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ និងជម្រើសការវិនិយោគ។

**ខ. ការបង្ហាញត្រួសៗពីការសម្របសម្រួលមូលនិធិបរទេស និងការរៀបចំដៃគូ**

២៣. រដ្ឋាភិបាលបន្តការពឹងផ្អែកលើហិរញ្ញប្បទានពីខាងក្រៅ សម្រាប់គ្រប់គម្រោងអភិវឌ្ឍន៍វិស័យសាធារណៈសំខាន់ៗ នៅក្នុងប្រទេសកម្ពុជា។[១៧] ម្ចាស់ជំនួយបានសន្យាថាផ្តល់៦០១លានដុល្លាសហរដ្ឋអាមេរិក សម្រាប់ជំនួយអភិវឌ្ឍន៍ជាផ្លូវការ (ODA) នៅឆ្នាំ២០០៦។[១៨] ការផ្តល់កម្ចី ADF រយៈពេល៣ឆ្នាំ តាមការចង្អុលទិសរបស់ ADB និងការចែកចាយទឹកប្រាក់ចំនួន២០៤.៣ លានដុល្លា (មិនមែនប្រាក់កម្ចី Non lording) ដែលរៀបចំសម្រាប់រយៈពេលនៅសល់របស់ CSP ២០០៧-២០០៩ ។[១៩]

២៤. ការបែងការងារអនុវត្តសាកល្បងរបស់កម្ពុជា (PBA) មានទឹកប្រាក់ចំនួន៩៩,៦លានដុល្លាអាមេរិកសម្រាប់ឆ្នាំ ២០០៧-២០០៩។[២០] កំណើនយ៉ាងខ្លាំងក្លា និងការគ្រប់គ្រងបំណុលឱ្យកាន់តែប្រសើរ ព្រមទាំងការវិភាគនិរន្តរភាពនៃបំណុលដែលកំពុងធ្វើ បញ្ជាក់ថា កម្ពុជាគួរពិចារណាបំណុលកម្រិតមធ្យម។ ដូច្នេះ ការរួមបញ្ចូលប្រាក់កម្ចីរបស់ ADB និងជំនួយឥតសំណងរបស់មូលនិធិអភិវឌ្ឍន៍អាស៊ី (ADF) (ដែលមានអប្បហារបំណុលក្នុងកម្រិតមធ្យម) អាចទាញការសន្និដ្ឋាន DSA និង ADF និងអនុវត្តគម្រោងសហគមន៍អភិវឌ្ឍន៍អន្តរជាតិក្នុងឆ្នាំ២០០៧។

---

16 MAFF, MOWRAM, MRD និង NAA បានអនុវត្តនូវទស្សនៈនៃកំណែទម្រង់លើ PFM សម្រាប់ការអភិវឌ្ឍជនបទ។

17 ម៉ាទ្រីកសម្របសម្រួលការអភិវឌ្ឍនឹងមានភ្ជាប់នៅឧបសម្ព័ន្ធ ៤។ ពីឆ្នាំ១៩៩២ ដល់២០០៦ ODA បានផ្តល់ប្រាក់ដល់ប្រទេសកម្ពុជារហូតដល់៦.៩កោដិដុល្លាអាមេរិក។ នៅក្នុងឆ្នាំ២០០៦ ODA បានផ្តល់ប្រហែលជា៦០១លានដុល្លាសហរដ្ឋអាមេរិក ដែលស្មើនឹងប្រហែល៨%នៅក្នុង GDP។

18 ដោយផ្អែកលើនិយមន័យដែលបានកែតម្រូវឡើងវិញរបស់ ODA ម្ចាស់ជំនួយដែលរួមមានសាធារណរដ្ឋប្រជាមានិតចិន បានសន្យាផ្តល់ជំនួយជាទឹកប្រាក់ ៦៩៨ លានដុល្លាសហរដ្ឋអាមេរិក នៅឆ្នាំ២០០៧។

19 ជាច្បាប់ចម្លងពីគម្រោងជំនួយសម្រាប់ឆ្នាំ២០០៧-២០០៩ របស់ADB នឹងមានភ្ជាប់នៅក្នុងតារាង នៅឧបសម្ព័ន្ធ ៥។ ដោយមានភាពមិនច្បាស់លាស់ដែលទាក់ទងនឹងគម្រោងវិស័យឯកជន ដែលផ្តល់មូលនិធិដោយ OCR (ដែលមិនឋិតនៅក្នុងគម្រោងជំនួយនេះ) គឺមិនត្រូវបានគេរៀបរាប់ឡើយ។ អ្វីដែលកំពុងមានដំណើរការនឹងត្រូវគោរពតាម DSA ឆ្នាំ២០០៧ សម្រាប់ប្រទេសកម្ពុជា។ ផែនការអាជីវកម្ម ដែលអនុវត្តនៅប្រទេសកម្ពុជាដែលបានពិនិត្យសាឡើងវិញសម្រាប់ ឆ្នាំ២០០៧-២០០៩ នឹងមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ៦។

20 ដោយយោងទៅលើការរៀបចំជំនួយឥតសំណងរវាង ADF និង IDA អប្បហារអាចកាត់បន្ថយការបែងចែកសរុបជារៀងរាល់ពីរឆ្នាំម្តង ក្នុងចំនួន៨៩,៧លានដុល្លា សហរដ្ឋអាមេរិក។

២៥. ចាប់តាំងពីឆ្នាំ២០០៥មក រដ្ឋាភិបាល រួមជាមួយនឹងដៃគូអភិវឌ្ឍន៍ បានធ្វើការពង្រឹងសមត្ថភាពរបស់ខ្លួន និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងជំនួយ។ នៅខែតុលា ឆ្នាំ២០០៦ មានការចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីការពង្រឹងប្រសិទ្ធភាពជំនួយ[21]។ រដ្ឋាភិបាលបានបង្កើតផែនការសកម្មភាពស្តីពីប្រពន្ធ័សុខដុមកម្ម ខ្សែរយៈទាក់ទង និងការសម្រេចលទ្ធផល ២០០៦-២០១០ ដែលការអនុវត្តផែនការសកម្មភាពបានពង្រឹងការងារសម្របសម្រួល និងភាពជាដៃគូរវាងម្ចាស់ជំនួយ និងរដ្ឋាភិបាល[22] ដូចមានសេចក្តីបញ្ជាក់លំអិតក្នុងរបាយការណ៍ប្រសិទ្ធភាពជំនួយនៅកម្ពុជាឆ្នាំ២០០៧[23] (AER) និងបានលើកមកធ្វើការពិភាក្សា នៅអង្គប្រជុំវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) នៅខែមិថុនា ឆ្នាំ២០០៧។

២៦. ADB បានធ្វើការប្រឹងប្រែងនៅក្នុងការអនុវតកិច្ចសន្យាភាពជាដៃគូ នៅក្នុងដំណាក់កាលត្រួតពិនិតឡើងវិញ។ ទីមួយ CSP ២០០៦-២០០៧ បានរៀបចំការសម្របសម្រួលយ៉ាងស្អិតរមួតជាមួយនឹងធនាគារពិភពលោក នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (DFID) នឹងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)។ បន្ទាប់ពីមានការប្រជុំជាប្រចាំរវាងដៃគូទាំងបួន និងកិច្ចប្រជុំប្រចាំឆ្នាំ ត្រូវធ្វើឡើងក្នុងគោលបំណងសហការអនុវត្តទៅតាមយុទ្ធសាស្ត្ររបស់ប្រទេសនីមួយៗ។ ការធ្វើរបៀបនេះ ត្រូវបានគាំទ្រដោយអង្គប្រជុំទ្វេភាគីពាក់ព័ន្ធនឹងប្រទេសកម្ពុជា និងការត្រួតពិនិត្យឡើងវិញ[24] រវាង ADB និងដៃគូអភិវឌ្ឍន៍។ ទីពីរ ADB និងដៃគូអភិវឌ្ឍដទៃកំពុងរៀបចំចុះហត្ថលេខាលើ "សេចក្តីថ្លែងការណ៍ស្តីពីគោលការណ៍តម្រង់ទិសសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍខាងក្រៅដោយធ្វើការសហការគ្នានៅក្នុងវិស័យកសិកម្ម និងធនធានទឹក"។ ទីបី ADB ជាអ្នកផ្តួចផ្តើមគំនិត ដើម្បីពង្រីកក្រុមម្ចាស់ជំនួយបួនពីដំបូង សម្រាប់ការប្រជុំប្រចាំឆ្នាំ នៅខែកញ្ញា ឆ្នាំ២០០៧ ដោយយកចិត្តទុកដាក់ទៅលើការងាររបស់ម្ចាស់ជំនួយដទៃទៀត (ដូចជារដ្ឋាភិបាលប្រទេសបារាំង អាឡឺម៉ង់ និងអូស្ត្រាលី)។ ជាចុងក្រោយទទួលស្គាល់ថាមានការកើនឡើងនៃម្ចាស់ជំនួយថ្មីៗទៀត (ដូចជា PRC) ស្ថិតនៅក្រៅដំណើរការ CDCF - ADB បានចាប់ផ្តើមការពិភាក្សាលើកិច្ចសហប្រតិបត្តិផ្នែកបច្ចេកទេសជាមួយនឹង PRC ក្រោមគម្រោង GMS នៅឆ្នាំ២០០៧។

២៧. ផែនការសហហិរញ្ញប្បទានឆ្លុះបញ្ចាំងពីការកើនឡើងនូវភាពជោគជ័យរបស់ ADB ក្នុងការកៀងគរធនធានបន្ថែមសម្រាប់កម្មវិធីរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ ការលើកឡើងសំខាន់ៗមានដូចជា (១) សហហិរញ្ញប្បទានរបស់ AusAID លើគម្រោងច្រកឆ្នេរសមុទ្រភាគខាងត្បូង GMS (២) សហហិរញ្ញប្បទានរបស់ ADB និង World Bank នៅឆ្នាំ២០០៧ សម្រាប់

---

21 សេចក្តីប្រកាសគឺជាសេចក្តីប្រកាស ដែលចេញដោយរដ្ឋាភិបាលកម្ពុជាជាផ្លូវការ (រដ្ឋាភិបាល) និងដៃគូអភិវឌ្ឍស្តីពីការពង្រឹងប្រសិទ្ធភាពជំនួយ។ សេចក្តីប្រកាសនេះយោងទៅលើសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស។

22 ទាំងនេះរួមមានកិច្ចប្រជុំគណកម្មាធិការសម្របសម្រួលកិច្ចអភិវឌ្ឍន៍របស់រដ្ឋាភិបាល (GDCC) នៅឆ្នាំ២០០៧ និងការសហការគ្នាយ៉ាងស្អិតរមួត តាមរយៈក្រុមការងារផ្នែកបច្ចេកទេសតាមវិស័យ។ នៅឆ្នាំ២០០៦-២០០៧ រដ្ឋាភិបាលបានត្រួតពិនិត្យទៅលើប្រសិទ្ធិភាពនៃជំនួយ ដែលមានជាប់ទាក់ទងទៅនឹង NSDP ។

23 Government of Cambodia-CDC 2007. *The Camodia Aid Effectiveness Report*. Phnom Penh (May). របាយការណ៍នេះ បានបង្ហាញថាការបែងចែកជំនួយទៅតាមផ្នែក និងដៃគូអភិវឌ្ឍ ប៉ះពាល់ដល់ភវនីយភាព ដែលថា MDGs នឹងសម្រេចបានជោគជ័យ និងធ្វើឱ្យថ្លៃប្រតិបត្តិការខ្ពស់ក្នុងការគ្រប់គ្រងជំនួយ កាន់តែកើនឡើង បង្កឱ្យមានការប្រកួតប្រជែងរវាងម្ចាស់ជំនួយការន់តែច្រើនឡើង ព្រមទាំងផ្លាស់ប្តូរការចាប់អារម្មណ៍ពីអាទិភាពនៃការអភិវឌ្ឍរបស់ប្រទេស។

24 ទាំងនេះរួមមាន (១) ការប្រជុំប្រចាំឆ្នាំរវាង ADB, World Bank, DFID និងប្រទេសជប៉ុន នៅទីក្រុងម៉ានីល នៅខែតុលា ឆ្នាំ២០០៦ (២) អង្គប្រជុំស្តីពីការគ្រប់គ្រងរវាង ADB និង World Bank នៅខែមិនា ឆ្នាំ២០០៧ (៣) និងការត្រួតពិនិត្យឡើងវិញរបស់ ADB និង DFID, MOU នៅខែមិថុនា ឆ្នាំ២០០៧ និង (៤) កិច្ចព្រមព្រៀងក្របខ័ណ្ឌអភិវឌ្ឍរបស់ ADB និង UNDP ឆ្នាំ២០០៧។

ម្រោងការគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់  និងសហហិរញ្ញប្បទានរបស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង  (AFD)  សម្រាប់កម្មវិធីធនធានទឹកនៅឆ្នាំ២០០៨។ ភាគជាដៃគូហិរញ្ញប្បទានដទៃទៀតកំពុងតែឋិតនៅក្រោមការពិចារណា។

## III. ការគ្រប់គ្រងផលប័ត្រ និងបញ្ហាតាមដានត្រួតពិនិត្យការអនុវត្ត

### ក. ការអនុវត្តចង្កោមវិនិយោគ

២៨. សូចនាករទាំង៥បានបង្ហាញថា ការអនុវត្តទូទៅលើផលប័ត្ររបស់ ADB នៅក្នុងប្រទេសកម្ពុជាគឺឋិតនៅក្រោមការរំពឹងទុកក្នុងអំឡុងឆ្នាំ២០០៥-២០០៧។ ទីមួយ គម្រោងមួយចំនួន មានហានិភ័យកើនឡើង[២៥] ។ ទីពីរ ទោះបីជាអត្រាចំណាយប្រចាំឆ្នាំ (ឥណទានមិនមានតាមកម្មវិធី) នៅតែឋិតនៅលើអត្រាវាយតម្លៃរបស់ ADB ជាបន្តបន្ទាប់ ហើយគម្លាតមានការខិតចូលគ្នាច្រើននៅប៉ុន្មានឆ្នាំនេះ[២៦] ។ ទីបី ការប្រគល់កិច្ចសន្យា និងសរុបនៃចំណាយនៅតែមានកម្រិតតិចជាងគម្រោងនៅ ឆ្នាំ២០០៣ ទោះបីជាមានកំណត់ទិសដៅជាក់ស្តែងក៏ដោយ[២៧] ។ ទីបួន ចន្លោះពេលជាមធ្យមពីការអនុម័តរហូតដល់ការចុះកិច្ចសន្យាយល់ព្រមលើផលប័ត្របច្ចុប្បន្នកាន់តែកើនឡើង ទោះបីជាចន្លោះពេលជាមធ្យមពីការចុះហត្ថលេខាយល់ព្រម រហូតដល់ការសម្រេចដាក់ជាធរមានត្រូវបានកែលំអ។ ទីប្រាំ ចំពោះការអនុវត្តការងារតាមវិស័យ ស្ថិតិស្តីពីសូចនាករហិរញ្ញវត្ថុ និងការតាមដាននូវការអនុវត្តប្រតិបត្តិការផលប័ត្រតាំងពីឆ្នាំ២០០២ បានបង្ហាញថា ស្ទើរតែគ្រប់វិស័យទាំងអស់ បានកត់ត្រាពីការពន្យារពេលក្នុងការបែងចែកចំណាយយ៉ាងច្រើន ក្នុងអំឡុងពេលការអនុវត្ត។ ការសង្ខេបពីស្ថានភាពអនុវត្តចង្កោមវិនិយោគ និងតារាងសង្ខេបការអនុវត្តមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ៧ ។ ដើម្បីដោះស្រាយការធ្លាក់ចុះជាទូទៅនៅក្នុងការអនុវត្តចង្កោមវិនិយោគ ការតាមដានរដ្ឋបាលគម្រោងដែលមានលក្ខណៈស៊ីជម្រៅនឹងធ្វើឡើងតាមរយៈ (១) ការត្រួតពិនិត្យឡើងវិញលើការអនុវត្តផលប័ត្ររួមមួយ (CPPR) (២) កំណែទម្រង់គោលនយោបាយតាមវិស័យ និង (៣) អនុសាសន៍លើការបែងចែកក្នុងចំណូលចំណាយ និងការចំណាយ ដែលមានលក្ខណៈសមស្រប។

២៩. ការសម្របសម្រួលលើការគ្រប់គ្រងផលប័ត្រ ត្រូវធ្វើឡើងតាមរយៈ CPPR។ នៅឆ្នាំ២០០៥ និង ២០០៦ មានបេសកម្មរួមមួយធ្វើឡើងដោយ World Bank និង CPPR។ បេសកម្មនេះ បានសន្និដ្ឋានថា ការអនុវត្តការងាររបស់ផលប័ត្រ (Portfolio) ទាំងពីរមិនទទួលលទ្ធផលជាទីពេញចិត្តឡើយ។ ក្នុងអំឡុងពេលបេសកកម្មរួមគ្នាយកចិត្តទុកដាក់ទៅលើកង្វះខាត

---

[25] នៅថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៧ ការចាត់ថ្នាក់ទូទៅលើឥណទានមិនទាន់សងនៅក្នុងចង្កោមវិនិយោគនៅប្រទេសកម្ពុជា ជាទូទៅត្រូវបានបង្ហាញ ថាមានការពេញចិត្តនឹងចំណាត់ថ្នាក់នេះ ដែលត្រូវជា៩២%នៃចង្កោមឥណទាន/ជំនួយឥតសំណងសកម្ម (២៣ក្នុងចំណោមឥណទាន និងជំនួយឥតសំណងសកម្មសរុបទាំង២៥) ត្រូវបានចាត់ថ្នាក់ថាមានការពេញចិត្ត និង៨% (២ក្នុងចំណោមឥណទាន និងជំនួយឥតសំណងសកម្មសរុបទាំង២៥) ត្រូវចាត់ថ្នាក់ថាមានការពេញចិត្តខ្លះ បើគិតលើការសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍ និងវិវត្តន៍នៅក្នុងការអនុវត្ត។ ដោយធ្វើការប្រៀបធៀបនៅចុងឆ្នាំ២០០៥ និង២០០៦ ពីរឆ្នាំដំបូងនៃការអនុវត្តឥណទាន CSP ១០០% (២០០៥) និង៩៥.២% (២០០៦) នៃក្នុងចង្កោមឥណទានត្រូវបានចាត់ថ្នាក់ថាមានការពេញចិត្ត។ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៧ ឥណទានពីរដែលមានការពេញចិត្តខ្លះក៏មានន័យថា ៨%នៃចង្កោមវិនិយោគត្រូវបានគេគិតថាមានហានិភ័យ ដែលឋិតនៅក្រោម១០%នៃការចាត់ថ្នាក់ជាមធ្យមរបស់ ADB។ ចង្កោមវិនិយោគនៅតែមិនមានហានិភ័យនៅក្នុងឆ្នាំ២០០៥ ប៉ុន្តែឥណទានបីខុសៗគ្នាឋិតនៅក្នុងហានិភ័យនៅឆ្នាំ២០០៦។

[26] អត្រាចំណាយសម្រាប់ឥណទានមិនមានកម្មវិធី (ឥណទានតាមកម្មវិធី) ប្រចាំនៅកម្ពុជា បានធ្លាក់ចុះជាលំដាប់ពី២២,៨% (២៣,១) នៅ២០០៣ រហូតដល់ ២១,៣% (២៥,១%) នៅ២០០៤ ២០,០% (២២,៧%) នៅ២០០៥ និង ១៧,៦% (២០,៣%) នៅ២០០៦។ អត្រាចំណាយ ទៅលើឥណទានមិនមានកម្មវិធី (ឥណទានមានកម្មវិធី) មាន១៤,៨% (១៧,៣%) នៅ២០០៣ ១២,៩% (១៥%) នៅឆ្នាំ២០០៤ ១៣,៧% (១៦,៦%) នៅ២០០៥ និង១៦,៣% (១៩,០%) នៅ២០០៦។

[27] ដូច្នេះនៅក្នុងឆ្នាំ២០០៥ រង្វាន់តាមកិច្ចសន្យាពិតប្រាកដមានទឹកប្រាក់ចំនួន៩៦,៤លានដុល្លាសហរដ្ឋអាមេរិក (៣៧,៤%នៃគម្រោងប្រចាំឆ្នាំ) និងនៅ២០០៦ មានចំនួន៣៩,១លានដុល្លាសហរដ្ឋអាមេរិក (៦០,៤%នៃគម្រោងប្រចាំឆ្នាំ)។ ការចំណាយពិតប្រាកដមានចំនួនរហូតដល់៨៤,៥លានដុល្លាអាមេរិក (៨៨,២% នៃគម្រោងប្រចាំឆ្នាំ) នៅ២០០៥ និង៥៤,៥លានដុល្លាសហរដ្ឋអាមេរិក (៨២,៩%នៃគម្រោងប្រចាំឆ្នាំ) នៅ២០០៦។

នៃការតាំងចិត្ត ឬការអនុម័តផែនការផែទាំរយៈពេលវែង ប្រកបដោយនិរន្តរភាពលើគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (ជាពិសេសផ្លូវថ្នល់) និងការបន្តផ្តល់បុគ្គលិកដល់គម្រោង។

៣០. ដំណោះស្រាយហេតុការណ៍មូលនិធិផ្ទួនៗ សម្រាប់ការថែទាំ គឺជាបញ្ហាដ៏ធំមួយដែលនៅពីក្រោយជំហ៊ាននៃការអនុវត្តយឺតៗនៅក្នុងគម្រោង ADB ប៉ារ៉ាម៉ែត្រហិរញ្ញប្បទានថ្មី ត្រូវបានយល់ព្រមដោយរដ្ឋាភិបាល និងត្រូវបានដាក់ស្នើជូនទៅដល់ប្រធាន ដើម្បីសុំការឯកភាព[២៨]។ សេចក្តីស្នើប៉ារ៉ាម៉ែត្រហិរញ្ញប្បទាន នឹងមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធបន្ថែម ង។

**ខ. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការងារអនុវត្ត**

៣១. ការរីកចម្រើននៅក្នុងលទ្ធផលតាមវិស័យ នៅក្រោមគម្រោងផែនការតាមវិស័យ ត្រូវបានត្រួតពិនិត្យតាមដានដោយធៀបនឹងសូចនាករនានា នៅក្នុងគម្រោងការនៃលទ្ធផលដែលបានពិនិត្យរួច (ឧបសម្ព័ន្ធ ៨)។ ការកែតម្រូវ ត្រូវបានធ្វើឡើងដើម្បីឆ្លុះបញ្ចាំងការយកចិត្តទុកដាក់ទៅអនាគតកាល សម្រាប់ការអនុវត្ត CSP ពីឆ្នាំ២០០៧ ទៅឆ្នាំ២០០៩។ វិធានការដែលតម្រូវឱ្យមានការថ្លឹងថ្លែងអំពីអភិបាលកិច្ចល្អ និងហានិភ័យនៃការខូចខាត ត្រូវបានគូសបញ្ជាក់ឡើងវិញ។

## IV. យុទ្ធសាស្ត្រប្រចាំប្រទេស និងគម្រោងការលទ្ធផលរបស់កម្មវិធី

៣២. នៅពេលរៀបចំ CSP ប្រចាំប្រទេសកម្ពុជា នៅឆ្នាំ២០០៥-២០០៩ ADB បានសាកល្បង CSP នានា ផ្អែកលើលទ្ធផលនៅក្នុងប្រទេសតូចៗមួយចំនួន។ ទោះបីកម្ពុជាមិនមែននៅក្នុងចំណោមប្រទេសសាកល្បងទាំងនោះក្តី ក៏វាមានបញ្ចូលលក្ខណៈនៃ CSP ផ្អែកលើលទ្ធផលបានយ៉ាងច្រើនដែរ។ ប៉ុន្តែ គម្រោងការលទ្ធផលដែលមាននៅក្នុង CSP មិនបានបង្កើតឱ្យទៅជាឧបករណ៍គ្រប់គ្រងពេញលេញទេ ចំពោះការអនុវត្ត CSP។ ហេតុនេះ គម្រោងការលទ្ធផល ដែលបានពិនិត្យហើយ ត្រូវបានរៀបចំ នៅអំឡុងពេលរៀបចំផែនការអាជីវកម្មប្រតិបត្តិការប្រចាំប្រទេស ឆ្នាំ២០០៧-២០០៩ ដែលបានព្រមព្រៀងនៅខែធ្នូ ឆ្នាំ២០០៦[២៩]។ គម្រោងការលទ្ធផលឆ្នាំ២០០៦-២០១០ ដែលបានពិនិត្យកែលំអ គម្រោងការ CSP រួចហើយ បានផ្តល់បញ្ចូលលទ្ធផលកាន់តែច្រើនប្រកបដោយលក្ខណៈ SMART គឺលក្ខណៈជម្រើស និងលំអិត អាចវាស់បាន អាចសម្រេចបានប្រាកដ និងទាន់ពេល។ អត្ថបទថ្មីមានផ្តល់នៅឧបសម្ព័ន្ធ ៨។

---

[28] ការកើនឡើងនៅក្នុងការងារដែលសម្រេចបានរបស់ ADB នឹងជំរុញឱ្យមានសាមគ្គីបភាពបន្ថែមទៀតជាមួយនឹង World Bank ដែលមិនដាក់កំហិតលើចង្កោមវិនិយោគទូទៅ និងផ្តល់សិទ្ធិរហូតដល់១០០% សម្រាប់គម្រោងនីមួយៗ។ ការងារដែលសម្រេចបានកាន់តែច្រើនជាងមុននឹងធ្វើឱ្យពន្ធដារ និងពន្ធគយនៅក្នុងប្រទេសមានលក្ខណៈសមស្របសម្រាប់ហិរញ្ញប្បទានរបស់ ADB ដោយសារគេគិតថាត្រឹមត្រូវ និងមិនមានការដាក់កំហិតនឹងដាក់ទៅលើការចំណាយផ្ទួនៗឡើយ ទោះបីជាមានការធានាឱ្យមានហិរញ្ញប្បទានផ្ទួនមាននិរន្តរភាព ដែលលើសពីគម្រោងរបស់ ADB។

[29] ADB. 2006. Country Operations Business Plan (2007-2008): Cambodia.Manila

ឧបសម្ព័ន្ធ១

## ១.ការវិភាគប្រចាំប្រទេស

### តារាង ក១.១ : សូចនាករសេដ្ឋកិច្ចប្រទេស

| រាយមុខ | ឆ្នាំសារពើពន្ធ - ការប៉ាន់ស្មានឡើងវិញ | | | | |
|---|---|---|---|---|---|
| | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦p |
| **ក. ចំណូល និង កំណើន** | | | | | |
| ១. GDP ក្នុងម្នាក់ៗ (គិតជាដុល្លា តាមតម្លៃបច្ចុប្បន្ន) | ៣២៦ | ៣៤៩ | ៣៩២ | ៤៥៤ | ៥១៣ |
| ២. កំណើន GDP (% ក្នុងតម្លៃថេរ ២០០០) | ៦,៥ | ៨,៥ | ១០,០ | ១៣,៥ | ១០,៨ |
| ក. វិស័យកសិកម្ម | -២,៥ | ១០,៥ | -០,៩ | ១៥,៧ | ៥,៥ |
| ខ. វិស័យឧស្សាហកម្ម | ១៧,១ | ១២,០ | ១៦,៦ | ១២,៧ | ១៨,៣ |
| គ. វិស័យសេវាកម្ម | ៧,៦ | ៥,៩ | ១៣,៣ | ១២,៧ | ១០,៣ |
| **ខ. ប្រាក់សន្សំ និងវិនិយោគ (តម្លៃបច្ចុប្បន្ន និងតម្លៃទីផ្សារ គិតជា % នៃ GDP )** | | | | | |
| ១. វិនិយោគក្នុងស្រុកសរុប | ១៩,៧ | ២១,៥ | ១៧,៤ | ២០,២ | ២១,៦ |
| ២. ប្រាក់សន្សំរបស់ជាតិសរុប | ១០,៦ | ១០,៨ | ១១,១ | ១០,៩ | ១៤,៤ |
| **គ. រូបិយវត្ថុ និងអតិផរណា (អត្រាកំណើនប្រចាំឆ្នាំគិតជាភាគរយ (%)** | | | | | |
| ១. សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ | ៣,៣ | ១,២ | ៣,៩ | ៥,៨ | ៤,៧ |
| ២. ការជម្រះបញ្ជីសរុប (M2) | ៣១,១ | ១៥,២ | ៣០ | ១៦,១ | ៣៨,២ |
| **ឃ. ហិរញ្ញវត្ថុរដ្ឋាភិបាល (% នៃ GDP )** | | | | | |
| ១. ចំណូល និងជំនួយឥតសំណង | ១០,៥ | ៩,៦ | ១០,៣ | ១០,៣ | ១១,៥ |
| ២. ចំណាយ និងកម្ចីបន្ត | ១៦,៨ | ១៥,៥ | ១៥,០ | ១៣,៧ | ១៣,០ |
| ៣. អតិរេកសារពើពន្ធរួម (ឬឱនភាព) | -៦,៣ | -៥,៩ | -៤,៧ | -៣,៤ | -១,៥ |
| **ង. ជញ្ជីងទូទាត់** | | | | | |
| ១. តុល្យភាពគណនីទំនិញ (% នៃ GDP ) | -១៣,៨ | -១២,៥ | -១២,៨ | -១៦,២ | -១៤,២ |
| ២. តុល្យភាពគណនីបច្ចុប្បន្ន (% នៃ GDP ) | -៩,៥ | -១០,៦ | -៨,២ | -៩,៤ | -៧,២ |
| ៣. កំណើនការនាំទំនិញចេញ (ដុល្លា) (កំណើន %ប្រចាំឆ្នាំ) | ១២,៧ | ១៧,៩ | ២៤,១ | ១២,៤ | ២៦,៩ |
| ៤. កំណើនការនាំទំនិញចូល (ដុល្លា) (កំណើន %ប្រចាំឆ្នាំ) | ១២,៨ | ១៣,០ | ២២,៥ | ២០,២ | ២០,៣ |
| **ច. សូចនាករទូទាត់ក្រៅប្រទេស** | | | | | |
| ១. ទុនបម្រុងផ្លូវការសរុប (រួមទាំងមាស គិតជាដុល្លា) | ៦៦៣ | ៧៣៧ | ៨០៦ | ៩១៥ | ១.០៩៧ |
| គិតជាចំនួន សប្តាហ៍នៃការនាំទំនិញចូលក្នុងឆ្នាំបច្ចុប្បន្ន | ១៤,៦ | ១៤,៤ | ១២,៨ | ១២,១ | ១២,១ |
| ២. សេវាសងបំណុលក្រៅប្រទេស (% នៃការនាំចេញ និងសេវាកម្ម) | ០,៩ | ១,០ | ០,៨ | ០,៧ | ០,៦ |
| ៣. បំណុលក្រៅប្រទេសសរុប (% នៃ GDP ) | ៦២,៧ | ៦២,៦ | ៥៦,០ | ៥០,៦ | ៤៥,៤ |
| **ឆ. រាយមុខសង្ខេប :** | | | | | |
| ១. GDP (តម្លៃបច្ចុប្បន្ន គិតជាពាន់លានរៀល)[ក] | ១៦.៧៥៦ | ១៨.៥០៨ | ២១.៣៤៣ | ២៥.៦៩៣ | ២៩.៨០៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ២. | អត្រាប្តូរប្រាក់ ( រៀល/ដុល្លា គិតជាមធ្យម) | ៣.៩២១ | ៣.៩៧៥ | ៤.០១៦ | ៤.០៩២ | ៤.១០៣ |
| ៣. | ចំនួនប្រជាជន ( លាននាក់) | ១៣.១០៤ | ១៣.៣២៦ | ១៣.៥៥០ | ១៣.៧២៨ | ១៤.១៦៣ |

GDP ផលិតផលក្នុងស្រុកសរុប

p/ ការប៉ាន់ស្មានដំបូង

[ក] វិទ្យាស្ថានជាតិស្ថិតិ។ ការប៉ាន់ស្មាន នៅខែកក្កដា ឆ្នាំ២០០៧

ប្រភព : ការប៉ាន់ស្មានរបស់អាជ្ញាធរ និងបុគ្គលិករដ្ឋាភិបាល

ឧបសម្ព័ន្ធ១

## តារាង ក ១.២ : សូចនាករភាពក្រីក្ររបស់ប្រទេស និងសង្គម

| រាយមុខ | រយៈពេល | | |
|---|---|---|---|
| | ១៩៩០ | ២០០០ | ឆ្នាំចុងក្រោយបំផុត |
| **ក. សូចនាករប្រជាជន** | | | |
| ១. ចំនួនប្រជាជនសរុប (លាននាក់) [ក] | ៨,៦ | ១២,៧ | ១៤,២ |
| ២. អត្រាកំណើនប្រជាជនប្រចាំឆ្នាំ (%ប្រែប្រួល) | ៣,៦ | ១,៦២ | ២,៤២ |
| **ខ. សូចនាករសង្គម** | | | |
| ១. អត្រាលទ្ធភាពបង្កកំណើតសរុប (កំណើត/ស្ត្រី) [ខ] | ៥,៦ | ៤ (១៩៩៨) | ៣,៤ (២០០៥) |
| ២. ផលធៀបមរណភាពមាតា (ក្នុងកំណើតរស់ ១០០.០០០) [ខ] | ៩០០ | ៤៣៧ | ៤៧២ |
| ៣. អត្រាមរណភាពកុមារ (ក្រោមអាយុ ១ឆ្នាំ/កំណើតរស់ ១.០០០) [ខ] | ៨០ | ៩៦ (២០០២) | ៦៦ (២០០៥) |
| ៤. អាយុកាលមធ្យមគិតពីកំណើត (ឆ្នាំ) [គ] | ៥០,៣ | ៥៤ (២០០២) | - |
| ក. ស្ត្រី | ៥២ | ៦២ (២០០២) | ៦៥ (២០០៤) |
| ខ. បុរស | ៤៨,៩ | ៥៥,៨ (២០០២) | ៦០ (២០០៤) |
| ៥. អក្ខរកម្មមនុស្សពេញវ័យ (%) | ៦២ | | ៧៣,៦ (២០០៤) |
| ក. ស្ត្រី | ៤៨,៨ | | ៦៤,១ (២០០៤) |
| ខ. បុរស | ៧៧,៧ | | ៨៤,៧ (២០០៤) |
| ៦. អត្រាសរុបនៃការចុះឈ្មោះសិក្សានៅបឋមសិក្សា (%) [ឃ] | ១២១ | ១២៣ | ១២៤ (២០០៥) |
| ៧. អត្រាសរុបនៃការចុះឈ្មោះសិក្សានៅមធ្យមសិក្សា (%) | ៣២ | ២១ (២០០១) | ៣៧,៣ (២០០៥) |
| ៨. កង្វះអាហារូបត្ថម្ភកុមារ (% ក្រោមអាយុ ៥ ឆ្នាំ) | ៥២ | ៤៥ | ៣៧ |
| ៩. ចំនួនប្រជាជននៅក្រោមបន្ទាត់ភាពក្រីក្រ (%) | ៣៩ (១៩៩៤) | ៣៥,៩ (១៩៩៩) | ៣៤,៧ (២០០៤) |
| ១០. ចំនួនប្រជាជនដែលមានទឹកស្អាតប្រើ (%) | ១៣,២ (១៩៩៤) | ៣០ | - |
| ក. ប្រជាជននៅតាមតំបន់ជនបទ | | ២៤ (១៩៩៨) | ៤១,៦ |
| ខ. ប្រជាជននៅតាមទីប្រជុំជន | | ៦០ (១៩៩៨) | ៧៥,៨ |
| ១១. ចំនួនប្រជាជនដែលមានអនាម័យ (%) | ២០ (១៩៩៤) | ២១ | - |
| ក. ប្រជាជននៅតាមតំបន់ជនបទ | | ៨,៦ | ១៦,៤ |
| ខ. ប្រជាជននៅតាមទីប្រជុំជន | | ៤៩ | ៥៥ |
| ១២. ចំណាយលើវិស័យអប់រំ [ង] (% នៃ GDP ) | | ១,៦៨ (២០០៥) | ១,៥៤ (២០០៦) |
| ១៣. លំដាប់សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | | ១៣០ (២០០១) | ១២៩ (២០០៤) |
| ១៤. លំដាប់សន្ទស្សន៍អភិវឌ្ឍន៍ទាក់ព័ន្ធនឹងយេនឌ័រ [ច] | | ១០៥ (២០០១) | ៩៧ (២០០៤) |
| **គ. សូចនាករភាពក្រីក្រ** [ឆ] | | | |
| ១. អាំងស៊ីដង់ភាពក្រីក្រ | ៣៩ (១៩៩៤) | ៣៥,៩ (១៩៩៩) | ៣៤,៧ (២០០៤) |
| ២. ភាគរយនៃប្រជាជនក្រីក្រលើចំនួនប្រជាជនសរុប | | | |

| | | | | |
|---|---|---|---|---|
| | ក. ភ្នំពេញ | ១១,៤ (១៩៩៤) | ៩,៧ (១៩៩៩) | ៤,៦ (២00៤) |
| | ខ. ទីប្រជុំជនដទៃទៀត | ៣៦,៦ (១៩៩៤) | ២៥,២ (១៩៩៩) | ២៤,៧ (២00៤) |
| | គ. ជនបទ | ៤៣,១ (១៩៩៤) | ៤0,១ (១៩៩៩) | ៣៩,២ (២00៤) |
| ៣. | គម្លាតភាពក្រីក្រ | ៩,២ (១៩៩៤) | ៦,៥ (១៩៩៩) | ៩,២ (២00៤) |
| ៤. | សន្ទស្សន៍នៃទម្ងន់នៃភាពក្រីក្រ | ៣,១ (១៩៩៤) | ២,0 (១៩៩៩) | ៣,៤ (២00៤) |
| ៥. | សន្ទស្សន៍ Gini | 0,៣៧ (១៩៩៤) | 0,៤៥ (១៩៩៩) | 0,៤២ (២00៤) |
| ៦. | សន្ទស្សន៍ភាពក្រីក្រមនុស្ស | | ៤២,៨ (២00១) | ២៩,៣ |
| | លំដាប់នៃភាពក្រីក្រមនុស្ស | | ៧៣ | ៧៣ |

(–) គ្មានសូចនាករ

ក. វិទ្យាស្ថានជាតិស្ថិតិ ។ ការរាប់ចំនួនប្រជាជន និងការធ្វើគម្រោងចំនួនប្រជាជន ផ្អែកលើការប៉ាន់ស្មានឆ្នាំ២00៦

ខ. ការស្ទាបស្ទង់មតិលើប្រជាសាស្ត្រ និងសុខភាព នៅប្រទេសកម្ពុជា ឆ្នាំ២00៥

គ. ការស្ទាប់ស្ទង់មតិលើសេដ្ឋកិច្ច-សង្គម នៅប្រទេសកម្ពុជា ឆ្នាំ២00៤ របស់ក្រសួងផែនការ នៅខែកញ្ញា ឆ្នាំ២00៥

ឃ. ស្ថិតិ និងសូចនាករអប់រំ ឆ្នាំ២00៥/0៦ របស់ក្រសួងអប់រំ យុវជន និងកីឡា

ង. ច្បាប់ជាតិស្តីពីថវិកា សម្រាប់ FY ឆ្នាំ២00៥ របស់ក្រសួងអប់រំ និងហិរញ្ញវត្ថុ

ច. UNDP, 2006 Human Development Report, New York 2006

ឆ. ឯកសារស្តីពីភាពក្រីក្រ នៅប្រទេសកម្ពុជា របស់ក្រសួងផែនការ ខែកុម្ភៈ ឆ្នាំ២00៦

ឧបសម្ព័ន្ធ១

## តារាង ក.១.៣ : ការរីកចម្រើនឆ្ពោះទៅរកគោលដៅ និងទិសដៅអភិវឌ្ឍសហស្សវត្សរ៍

(តម្លៃសូចនាករនៃទិសដៅផ្សំ ដែលជាសូចនាករ ឬឆ្នាំដំបូងបំផុត)

| គោលដៅ និងទិសដៅ | ឆ | ឆ្នាំ | ២០០៥ | | ២០១០ | ២០១៥ | ស្ថានភាព |
|---|---|---|---|---|---|---|---|
| | | | ទិសដៅ | ការប៉ាន់ស្មាន | | | |
| **គោលដៅទី១ : លុបបំបាត់ភាពក្រីក្រ និងអត់ឃ្លានខ្លាំង** | | | | | | | |
| **ទិសដៅទី១ : កាត់បន្ថយភាគរយនៃប្រជាជនដែលមានប្រាក់ចំណូលតិចជាង១ដុល្លា ក្នុងមួយថ្ងៃ ក្នុងរវាងឆ្នាំ១៩៩០ និង២០១៥** | | | | | | | |
| ប្រជាជនដែលសន្មតថាស្ថិតនៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ (%) | (៣៩)[ក] | ១៩៩៣ | ៣១ | ៣៤,៧[១] (២៨,០)[ក] | ២៥ | ១៩,៥ | គ |
| ផលធៀប១ភាគ៥នៃប្រជាជនដែលក្រីក្រជាងគេ នៅក្នុងការប៉ាន់ស្មានថ្នាក់ជាតិ (%) (ប្រៀបធៀបទៅ នឹងការប៉ាន់ស្មានឆ្នាំ២០០៤) | ៧,៤ (៨,៥)[ក] | ១៩៩៣ | ៩ | (៧)[ក] | ១០ | ១១ | ង |
| **ទិសដៅទី២ : កាត់បន្ថយភាគរយនៃប្រជាជនដែលទទួលរងគ្រោះដោយសារភាពអត់ឃ្លាន ក្នុងរវាងឆ្នាំ១៩៩០ និងឆ្នាំ២០១៥** | | | | | | | |
| ប្រេវ៉ាឡង់នៃក្មេងអាយុក្រោម៥ឆ្នាំ ដែលមិនគ្រប់ទម្ងន់ (%) | ៤៥,២ | ២០០០ | ៣៦ | ៣៦[៣] | ២៩ | ២២ | ខ |
| ភាគរយនៃចំនួនប្រជាជនក្រោមខ្សែបន្ទាប់នៃភាពក្រីក្រអត់អាហារ (%) | (២០) | ១៩៩៣ | ១៦ | ១៩,៧ (១៤,២)[២] | ១៣ | ១០ | គ |
| **គោលដៅទី២ : ការសម្រេចបាននូវការអប់រំថ្នាក់បឋមសិក្សាជាសកល** | | | | | | | |
| **ទិសដៅ៣ : ធានាថា ក្មេងៗនៅគ្រប់ទីកន្លែងទាំងអស់ ទាំងក្មេងប្រុស ទាំងក្មេងស្រី នឹងអាចមានលទ្ធភាពបញ្ចប់ថ្នាក់ទាំងស្រុងបាន ឬអាចទទួលបានការអប់រំ នៅកម្រិតបឋមសិក្សាបានគ្រប់ៗគ្នា ត្រឹមឆ្នាំ២០១៥** | | | | | | | |
| ផលធៀបនៃការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា | ៨៧ | ២០០១ | ៩៥ | ៩១,៣[៤] | ១០០ | ១០០ | គ |
| ភាគរយនៃក្មេងដែលបានសិក្សាដល់ថ្នាក់ទី៥ (%) | ៥៨ | ២០០១ | ៧៧ | ៥៩,២ | ១០០ | ១០០ | ឃ |
| អត្រាចេះអាន និងចេះសរសេរ ក្នុងចំណោមមនុស្សដែលវ័យ១៥-២៤ឆ្នាំ (%) | ៨២ | ១៩៩៩ | ៩០ | ៨៣,៤ | ៩៥ | ១០០ | ឃ |
| **គោលដៅទី៣ : លើកកម្ពស់សមភាពយេនឌ័រ និងផ្ដល់សិទ្ធិអំណាចដល់ស្ត្រី** | | | | | | | |
| **ទិសដៅទី៤ : លុបបំបាត់ចោលភាពខុសគ្នារវាងយេនឌ័រ នៅក្នុងការអប់រំកម្រិតបឋម និងមធ្យមសិក្សា ត្រឹមឆ្នាំ២០០៥ បើអាចធ្វើទៅបាន និងនៅក្នុង អប់រំគ្រប់កម្រិតទាំងអស់ មិនឱ្យហួសពីឆ្នាំ២០១៥** | | | | | | | |
| ផលធៀបរវាងក្មេងស្រី និងក្មេងប្រុស (%) | | | | | | | |
| ក. នៅកម្រិតបឋមសិក្សា | ៨៧ | ២០០១ | ៩៨ | ៨៩,៥ | ១០០ | ១០០ | គ |
| ខ. នៅកម្រិតមធ្យមសិក្សាបឋមភូមិ | ៦៣ | ២០០១ | ៩៦ | ៧៧,០ | ១០០ | ១០០ | គ |
| គ. នៅកម្រិតធម្យមសិក្សាទុតិយភូមិ | ៣៨ | ២០០១ | ៥០ | ៤៥,៦ | ៧០ | ៨៥ | គ |
| ផលធៀបរវាងមនុស្សស្រី និងមនុស្សប្រុស ដែលចេះអាន និងសរសេរ ដែលមានអាយុ១៥-២៤ឆ្នាំ (%) | ៨៧ | ១៩៩៨ | ៩៥ | ៩០,០ | ១០០ | ១០០ | គ |
| ការចូលរួមរវាងស្ត្រី ទៅនឹងការងារ នៅក្នុងឧស្សាហកម្ម | ៤៣,៧ | ១៩៩៨ | ៥០ | ៥៣,៥ | ៥០ | ៥០ | គ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ការទទួលបានកៅអីរបស់ស្ត្រី នៅក្នុងរដ្ឋសភា (%) | ១២ | ២០០៣ | ១៧ | ១៧,១ | ២៤ | ២០ | ខ |
| **គោលដៅទី៤ : កាត់បន្ថយអត្រាមរណៈរបស់កុមារ** | | | | | | | |
| **ទិសដៅទី៥ : កាត់បន្ថយអត្រាមរណៈក្រោម៥ ឱ្យបាន២ភាគ៣ រវាងឆ្នាំ១៩៩០ និងឆ្នាំ២០១៥** | | | | | | | |
| អត្រាមរណៈក្រោម៥ ក្នុងចំណោមការផ្តល់កំណើតនៅរស់ ចំនួន១.០០០នាក់ | ១២៤ | ១៩៩៨ | ១០៥ | ៨២ | ៨៥ | ៦៥ | ក |
| អត្រាមរណៈរបស់ក្មេង ក្នុងចំណោមការផ្តល់កំណើតនៅរស់ ចំនួន១.០០០នាក់ | ៩៥ | ១៩៩៨ | ៧៥ | ៦៦ | ៦០ | ៥០ | ក |
| ក្មេងក្រោមអាយុ១ឆ្នាំ ដែលសាំទៅនឹងជំងឺកញ្រ្ជិល (%) | ៤១,៤ | ២០០០ | ៨០ | ៨០ | ៨៥ | ៩០ | ខ |
| **គោលដៅទី៥ : ធ្វើឱ្យសុខភាពមាតា កាន់តែប្រសើរឡើង** | | | | | | | |
| **ទិសដៅទី៦ : កាត់បន្ថយអត្រាមរណៈមាតាឱ្យបាន២ភាគ៣ រវាងឆ្នាំ១៩៩០ និងឆ្នាំ២០១៥** | | | | | | | |
| ផលធៀបអត្រាមរណៈរបស់មាតា ក្នុងចំណោមការផ្តល់ កំណើតនៅរស់ចំនួន១០០.០០០នាក់ | ៤៣៧ | ១៩៩៧ | ៣៤៣ | ៤៧៣[៣] | ២៤៣ | ១៤០ | ង |
| **គោលដៅទី៦ : ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗទៀត** | | | | | | | |
| **ទិសដៅ៧ : បញ្ឈប់ការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ព្រមទាំងចាប់ផ្តើមធ្វើឱ្យប្រសើរឡើងវិញ ឱ្យបានត្រឹមឆ្នាំ២០១៥** | | | | | | | |
| ប្រេវ៉ាឡង់នៃមេរោគអេដស៍ ក្នុងចំណោមស្ត្រី អាយុ ១៥-២៤ ឆ្នាំ ដែលបានទទួលការថែរក្សាមុនពេលឆ្លងទន្លេ (%) | ២,៥ | ១៩៩៨ | ២,៤ | ២,១ | ២,០ | ១,៥ | ក |
| អត្រាប្រើប្រាស់ស្រោមអនាម័យ ក្នុងចំណោមអ្នករកស៊ីផ្លូវភេទ ក្នុងអំឡុងពេលរួមភេទចុងក្រោយ (%) | ៩១ | ២០០២ | ៩៨ | ៩៦,៧ | ៩៨ | ៩៨ | គ |
| **ទិសដៅទី៨ : បញ្ឈប់ការកើតឡើងនៃជំងឺគ្រុនចាញ់ និងជំងឺចម្បងផ្សេងៗទៀត ព្រមទាំងចាប់ផ្តើមធ្វើឱ្យប្រសើរឡើងវិញ ឱ្យបានត្រឹមឆ្នាំ២០១៥** | | | | | | | |
| ប្រេវ៉ាឡង់ និងការស្លាប់ ដោយសារជំងឺគ្រុនចាញ់ | | | | | | | |
| ក. អត្រាមរណៈដោយសារជំងឺគ្រុនចាញ់ (ក្នុងចំណោម មនុស្ស១០០.០០០នាក់) | ០,៤ | ២០០០ | ០,៣ | ០,៣៦ | ០,២៥ | ០,១ | គ |
| ខ. ចំនួនប្រជាជន ដែលដេកក្នុងមុងជ្រលក់ថ្នាំសម្លាប់សត្វល្អិត ក្នុងពេលយប់ កំពុងប្រឈមនឹងគ្រោះថ្នាក់ (%) | ២,៤ | ២០០០ | ៨០ | ៤៩ | ៩៥ | ៩៨ | គ |
| ប្រេវ៉ាឡង់ និងការស្លាប់ដោយសារជំងឺរបេង | | | | | | | |
| ក. អត្រាប្រេវ៉ាឡង់នៃជំងឺរបេង ក្នុងចំណោមមនុស្ស ១០០.០០០នាក់ | ៤២៨ | ១៩៩៧ | ៣២១ | - | ២១៤ | ១៣៥ | - |
| ខ. អត្រាមរណៈដោយសារជំងឺរបេង ក្នុងចំណោមមនុស្ស ១០០.០០០នាក់ | ៩០ | ១៩៩៧ | ៦៨ | - | ៤៥ | ៣២ | - |
| ភាគរយនៃករណីជំងឺរបេង ដែលត្រូវបានរកឃើញ និងព្យាបាលឱ្យជាសះស្បើយ ក្រោមការព្យាបាលដោយការតាមដានផ្ទាល់ (រយៈពេលខ្លី) | | | | | | | |
| ក. អត្រារកឃើញ (%) | ៥៧,០ | ២០០២ | ៧០ | ៦១ | >៧០ | >៧០ | គ |
| ខ. អត្រាជោគជ័យក្នុងការព្យាបាល (%) | ៨៩,០ | ២០០២ | >៨៥ | - | ៨៥ | ៨៥ | |
| **គោលដៅទី៧ : ធានានូវការទ្រទ្រង់បរិស្ថាន** | | | | | | | |
| **ទិសដៅទី៩ : ធ្វើសមាហរណកម្មគោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តភាព ទៅជាគោលនយោបាយ និងកម្មវិធីប្រចាំប្រទេស និងទទួលបាន** | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| មកវិញនូវធនធានបរិស្ថានដែលបាត់បង់ | | | | | | | |
| ភាគរយនៃដីដែលគ្របដណ្តប់ដោយព្រៃឈើ (%) | ៦០,០ | ២០០២[៥] | ៦០ | ៥៨ | ៦០ | ៦០ | អ |
| ភាគរយនៃចំនួនប្រជាជនដែលប្រើប្រាស់ឥន្ធនៈរឹង (%) | ៩២ | ១៩៩៣ | ៧០ | ៨៣,៩ | ៦១ | ៥២ | គ |
| **ទិសដៅទី១០ : កាត់បន្ថយភាគរយនៃប្រជាជនដែលមិនទទួលបានទឹកស្អាតបរិភោគ ត្រឹមឆ្នាំ២០១៥** | | | | | | | |
| ភាគរយនៃចំនួនប្រជាជនដែលទទួលបានទឹកស្អាតសម្រាប់បរិភោគ | | | | | | | |
| ក. ទីក្រុង | ៦០,០ | ១៩៩៨ | ៦៨ | ៧៥,៨ | ៧៤ | ៨០ | ក |
| ខ. ជនបទ | ២៤,០ | ១៩៩៨ | ៣០ | ៤១,៦ | ៤០ | ៥០ | ក |
| ភាគរយនៃចំនួនប្រជាជនដែលមានអនាម័យកាន់តែប្រសើរឡើង | | | | | | | |
| ក. ទីក្រុង | ៤៩ | ១៩៩៨ | ៥៩ | ៥៥ | ៦៧ | ៧៤ | គ |
| ខ. ជនបទ | ៨,៦ | ១៩៩៨ | ១២ | ១៦,៤ | ២០ | ៣០ | ក |
| **ទិសដៅទី១១ : សម្រេចបាននូវការកែលំអការរស់នៅរបស់ប្រជាជនដែលរស់នៅសំណង់អនាធិបតេយ្យ** | | | | | | | |
| ចំនួនដីដែលមានប្លង់កម្មសិទ្ធិ ទាំងនៅទីក្រុង និងតំបន់ជនបទ (%) | ១៥,០ | ២០០០ | ១៦ | ១៦ | ៣២ | ៦៥ | ឃ |

ស្ថានភាព (ចាប់ពីការធ្វើបច្ចុប្បន្នភាព CMDG នៅខែតុលា ឆ្នាំ២០០៥) :

ក. គោលដៅអនុវត្តតាមទិសដៅត្រឹមត្រូវ នាពេលបច្ចុប្បន្ន និងនៅឆ្នាំ២០០៥ ទំនងជាសម្រេចបានជោគជ័យ កាន់តែច្រើនឡើង។

ខ. គោលដៅអនុវត្តតាមទិសដៅត្រឹមតែត្រូវ នាពេលបច្ចុប្បន្ន និង នៅឆ្នាំ២០០៥ ទំនងជាសម្រេចបានជោគជ័យ។

គ. គោលដៅអនុវត្តមិនត្រឹមតាមទិសដៅ នាពេលបច្ចុប្បន្ន និងនៅឆ្នាំ២០០៥ ប៉ុន្តែស្ថានភាពមានភាពប្រសើរឡើង ប្រៀបធៀបទៅនឹងឆ្នាំមូលដ្ឋាន ទំនងជាមិនទទួលបានជោគជ័យទេ។

ឃ. គោលដៅអនុវត្តមិនត្រឹមតាមទិសដៅ នាពេលបច្ចុប្បន្ន និងនៅឆ្នាំ២០០៥ ប៉ុន្តែស្ថានភាព ជាទូទៅ មិនមានភាពប្រសើរឡើងទេ ប្រៀបធៀបទៅនឹងឆ្នាំមូលដ្ឋាន ពិតជាមិនទទួលបានជោគជ័យឡើយ។

ង. គោលដៅអនុវត្តមិនត្រឹមតាមទិសដៅ នាពេលបច្ចុប្បន្ន និងនៅឆ្នាំ២០០៥ ទំនងជាមិនទទួលបានជោគជ័យទេ ប៉ុន្តែស្ថានភាពជាទូទៅកាន់តែអាក្រក់ឡើង ប្រៀបធៀបទៅនឹងឆ្នាំមូលដ្ឋាន។

១. តួលេខនៅក្នុងរង្វង់ក្រចក បង្ហាញពីស្ថានភាព នៅក្នុងតំបន់ដែលត្រូវបានយកមកសិក្សា (៥៦%នៃតំបន់ភូមិសាស្ត្រ និង៦៥%នៃគ្រួសារ ត្រូវបានយកមកសិក្សា នៅក្នុងការស្ទាបស្ទង់មតិ នៅឆ្នាំ១៩៩៣) តំបន់ផ្សេងៗទៀត មិនអាចទៅដល់បាន ដោយសារស្ថានភាពសន្តិសុខ។

៣. ការស្ទាបស្ទង់ប្រជាសាស្ត្រ និងសុខភាព នៅកម្ពុជា។

៤. ស្ថិតិ និងសូចនាករអប់រំ ឆ្នាំ២០០៥/២០០៦។

៥. ព្រៃឈើ ត្រូវបានលើកយកមកសិក្សា ជាមធ្យម នៅក្នុងឆ្នាំ១៩៩២-២០០២។

ប្រភព : វិទ្យាស្ថានជាតិស្ថិតិ។ ផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ ២០០៦-២០១០។ ឧបសម្ព័ន្ធ១.១ ទំព័រ៩៩-១០១។ ប្រទេសកម្ពុជា។

ឧបសម្ព័ន្ធ១

## តារាង ក១.៤ : សូចនាករបរិស្ថានប្រទេស

| សូចនាករ | ឆ្នាំយោង[ក] | ឆ្នាំចុងក្រោយបំផុត |
|---|---|---|
| **ក. ប្រសិទ្ធភាពនៃការបញ្ចេញថាមពល** | | |
| ១. GDP/ឯកតានៃការប្រើថាមពល | ......... | ......... |
| ២. ការប្រើឥន្ទនៈប្រពៃណី (%នៃការប្រើថាមពលសរុប) | ៨៩.៣ (១៩៩៧) | ៨៩.៣ (១៩៩៧) |
| ៣.ការបញ្ចេញកាបូនឌីអុកស៊ីដ | | |
| ក. តោន | ០,៧ (១៩៩៩) | ៤៨៥.៣ (២០០៣)[ខ] |
| ខ. តោនក្នុងម្នាក់ៗ | ០,០៥ (១៩៩៩) | ០,០៣ (២០០៣)[គ] |
| **ខ. ការធ្វើឱ្យទឹកកខ្វក់ : ទឹក និងអនាម័យ** | | |
| ១. %នៃប្រជាជននៅទីក្រុងដែលមានទឹកស្អាតប្រើប្រាស់ | ៥៤ (២០០០) | ៦៤ (២០០៧)[ឃ] |
| ២. %នៃប្រជាជននៅទីជនបទដែលមានទឹកស្អាតប្រើប្រាស់ | ២៦ (២០០០) | ៣៥ (២០០៧)[ឃ] |
| ៣. %នៃប្រជាជននៅទីក្រុងដែលមានអនាម័យ | ៥៥ (២០០០) | ៥៣ (២០០៧)[ឃ] |
| **គ. ការប្រើប្រាស់ដីធ្លី និងការកាប់ព្រៃឈើ** | | |
| ១. ផ្ទៃដីព្រៃឈើ (លានហិកតា) | ៩.៣ (២០០០) | ១០,៤ (២០០៥)[ង] |
| ២. ការកាប់ព្រៃឈើជាមធ្យម | | |
| ក. គីឡូម៉ែត្រការ៉េ | ៥៦១ (១៩៩០-២០០០) | ៥៦១ (២០០០) |
| ខ. % ប្រែប្រួល | ០,៦(១៩៩០-២០០០) | ២ (២០០២-២០០៥)[ច] |
| ៣. ដង់ស៊ីតេប្រជាជនជនបទ (ប្រជាជន/គម² នៃដីអាចដាំដុះបាន) | ២៦៨ (១៩៩៩) | ៣០៥ (២០០៧)[ឆ] |
| ៤. ដីដែលអាចដាំដុះបាន (%នៃផ្ទៃដីសរុប) | ១១,៣ (១៩៨០) | ២១,០ (១៩៩៩) |
| ៥. ផ្ទៃដីដាំដំណាំអចិន្ត្រៃយ៍ (%នៃផ្ទៃដីសរុប) | ០,៤ (១៩៨០) | ០,៦ (១៩៩៩) |
| **ឃ. ជីវៈចម្រុះ និងផ្ទៃដីការពារ** | | |
| ១. រុក្ខជាតិខ្ពស់ (ចំនួនប្រភេទរុក្ខជាតិដែលរងការគម្រាមកំហែង) | ៣១ (២០០៤) | ៣២ (២០០៦)[ឆ] |
| ២. សត្វល្អូន (ចំនួនប្រភេទសត្វ ដែលរងការគម្រាមកំហែង) | ១០ (២០០២) | ១៥ (២០០៦)[ឆ] |
| ៣. មណ្ឌុកសត្វ (ចំនួនប្រភេទសត្វដលរងការគម្រាមកំហែង) | ០ (២០០២) | ៦ (២០០៦)[ឆ] |
| ៤. ផ្ទៃដីការពារថ្នាក់ជាតិ | | |
| ក. លានហិកតា | ៤.៣ (២០០២) | ៤.២ (២០០២)[ជ] |
| ខ. % នៃផ្ទៃដីសរុប | ២៣.៧ (២០០២) | ២៣.៥ (២០០៧)[ឃ] |
| ៥. ថនិកសត្វ (ចំនួនប្រភេទសត្វដែលរងការគម្រាមកំហែង) | ២៩ (២០០២) | ២៣ (២០០៧)[ឃ] |
| ៦. សត្វស្លាប (ចំនួនប្រភេទសត្វដែលរងការគម្រាមកំហែង) | ១៩ (២០០២) | ២៤ (២០០៧)[ឃ] |
| **ង. ទីប្រជុំជន** | | |
| ១. ប្រជាជនទីក្រុង | | |
| ក. លាន | ២.៣ (២០០២) | ២.៧ (២០០៧)[ឃ] |
| ខ. % នៃចំនួនប្រជាជនសរុប | ១៨ (២០០២) | ១៩.៧ (២០០៧)[ឃ] |

| | | | |
|---|---|---|---|
| ២. | ការប្រើទឹកក្នុងម្នាក់ (លីត្រ/ថ្ងៃ)[ឈ] | | |
| | ភ្នំពេញ | | ២៥០ (២០០៧) |
| | ទីរួមខេត្ត | | ១៥០ (២០០៧) |
| | ទីប្រជុំជនដទៃទៀត | ...... | ៦០ (២០០៧) |
| ៣. | ទឹកកខ្វក់ដែលត្រូវបានសំអាត (%) | ...... | |
| ៤. | សម្រាមរឹងដែលត្រូវបានបង្កើតឡើងនៅក្នុងម្នាក់ (គ.ក/ថ្ងៃ) | ...... | ០.៤៦ (២០០២)[ជ] |

GDP = ផលិតផលសរុបក្នុងស្រុក គ.ក = គីឡូក្រាម kgoe = គីឡូក្រាមនៃសមមូលប្រេងកាត គម$^{២}$ = គីឡូម៉ែត្រការ៉េ PPP = កម្លាំងទិញស្មើថ្លៃ។

[ក] ADB. 2005. *Country Strategy and Program (2005-2009) Table A1.4, p 35: Cambodia*.Manila.

[ខ] Carbon dioxide emisison (CO2), United Nations Statistics Divison, 2003 http://unstats.un.org/unsd/cdb/cdb years on top.assp?srID=30249&ct1ID=&crID=116&yrID=2003

[គ] The Little Green Data Book, p.59, http://sisteresource.worldbank.org/INTEE/93621411462515-11077/213295/ LGB2007.pdf

[ឃ] អង្កេតការជំរឿនប្រជាជនចន្លោះ ឆ្នាំ២០០៤។ សៀវភៅផែនទីប្រទេសកម្ពុជា ភាពក្រីក្រថ្នាក់ជាតិ និងផែនទីបរិស្ថាន ទីក្រុងភ្នំពេញ ឆ្នាំ២០០៦ ទំព័រ១២២។

[ង] FAO. ការវាយតម្លៃធនធានព្រៃឈើ ឆ្នាំ ១៩៩៩ ២០០០ និង២០០៥។

[ច] វិទ្យាស្ថានធនធានអភិវឌ្ឍន៍កម្ពុជា។ សៀវភៅផែនទីប្រទេសកម្ពុជា ទំព័រ៤២។

[ឆ] បញ្ជីពណ៌ក្រហម IUCN នៃប្រភេទសត្វ ឬរុក្ខជាតិដែលទទួលរងការគំរាមកំហែង: ការសង្ខេបស្ថិតិ ឆ្នាំ២០០៦ : ការសង្ខេបស្ថិតិ។ http://www.iucnredlist.org/info/tables/table5.

[ជ] រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៤។ ព្រៃឈើសំបូរទៅដោយធនធាន។ ប្រទេសកម្ពុជា។

[ឈ] រោងចក្រសំអាតទឹកកខ្វក់នៅទីក្រុងព្រះសីហនុតែមួយគត់។ តំបន់ទីក្រុងដទៃទៀត រួមទាំងទីក្រុងភ្នំពេញសំអាតតែទឹកកខ្វក់តាមរយៈការផ្ទុកទឹកកខ្វក់នៅក្នុងស្រះ (ដំណើរការសំអាតតាមបែបធម្មជាតិ)។

# ការធ្វើចំណាត់ថ្នាក់លើការវាយតម្លៃការអនុវត្តប្រចាំប្រទេស

| ការធ្វើចំណាត់ថ្នាក់[ក] | លក្ខណវិនិច្ឆ័យ/សូចនាករសំខាន់ |
|---|---|
| **៣.៨** | **ក. ការគ្រប់គ្រងសេដ្ឋកិច្ច** |
| ៤.៥ | ១. ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច |
| ៣.៥ | ២. គោលនយោបាយសារពើពន្ធ |
| ៣.៥ | ៣. គោលនយោបាយជំពាក់បំណុល |
| **៣.៣** | **ខ. គោលនយោបាយរចនាសម្ព័ន្ធ** |
| ៤.0 | ១. ពាណិជ្ជកម្ម |
| ៣.0 | ២. វិស័យហិរញ្ញវត្ថុ |
| ៣.0 | ៣. បរិស្ថាននិយ័តកម្មក្នុងការធ្វើពាណិជ្ជកម្ម |
| **៣.៣** | **គ. ការដាក់បញ្ចូលទៅក្នុងសង្គម/សមធម៌** |
| ៤.0 | ១. សមធម៌យេនឌ័រ |
| ៣.៥ | ២. សមធម៌នៃការប្រើប្រាស់ធនធានសាធារណៈ |
| ៤.0 | ៣. ការកសាងធនធានមនុស្ស |
| ២.៥ | ៤. ការការពារសង្គម និងពលករ |
| ២.៥ | ៥. គោលនយោបាយ និងស្ថាប័នសម្រាប់ទ្រទ្រង់ដល់បរិស្ថាន |
| **២.៨** | **ឃ. អភិបាលកិច្ច និងការគ្រប់គ្រងវិស័យសាធារណៈ** |
| ២.៥ | ១. សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ និងអភិបាលផ្អែកលើច្បាប់ |
| ៣.0 | ២. គុណភាពនៃការគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ |
| ៣.៥ | ៣. ប្រសិទ្ធផលនៃការកៀងគរផលទុន |
| ២.៥ | ៤. គុណភាពខាងផ្នែករដ្ឋបាលសាធារណៈ |
| ២.៥ | ៥. តម្លាភាព គណនេយ្យភាព និងអំពើពុករលួយ នៅក្នុងវិស័យសាធារណៈ |
| **៥.៥** | **ង. ផលប័ត្រ (Portrolio)** |
| ៥.៥ | ១. ផលប័ត្រ **(Portrolio)** |

[ក] Cambodia Resident Mission. Country Performance Assessment. 2006. Cambodia. The 2007 CPA exercise is schedule to take place in July 2007.

# វិស័យ និងប្រធានបទអាទិភាពដែលត្រូវធ្វើបច្ចុប្បន្នភាព

| វិស័យនាំមុខ | ការអភិវឌ្ឍ នៅពេលអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស |
|---|---|
| **កសិកម្ម និងវិស័យធនធានធម្មជាតិ** | ការរីកចម្រើន ត្រូវបានវាយតម្លៃដោយផ្អែកលើលទ្ធផលរបស់វិស័យសំខាន់ៗបួន ដែលមានផែនការ ដើម្បីកាត់បន្ថយភាពក្រីក្រ (ជាពិសេស ភាពក្រីក្រនៅតាមជនបទ) និងរក្សាកំណើនផលិតផលក្នុងស្រុកសរុប ឱ្យបាន៦ភាគរយក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០០៦ រហូតដល់ឆ្នាំ២០១០។ លទ្ធផលរបស់វិស័យសំខាន់ៗទាំងនោះ រួមមាន : (១) ផលិតកម្មកសិកម្មកើនឡើង (២) បរិស្ថានគោលនយោបាយកាន់តែមានភាពប្រសើរឡើង ដើម្បីធ្វើឱ្យមានកំណើនសហគ្រាសឯកជនផ្អែកលើវិស័យកសិ-ឧស្សាហកម្ម (៣) ការគ្រប់គ្រង និងការអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព និង (៤) ការខាតបង់ផ្នែកសេដ្ឋកិច្ច ដែលបណ្តាលមកពីទឹកជំនន់ និងគ្រោះរាំងស្ងួត មានការថយចុះ។ កសិកម្មមានការរីកចម្រើនយ៉ាងខ្លាំងក្លា រហូតដល់១៥.៧ភាគរយ នៅឆ្នាំ២០០៥ បន្ទាប់មក កើនបាន៥.៥ភាគរយទៀត នៅឆ្នាំ២០០៦ ក្រោយពីមានការថយចុះបន្តិចបន្តួច (-0,៩ភាគរយ) នៅឆ្នាំ២០០៤។ ទោះជាយ៉ាងណាក៏ដោយ វិស័យនេះនៅតែប្រឈមមុខនឹងឧបសគ្គជាច្រើនដដែល។<br>**ឆ្លើយតបទៅនឹងសំណើរបស់រដ្ឋាភិបាលទៅកាន់ ADB ដើម្បីឱ្យធនាគារនេះផ្តោតទៅលើកិច្ចប្រតិបត្តិការរបស់ខ្លួន លើការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ឱ្យបានកាន់តែខ្លាំងក្លា ដើម្បីធ្វើឱ្យមានតុល្យភាពនៃរយៈពេលអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រប្រចាំប្រទេស (CSP) ទិសដៅរបស់ ADB នឹងផ្តោតទៅលើ : (១) ការអនុវត្តយ៉ាងយកចិត្តទុកដាក់លើកម្មវិធី និងគម្រោង ដែលកំពុងតែអនុវត្តតាមវិស័យ (២) ការបង្កើតកម្មវិធីកំណែទម្រង់គោលនយោបាយពហុវិស័យតាមជនបទ និងការរៀបចំស្ថាប័នពាក់ព័ន្ធ សម្រាប់ការធ្វេសប្រហែសក្នុងការអនុវត្តរបស់ខ្លួន ប្រកបដោយលក្ខណៈសម្របសម្រួល (៣) ការអនុវត្តគម្រោងផ្តួចផ្តើមបឹងទន្លេសាបកាន់តែខ្លាំងក្លាឡើង (៤) ពង្រីកកម្មវិធីធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) របស់ក្រសួងអភិវឌ្ឍន៍ជនបទ និង (៥) គម្រោងផ្តួចផ្តើមអនុតំបន់ស្តីពីការស្វែងរកដំណោះស្រាយសម្រាប់វិស័យកសិកម្មថ្មីៗ។** |
| **វិស័យដឹកជញ្ជូន** | ការរីកចម្រើន ត្រូវបានវាយតម្លៃដោយផ្អែកលើលទ្ធផលសំខាន់ៗ៥ : (១) ប្រសិទ្ធផលនៃការដឹកជញ្ជូនកើនឡើង (២)ការទ្រទ្រង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន កាន់តែមានភាពប្រសើរឡើង (៣) លទ្ធភាពទៅកាន់តំបន់ជនបទកាន់តែមានភាពប្រសើរឡើង (៤) ការអនុវត្តគោលនយោបាយការពារ និង (៥) សុវត្ថិភាពផ្លូវថ្នល់កាន់តែមានភាពប្រសើរឡើង។ ការរីកចម្រើន មានការកើនឡើង ប៉ុន្តែឧបសគ្គចម្បងក្នុងការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទៅកាន់តំបន់ជនបទ នៅតែមានដដែល។ ឧបសគ្គទាំងនោះ ទាមទារឱ្យមានការដោះស្រាយ ដើម្បីធានាថា បណ្តាញផ្លូវថ្នល់នៅតាមខេត្ត និងតំបន់ជនបទ ត្រូវបានស្តារឡើងវិញ និងថែរក្សា ដើម្បីទៅកាន់តំបន់ជនបទ ប្រកបដោយប្រសិទ្ធភាព។ ថ្លៃដឹកជញ្ជូននៅតាមតំបន់ជនបទ នៅតែមានតម្លៃខ្ពស់ដដែល ហើយអាចនឹងធ្វើឱ្យការនាំចេញផលិតផលកសិកម្មរបស់ប្រទេសកម្ពុជាទៅកាន់អនុតំបន់ មានការរាំងស្ទះទៀតផង។ របាយការណ៍ឆ្នាំ២០០៧ របស់វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា បានប៉ាន់ប្រមាណថា ថ្លៃដឹកជញ្ជូនគ្រាប់ធញ្ញជាតិ ១តោន លើចម្ងាយផ្លូវជាង១០០គ.ម គឺប្រហែលជា១២ដុល្លា នៅប្រទេសកម្ពុជា បើប្រៀបធៀបទៅប្រទេសវៀតណាម មានតម្លៃ៥ដុល្លា និងប្រទេសថៃ មានតម្លៃ២.៥០ដុល្លាតែប៉ុណ្ណោះ។<br>**សម្រាប់តុល្យការនៃរយៈពេល CSP កិច្ចប្រតិបត្តិការរបស់ ADB នឹងផ្លាស់ប្តូរពីកិច្ច** |

| | |
|---|---|
| | ប្រតិបត្តិការទ្រង់ទ្រាយធំលើផ្លូវថ្នល់ និងផ្លូវដែកក្នុងវិស័យសាធារណៈ ទៅលើកកម្ពស់កិច្ចសហការលើផ្នែកបច្ចេកទេស បរិស្ថានដែលមានបទដ្ឋាន ការវិនិយោគទុនរបស់វិស័យឯកជន និងផ្នែក **Sotfware** ព្រមទាំងផលប៉ះពាល់លើការអភិវឌ្ឍជនបទនៃការតភ្ជាប់ការដឹកជញ្ជូនតាមអនុតំបន់។ នេះមានន័យថា **ADB** នឹងផ្តោតទៅលើ (១)សុវត្ថិភាពផ្លូវជាតិ ការការពារសង្គម បទដ្ឋានបច្ចេកទេស និងការលើកកម្ពស់បទដ្ឋានទាំងនោះលើគ្រប់វិស័យ តាមរយៈការពិភាក្សាលើកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស ជាមួយរដ្ឋាភិបាល និងដៃគូផ្តល់ជំនួយឯកតោភាគី (២) ការថែរក្សា និងបញ្ហាពាក់ព័ន្ធនានាស្តីពីមូលដ្ឋានគ្រឹះតាមស្ថាប័នមួយប្រកបដោយនិរន្តរភាព មានបទដ្ឋានគុណភាពតាមរយៈគម្រោងគ្រប់គ្រងទ្រព្យសកម្មផ្លូវថ្នល់ ដែលផ្តល់ជំនួយហិរញ្ញវត្ថុដោយដៃគូផ្តល់ជំនួយពហុភាគី (៣) ជំរុញឱ្យមានការចូលរួមពីដៃគូផ្តល់ជំនួយផ្សេងៗទៀត ក្នុងការភ្ជាប់ទំនាក់ទំនងតាមអនុតំបន់ តាមរយៈកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរួម (៤) ជំរុញឱ្យមានការវិនិយោគទុនរបស់វិស័យឯកជននៅក្នុងប្រព័ន្ធផ្លូវដែក តាមរយៈការអនុវត្តការស្តារឡើងវិញនូវផ្លូវដែក នៅតាមហាអនុតំបន់ទន្លេមេគង្គ នៅក្នុងគម្រោងរបស់ប្រទេសកម្ពុជា ប្រកបដោយប្រសិទ្ធភាព និង (៥) ការឧបត្ថម្ភគាំទ្រឱ្យមានលទ្ធភាពទៅកាន់តំបន់ជនបទ កាន់តែប្រសើរឡើង តាមរយៈគម្រោងដឹកជញ្ជូនតាមអនុតំបន់នៅតាមខេត្តជនបទ។ |
| **វិស័យថាមពល** | ការរីកចម្រើន ត្រូវបានវាយតម្លៃ ដោយផ្អែកលើការផ្គត់ផ្គង់ថាមពលគ្រប់គ្រាន់ និងអាចប្រើប្រាស់បាន និងប្រសិទ្ធផលនៃកិច្ចប្រតិបត្តិការរបស់អគ្គិសនីកម្ពុជា (EDC)។ ចំពោះការបង្កើនលទ្ធភាពក្នុងការផ្គត់ផ្គង់ថាមពលគ្រប់គ្រាន់ និងអាចប្រើប្រាស់បាន កម្ពុជាកំពុងអនុវត្តតាមការណែនាំ ដើម្បីសម្រេចទិសដៅរបស់ខ្លួន ក្នុងការបង្កើនប្រវែងបណ្តាញតភ្ជាប់ចរន្តអគ្គិសនី រហូតដល់១០០គីឡូវ៉ាត់ចាប់តាំងពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ និងបង្កើនការប្រើប្រាស់អគ្គិសនីក្នុងមនុស្សម្នាក់ ពី៥៤គីឡូវ៉ាត់ក្នុងមួយម៉ោង នៅឆ្នាំ២០០៥ រហូតដល់៨៩គីឡូវ៉ាត់ក្នុងមួយម៉ោង នៅឆ្នាំ២០១០។ ក្នុងការឆ្លើយតបទៅនឹងតម្រូវការកើនឡើងរបស់សេដ្ឋកិច្ចដែលកំពុងរីកចម្រើន និងការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានអគ្គិសនីប្រើប្រាស់ និងការកាត់បន្ថយថ្លៃភ្លើងអគ្គិសនី នៅតាមជនបទ នៅតែមានឧបសគ្គ។ ចំពោះប្រសិទ្ធផលនៃកិច្ចប្រតិបត្តិការរបស់អគ្គិសនីកម្ពុជា ការរីកចម្រើនមានការកើនឡើង ដោយមិនគិតពីការកើនឡើងនៃពន្ធទំនិញនាំចេញ នាំចូល ការធ្វើសនិទានកម្មលើប្រភេទពន្ធទំនិញនាំចេញនាំចូលតាមរយៈនិយ័តករ និងការកើនឡើងនូវថវិកាបម្រុងទុករបស់រដ្ឋាភិបាល សម្រាប់ថ្លៃអគ្គិសនី និងការទូទាត់សងបំណុល។ ជាលទ្ធផល ស្ថានភាពហិរញ្ញវត្ថុរបស់អគ្គិសនីកម្ពុជា កំពុងមានភាពប្រសើរឡើង ហើយអគ្គិសនីនឹងលែងដាច់ទៀតហើយ សូម្បីតែនៅឆ្នាំ២០០៨នេះ។<br>**ដោយមានការចាប់អារម្មណ៍របស់វិស័យឯកជនដែលកំពុងមានការរីកចម្រើន មកលើវិស័យថាមពល ADB នឹងផ្លាស់ប្តូរពីប្រតិបត្តិការផ្តល់ប្រាក់កម្ចីដល់វិស័យសាធារណៈតាមបែបបុរាណ នៅក្នុងផ្នែកអគ្គិសនី។ សម្រាប់តុល្យភាពនៃរយៈពេល CSP, ADB នឹងផ្តោតលើ : (១) ការអនុវត្តគម្រោងរបស់វិស័យសាធារណៈដែលមានជាបន្តជាមួយអគ្គិសនីកម្ពុជា ប្រកបដោយប្រសិទ្ធភាព (២) ការគាំទ្រដល់កិច្ចប្រតិបត្តិការរបស់វិស័យឯកជន (៣) ការងារវិភាគ គោលនយោបាយ និងបច្ចេកទេសក្នុងការលេចឡើងនូវតំបន់ប្រេង និងឧស្ម័ន និង (៤) ការងារវិភាគទៅលើលទ្ធភាព និងរចនាសម្ព័ន្ធរបស់គោលនយោបាយសាធារណៈ សម្រាប់ថាមពលកើតថ្មី នៅប្រទេសកម្ពុជា។** |
| **វិស័យទឹកស្អាត និងអនាម័យ** | ការរីកចម្រើន ត្រូវបានវាយតម្លៃដោយផ្អែកលើលទ្ធផលរបស់វិស័យ២ (ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ |

| | |
|---|---|
| | និងប្រកបដោយនិរន្តរភាព និងការយល់ដឹងរបស់សហគមន៍) ដែលមានគោលបំណងធ្វើឱ្យសុខភាព និងការរស់នៅរបស់ប្រជាជន នៅតាមជនបទ មានភាពប្រសើរឡើង។ គោលបំណងរបស់ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ និងប្រកបដោយនិរន្តរភាព សម្រាប់ជួយសម្រួលដល់ការផ្គត់ផ្គង់ទឹកបរិភោគមានសុវត្ថិភាព និងអនាម័យ ត្រូវបានឧបត្ថម្ភដោយគម្រោងមួយចំនួន ដូចជា គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅតំបន់ជនបទតាមបឹងទន្លេសាបរបស់ ADB ជាដើម។ ដើម្បីធានាឱ្យមានការយល់ដឹងពីសហគមន៍ ចំពោះទំនាក់ទំនងរវាងយេនឌ័រ ទឹកមានសុវត្ថិភាព អនាម័យ និងសុខភាព កិច្ចខំប្រឹងប្រែងក្នុងការកៀងគរសហគមន៍ ក្រោមគម្រោងបឹងទន្លេសាបរបស់ ADB រួមទាំងកិច្ចខំប្រឹងប្រែងរបស់ដៃគូផ្តល់ជំនួយផ្សេងៗទៀត ដូចជា កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) ពិតជាមានប្រយោជន៍ណាស់។ ប៉ុន្តែ រដ្ឋាភិបាលត្រូវគាំទ្រដល់កិច្ចខំប្រឹងប្រែងទាំងនេះ ដោយតាំងចិត្តតាមដានការយល់ដឹងរបស់សហគមន៍ ឱ្យដូចជាផ្នែកមួយនៃយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ។<br>**ចំពោះតុល្យការនៃរយៈពេល CSP, ADB នឹងផ្តោតលើ : (១) ការតាមដានយ៉ាងជិតស្និទលើការអនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតាមតំបន់ជនបទ បឹងទន្លេសាប (២) ធ្វើការតាំងចិត្តរយៈពេលមធ្យម ដើម្បីទទួលបានការវិនិយោគតាមវិស័យ និងកៀងគរដៃគូផ្តល់ជំនួយបន្ថែមទៀត ដើម្បីផ្តល់មូលនិធិសម្រាប់ហេដ្ឋារចនាសម្ព័ន្ធផ្នែកតាមវិស័យ ក្នុងការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យតាមតំបន់ជនបទ (៣) បង្កើតយុទ្ធសាស្ត្រផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ដោយធ្វើឱ្យដៃគូផ្តល់ជំនួយផ្សេងៗទៀត តាំងចិត្តប្រកបដោយការវិភាគ និងតាមវិស័យ ព្រមទាំងធ្វើឱ្យរដ្ឋាភិបាលតាំងចិត្តចំពោះសូចនាករតាមដានរួមគ្នា នាថ្ងៃអនាគត (JMI) ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។** |
| **វិស័យសហគ្រាសធុនតូច និងធម្យម (SME)** | សហគ្រាសធុនតូច និងធម្យម (SMEs) ត្រូវបានគេមើលឃើញថាជាប្រភពដ៏ខ្លាំងក្លា ដែលធ្វើឱ្យមានកំណើនសេដ្ឋកិច្ចចម្រុះ និងប្រកបដោយសមធម៌។ ការរីកចម្រើនមួយចំនួន កើនឡើងដោយគិតទៅលើ : (១) ការអនុម័តរបស់រដ្ឋាភិបាលលើរចនាសម្ព័ន្ធជាតិដើម្បីអភិវឌ្ឍសហគ្រាសធុនតូច និងធម្យម (SMEDF) នៅចុងឆ្នាំ២០០៥ (២) ការអនុម័តកំណែទម្រង់ច្បាប់ និងបទបញ្ញត្តិសំខាន់ៗ (៣) ទំនុកចិត្តលើផ្នែកពាណិជ្ជកម្ម ដែលបានឆ្លុះបញ្ចាំងនៅក្នុងការស្ទាបស្ទង់ពីបរិយាកាសក្នុងការវិនិយោគទុន មានការកើនឡើង (៤) កិច្ចសន្ទនារបស់វិស័យឯកជន និង (៥) ការកើនឡើងនូវចំនួនពាណិជ្ជកម្មដែលបានចុះបញ្ជី។ ប៉ុន្តែឧបសគ្គក្នុងការអនុវត្ត SMEDF ឱ្យមានប្រសិទ្ធភាពនៅតែមានដដែល ដូចជា : (១) ឧបសគ្គក្នុងការកសាងសមត្ថភាព ដើម្បីអនុវត្តវិមជ្ឈការឱ្យមានប្រសិទ្ធភាព និងផ្សព្វផ្សាយការចុះបញ្ជីពាណិជ្ជកម្ម (២) តម្រូវការដ៏ច្រើននៃឥណទានឯកជនក្នុងបង្កើតសហគ្រាសធុនតូច និងមធ្យម ដើម្បីមានដើមទុនគ្រប់គ្រាន់ និង (៣) តម្រូវការក្នុងការបញ្ជាក់បន្ថែមពីអភិបាលកិច្ច និងហានិភ័យ នៃអំពើពុករលួយ។<br>**សម្រាប់តុល្យភាពនៃរយៈពេល CSP, ADB នឹង : (១) ឧបត្ថម្ភគាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់គោលនយោបាយបន្ត និងអនុម័តគម្រោងថ្មីៗ ដើម្បីបង្កើតឱ្យមានបរិយាកាស ជំរុញកាន់តែប្រសើរឡើងសម្រាប់ធ្វើឱ្យSMEsអនុលោមទៅតាមទស្សនវិស័យរយៈពេលយូររបស់ SMEDF ថ្នាក់ជាតិ (២) ឧបត្ថម្ភគាំទ្រដល់ការធ្វើកំណែទម្រង់អភិបាលកិច្ចដែលមានលក្ខណៈសហប្រតិបត្តិការចម្បងៗ សម្រាប់ SME និង (៣) សម្របសម្រួលដល់ការវិនិយោគទុនលើវិស័យ SME ដោយមានការឧបត្ថម្ភគាំទ្រពីដៃគូផ្តល់ជំនួយផ្សេងៗទៀត គម្រោងរបស់ SME ផ្តោតលើលទ្ធផល សម្រាប់ការអភិវឌ្ឍជាក់ស្តែងលើសេវាកម្មពាណិជ្ជកម្ម ដែលតម្រូវឱ្យមានការពង្រឹង ជំនាញសហគ្រិន បច្ចេកវិទ្យា ធនធានមនុស្សរបស់ SMEs ។** |

| | |
|---|---|
| **វិស័យហិរញ្ញវត្ថុ** | វិស័យនេះ ព្យាយាមបង្កើតប្រព័ន្ធហិរញ្ញវត្ថុដោយផ្អែកលើទីផ្សារ ដែលគាំទ្រឱ្យមានការកៀងគរធនធាន និងការធ្វើអន្តរាគមន៍ហិរញ្ញវត្ថុ។ ការរីកចម្រើននេះត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋានគ្រឹះនៃសូចនាកររបស់លទ្ធផលជាក់លាក់ : ឥណទានរបស់វិស័យឯកជនមានការកើនឡើង អត្រាការប្រាក់ថយចុះ ការកើនឡើងនូវផលធៀបទ្រព្យសកម្ម/ផលិតផលក្នុងស្រុកសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ（MFI） និងការកើនឡើងនូវផលធៀបរវាងប្រាក់ធានារ៉ាប់រង/ផលិតផលក្នុងស្រុកសរុប។ សរុបមក វិស័យហិរញ្ញវត្ថុដែលកំពុងចាប់កំណើតឡើងនៅប្រទេសកម្ពុជា មានការកើនឡើង។ ឥណទានរបស់វិស័យឯកជនមានការកើនឡើងគួរឱ្យកត់សម្គាល់ ចាប់ពី៩,៤ភាគរយ នៅឆ្នាំ២០០៥ ដល់១២,៣ភាគរយ នៅឆ្នាំ២០០៦។ មីក្រូហិរញ្ញវត្ថុ និងអនុវិស័យធានារ៉ាប់រង មានភាពប្រសើរជាងមុន។ នៅឆ្នាំ២០០៥ ទ្រព្យសកម្មរបស់ MFI ស្មើនឹង១ភាគរយនៃផលិតផលក្នុងស្រុកសរុប នៅពេលដែលប្រាក់ថ្លៃធានារ៉ាប់រង ស្មើនឹង០,២ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ទោះបីមានទំនុកចិត្តកាន់តែខ្លាំងក៏ដោយ ក៏វិស័យហិរញ្ញវត្ថុនៅតែងាយទទួលប្រឈមមុខនឹងហានិភ័យ និងការចំណាយជាច្រើន ដែលមានការកត់សម្គាល់ខ្លាំងឡើង ដោយសារកំណើនសេដ្ឋកិច្ច កាន់តែមានការកើនឡើង។<br>**ចំពោះតុល្យភាពនៃរយៈពេល CSP ប្រតិបត្តិការលើវិស័យហិរញ្ញវត្ថុរបស់ ADB នឹងត្រូវបានផ្តោតទៅលើស៊េរីនៃផែនការអភិវឌ្ឍតាមវិស័យ ក្រោមទិសដៅនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យហិរញ្ញវត្ថុរបស់រដ្ឋាភិបាល（FSDS） ឆ្នាំ២០០៦-២០១៥ ដើម្បីជំរុញឱ្យមានការគ្រប់គ្រងកាន់តែប្រសើរទៀត លើហានិភ័យនៅក្នុងវិស័យហិរញ្ញវត្ថុ ថ្លៃដើម និងឧបសគ្គរាំងស្ទះដល់ស្ថាប័ន និងប្រព័ន្ធនៅក្នុងសេដ្ឋកិច្ចដែលកំពុងមានការរីកចម្រើន។** |
| **វិស័យអប់រំ** | ការរីកចម្រើន ត្រូវបានវាយតម្លៃ ដោយផ្អែកលើលទ្ធផលតាមវិស័យចំនួន៤ : លទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា រួមទាំងនៅខេត្តដាច់ស្រយាល ប្រសិទ្ធភាពផ្ទៃក្នុង និងការកសាងសមត្ថភាពរបស់ស្ថាប័ន ដើម្បីទទួលបានការអប់រំមួយ ប្រកបដោយគុណភាពសមភាពយេនឌ័រ និងការប្រើប្រាស់ធនធាន ដើម្បីឧបត្ថម្ភដល់ការចំណាយផ្ទួនៗ។ ការរីកចម្រើននៅតែមាន ដោយមិនគិតពីការប្រើប្រាស់ធនធាន ដែលកើនឡើងរហូតដល់១៨,៥ភាគរយនៃថវិកាផ្ទួនៗ ការតាំងចិត្តយ៉ាងខ្លាំងក្លារបស់ដៃគូផ្តល់ជំនួយ ដែលជំរុញនូវវិសាលភាពក្នុងការកសាងសាលារៀន និងចាប់ផ្តើមការកសាងសមត្ថភាព សម្រាប់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដែលមានតម្រូវការខ្ពស់។ វគ្គនេះរួមមាន គម្រោងអភិវឌ្ឍន៍វិស័យអប់រំលើកទី២របស់ ADB ដែលគាំទ្រដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្នុងដំណាក់កាលចាប់ផ្តើមទី១នៃកម្មវិធីបណ្តុះបណ្តាលជំនាញ ផ្អែកតាមសហគមន៍ តាមរយៈសៀវភៅបញ្ជាក់ពីការបណ្តុះបណ្តាលនៅតាមឃុំចំនួន២១០ ក្នុងចំណោមឃុំក្រីក្រជាងគេបំផុត នៅក្នុងខេត្តចំនួន៧ និងការអភិវឌ្ឍស្ថាប័ន ព្រមទាំងការកសាងសមត្ថភាព។ ទោះជាយ៉ាងណាក៏ដោយ មានកិច្ចការជាច្រើន ទាមទារឱ្យមានការអនុវត្ត ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា（CMDG）សម្រាប់ការអប់រំជាសកល ដើម្បីកាត់បន្ថយអត្រាបោះបង់ចោលការសិក្សា បញ្ជាក់ពីអត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សា ដែលស្ថិតនៅនឹងមួយកន្លែង និងដើម្បីផ្តល់ការអប់រំ ដល់អ្នកគ្មានការអប់រំ ដែលគ្មានលទ្ធភាពទទួលបានការអប់រំក្នុងប្រព័ន្ធ។<br>**ADB នឹង（១） ជំរុញឱ្យមានការកែទម្រង់បន្ថែមទៀត ដោយគាំទ្រដល់ការអភិវឌ្ឍម៉ាទ្រីកនៃវិធានការគោលនយោបាយលើគ្រប់វិស័យរបស់ផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០០៦-២០១០ និងច្បាប់នៃការអប់រំ（២） ជំរុញឱ្យមានការគាំទ្រពីដៃគូផ្តល់ជំនួយ ចំពោះការកែទម្រង់ស្ថាប័នក្នុងក្រសួង** |

| | |
|---|---|
| | **អប់រំ ក្នុងទិសដៅគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលអប់រំជាសាធារណៈ ដោយផ្អែកទៅលើគុណូបការៈ (៣) ធ្វើឱ្យការកែលំអគុណភាពការអប់រំ មានស្តង់ដា និងចែកចាយដល់គ្រប់តំបន់ និង (៥) ពង្រឹងទំនាក់ទំនងរវាងការអប់រំ និងការអភិវឌ្ឍជនបទ ដើម្បីធ្វើឱ្យកម្លាំងពលកម្មនៅតាមជនបទ មានការកើនឡើង តាមរយៈការផ្តោតយ៉ាងយកចិត្តទុកដាក់លើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស។** |
| **វិស័យទេសចរណ៍** | ការរីកចម្រើន ត្រូវបានវាយតម្លៃ ដោយគិតទៅលើកំណើនក្នុងវិស័យទេសចរណ៍ និងល្បឿននៃការអនុវត្តគម្រោង។ ទេសចរណ៍គឺជាកត្តាមួយជួយជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ដោយមានភ្ញៀវទេសចរ ចូលមកទស្សនាចំនួនប្រហែលជា១,៧លាននាក់ នៅឆ្នាំ២០០៦ និងមានការរំពឹងទុកថា ចំនួននេះអាចនឹងកើនឡើងរហូតដល់២លាននាក់ នៅឆ្នាំ២០០៧។ ប៉ុន្តែ ការអនុវត្តគម្រោងមានភាពយឺតយ៉ាវ។ គម្រោងអភិវឌ្ឍន៍វិស័យទេសចរណ៍របស់ប្រទេសនៅតាមទន្លេមេគង្គ ដែលផ្តល់ជំនួយដោយ ADB ត្រូវបានពន្យារពេលដោយសារបញ្ហាដែលមិនអាចដោះស្រាយបាន ទាក់ទងទៅនឹងថ្លៃរោងចក្របំលែងទឹកកាកសំណល់នៅក្នុងខេត្តសៀមរាប និងព្រលានយន្តហោះនៅភាគឦសាន។ ប៉ុន្តែ ក្រសួងទេសចរណ៍ បានតាំងចិត្តដោះស្រាយបញ្ហាទាំងនេះ នៅឆ្នាំ២០០៧។<br>**សម្រាប់រយៈពេលនៅសល់នៃរយៈពេល CSP, ADB នឹងផ្តោតទៅលើ : (១) ការតាមដានយ៉ាងយកចិត្តទុកដាក់លើការអនុវត្តគម្រោងអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងប្រទេស នៅតាមដងទន្លេមេគង្គ និង (២) លើកកម្ពស់សិទ្ធិកាន់កាប់ដីផ្អែកលើសហគមន៍ និងលើកកម្ពស់ផលិតកម្ម ផលិតផលកសិកម្ម ឱ្យកាន់តែប្រសើរឡើង ដើម្បីគាំទ្រដល់សេដ្ឋកិច្ចទេសចរណ៍ ក្នុងរយៈពេលមធ្យម ដើម្បីបង្កើត អត្ថប្រយោជន៍ក្នុងវិស័យទេសចរណ៍ ដល់ប្រជាជនក្រីក្រនៅតាមតំបន់ជនបទ។ គ្មានគម្រោងរបស់ វិស័យទេសចរណ៍ផ្ទាល់ណា សុទ្ធតែត្រូវបានទទួលស្គាល់ នៅក្នុងតុល្យភាពនៃរយៈពេល CSP ទេ។** |
| **វិស័យសុខភាព** | ការអភិវឌ្ឍនាពេលថ្មីៗនេះ គាំទ្រដល់ការសម្រេចចិត្តរបស់ ADB នៅពេលចាប់ផ្តើមដំណើរការ CSP ឆ្នាំ២០០៥-២០០៩ ដើម្បីបញ្ឈប់លែងឱ្យមានអន្តរាគមន៍លើវិស័យសុខភាពថ្នាក់ជាតិដោយផ្ទាល់ នៅប្រទេសកម្ពុជា។ ការរីកចម្រើនជាដុំកំភួន មាននៅក្នុងសូចនាករសេវាកម្មសុខភាពផ្ទាល់មួយចំនួន។ នៅពេលដែលវិស័យសុខភាពនៅតែប្រឈមមុខនឹងឧបសគ្គដដែល (ដូចជាការធ្វើឱ្យអត្រាមរណៈរបស់មាតា កាន់តែមានភាពប្រសើរឡើង) មានមូលនិធិសំខាន់ៗ ប៉ុន្តែដោយផ្អែកដែលទទួលបានពីម្ចាស់ជំនួយ សម្រាប់ជួយដល់អន្តរាគមន៍លើវិស័យសុខភាពដោយផ្ទាល់ ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ប្រសិទ្ធភាពជំនួយរបស់រដ្ឋាភិបាល នៅឆ្នាំ២០០៧។<br>**គ្មានការផ្លាស់ប្តូរណាមួយ នៅក្នុងការបញ្ឈប់លែងឱ្យមានអន្តរាគមន៍ថ្នាក់ជាតិលើផ្នែកសុខភាពដោយផ្ទាល់ នាពេលបច្ចុប្បន្ននេះ ត្រូវបានផ្តល់យោបល់ទេ ប៉ុន្តែមានការផ្តល់នូវលក្ខណៈអន្តរតំបន់នៃជំងឺឆ្លងវិញ គម្រោង GMS ស្តីពីការគ្រប់គ្រងជំងឺឆ្លង ផ្អែកលើការអនុវត្តគម្រោងថ្នាក់ជាតិ ដែលមានជាបន្ត នឹងត្រូវបានអនុវត្តបន្ត។** |
| **ការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព** | ការអភិវឌ្ឍជាដុំកំភួន កើតមានឡើង នៅពេលដែល CSP ត្រូវបានអនុវត្ត។ ស្ថានភាពនយោបាយមានស្ថេរភាព ហើយត្រូវបានរំពឹងថា វានៅតែមានស្ថេរភាពរហូតដល់ក្រោយការបោះឆ្នោតជាសកលឆ្នាំ២០០៨។ សេដ្ឋកិច្ចបានកើនឡើងហួសពីការរំពឹងទុកទៀត ហើយការរំពឹងទុកក្នុងរយៈពេលមធ្យម |

| | |
|---|---|
| | ថា នឹងមានការលួតលាស់ខ្លាំង មានផលជាវិជ្ជមាន។ ការគ្រប់គ្រងបំណុលផ្ទៃក្នុង ត្រូវបានលើកឡើង នៅពេលដែលហានិភ័យនៃការទារបំណុល កំពុងធ្លាក់ចុះ។ ប៉ុន្តែ ពពកខ្មៅនៅតែមានដដែល (ភាពក្រីក្រ និងអភិបាលកិច្ចមិនល្អ)។ សូចនាករផ្នែកសង្គម បានលើកឡើងពីការប្រតិបត្តិរួមគ្នា ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា។ នៅពេលដែលភាពក្រីក្រធ្លាក់ចុះ វិសមភាពនៃប្រាក់ចំណូល មានកាន់តែច្រើនឡើង ហើយភាពក្រីក្រនៅតាមជនបទ នៅតែមានដដែល។ ទស្សនៈចំពោះអភិបាលកិច្ចមិនល្អ នៅតែកើតមានជាបន្តដដែល។<br><br>ផ្ទុយពីប្រភពដើម ការត្រួតពិនិត្យឡើងវិញ នៅពាក់កណ្តាលត្រីមាស បញ្ជាក់ពីទំនាក់ទំនងជាបន្តនៃការរឹតបន្តឹងយុទ្ធសាស្ត្រ **CSP** សម្រាប់ឆ្នាំ២០០៥-២០០៩ ដោយគិតលើការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព និងការកំណត់ការរួមបញ្ចូលគ្នានូវឧបសគ្គក្នុងការកាត់បន្ថយភាពក្រីក្រ។ តម្រូវការដើម្បីពង្រីកនូវប្រភពនៃកំណើន និងដើម្បីដោះស្រាយភាពក្រីក្រនៅតាមជនបទ បញ្ជាក់យ៉ាងច្បាស់ពីសារៈសំខាន់នៃការផ្តោតយ៉ាងខ្លាំងទៅលើការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ។ ឆ្លើយតបទៅនឹងតម្រូវការ និងសំណើរបស់រដ្ឋាភិបាល ដើម្បីបញ្ចប់រយៈពេល **CSP, ADB** នឹងបន្តកម្មវិធីរួមបញ្ចូលគ្នាមួយ ដែលពង្រឹងនូវការអភិវឌ្ឍវិស័យកសិកម្ម និងជនបទទៅវិញទៅមក។ នេះមានន័យថា ការផ្តោតទៅលើគម្រោងមូលធននៅតាមជនបទ ការបង្កើនលទ្ធភាពក្នុងការផ្តល់ហិរញ្ញវត្ថុនៅតាមជនបទ ការធ្វើប្រសើរឡើងនូវលទ្ធភាពទទួលបានឥណទាន និងការធ្វើវិមជ្ឈការនៃការចុះបញ្ជីពាណិជ្ជកម្ម នៅតាមតំបន់ជនបទ ការធ្វើឱ្យកសិករទទួលបានការអប់រំកាន់តែប្រសើរឡើង និងការពង្រឹងឧស្សាហកម្មនៅតាមតំបន់ជនបទ ព្រមទាំងការបន្តគម្រោងផ្តួចផ្តើមទន្លេសាប ស្តីពីការធ្វើឱ្យស្ថានភាពរស់នៅរបស់ប្រជាជនក្រីក្រ នៅតាមតំបន់ទទួលរងផលប៉ះពាល់ កាន់តែមានភាពប្រសើរឡើង។ ដើម្បីធានាថា ធនធានដែលទទួលបានពីរដ្ឋាភិបាល និងដៃគូផ្តល់ជំនួយ ត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល និងដើម្បីពន្លឿនការគាំទ្រពីដៃគូផ្តល់ជំនួយបន្ថែមទៀត **ADB** នឹងគាំទ្រដល់ការពង្រីកកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**PFM**) ដែលបានស្នើទៅកាន់ក្រសួងអភិវឌ្ឍន៍ជនបទ **MRD, MOWRAM** និង **MAFF**។ |

## ម៉ាទ្រីកសម្របសម្រួលការអភិវឌ្ឍ

| វិស័យ/ការផ្ដោតលើប្រធានបទ | យុទ្ធសាស្ត្រ/សកម្មភាពរបស់ ADB | ហានីភ័យ |
|---|---|---|
| **អភិបាលកិច្ច** | **អភិបាលកិច្ច និងសកម្មភាពប្រឆាំងអំពើពុករលួយ ៖** ADB បានអនុវត្តតួនាទីរៀបចំទុកមុនកាន់តែច្រើនឡើង នៅក្នុងការបង្កើតឱ្យមានអភិបាលកិច្ច តាមរបៀបនៃការឱ្យខ្ចី និងមិនឱ្យខ្ចីរបស់ ADB ។ ADB ផ្ដោតលើអភិបាលកិច្ចផ្ទាល់ តាមរយៈ (១) ការគាំទ្រដល់ការកែលំអការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ឱ្យកាន់តែប្រសើរឡើង (២) ការគាំទ្រដល់ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីពង្រឹងការផ្សព្វផ្សាយសេវាកម្មសាធារណៈ និងគណនេយ្យភាព (គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ (CCDP) និង CCDP ២) (៣) ការសម្របសម្រួល និងជំរុញឱ្យមានកំណែទម្រង់រដ្ឋបាលសាធារណៈតាមកម្រិតវិស័យ (ក្នុងវិស័យអប់រំ) និង (៤) ការគាំទ្រដល់កំណែទម្រង់ច្បាប់សេដ្ឋកិច្ច ដែលទាក់ទងទៅនឹងធនធានធម្មជាតិ និងការចូលជាសមាជិករបស់ WTO និងលើកកម្ពស់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិផ្អែកលើសហគមន៍ ។<br>ដោយផ្អែកលើគុណសម្បត្តិពាក់ព័ន្ធ និងការចូលរួមពីម្ចាស់ជំនួយផ្សេងៗទៀត ADB បាននឹងកំពុងគិតដោះស្រាយអំពើពុករលួយ ដោយផ្ដោតលើទិដ្ឋភាពមួយចំនួន ក្នុងចំណោមទិដ្ឋភាពតាមស្ថាប័នជាច្រើនរបស់ខ្លួន តាមរយៈ PFM និងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ ។ ប៉ុន្តែការធ្វើអន្តរាគមន៍ទាំងអស់របស់ ADB នៅក្នុងអភិបាលកិច្ច (រួមបញ្ចូលទាំងអន្តរាគមន៍ក្នុងការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចដែលមានលក្ខណៈសហប្រតិបត្តិការ និងប្រសិទ្ធភាពតាមវិស័យនៅក្នុងវិស័យជាច្រើន ដែល ADB បានធ្វើប្រតិបត្តិការជាមួយ ព្រមទាំងការរៀបចំ និងការអនុវត្តគម្រោង) មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងគណនេយ្យភាព ដែលគិតរកដំណោះស្រាយចំពោះអំពើពុករលួយគ្រប់រូបភាព ដោយផ្ទាល់ក្ដី មិនផ្ទាល់ក្ដី ។<br>នាពេលបច្ចុប្បន្ននេះ នៅគ្រប់កម្រិតទាំងអស់ ការិយាល័យអគ្គសវនករ (OAG) របស់ ADB និងអាជ្ញាធរជាតិសវនកម្ម (NAA) រួមគ្នាដឹកនាំធ្វើការចែកចាយ ទាក់ទងនឹងសវនកម្ម | **កំណែទម្រង់រដ្ឋបាលសាធារណៈ ៖** AusAID, CIDA, EC និង UNDP ឧបត្ថម្ភគាំទ្រដល់ការកសាងសមត្ថភាព សម្រាប់ក្រុមប្រឹក្សាកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ (PAR) និងគាំទ្រឱ្យមានបង្កើតស្ថាប័ន ដើម្បីផ្សព្វផ្សាយសេវាកម្មសាធារណៈ ។ ប្រទេសជប៉ុន និងសាធារណរដ្ឋកូរ៉េ និង UNDP ឧបត្ថម្ភគាំទ្រដល់ការបង្កើត ICT សម្រាប់ PAR ។<br>**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៖** AusAID, DFID, EC និងប្រទេសបារាំង IMF ប្រទេសជប៉ុន SIDA, UNDP និងធនាគារពិភពលោក រួមគ្នាគាំទ្រដល់រដ្ឋាភិបាល ដើម្បីអនុវត្តកម្មវិធីកំណែទម្រង់ PFM ។<br>**អភិបាលកិច្ចដែលមានលក្ខណៈប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ៖** AusAID, CIDA, SIDA, UNDP និង USAID គាំទ្រដល់ការការពារសិទ្ធិមនុស្ស និងការបង្កើតលទ្ធិប្រជាធិបតេយ្យ តាមរយៈអង្គការសង្គមស៊ីវិល ។<br>**កំណែទម្រង់ច្បាប់ និងតុលាការ ៖** AFD, CIDA, EC, ប្រទេសជប៉ុន GTZ និងធនាគារពិភពលោក គាំទ្រដល់កំណែទម្រង់ច្បាប់ និងតុលាការ ។ AuAID ផ្ដល់ជំនួយយុត្តិធម៌ផ្នែកព្រហ្មទណ្ឌដែលមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងក្លាទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ សម្រាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ។ ប្រទេសជប៉ុនគាំទ្រដល់សេចក្ដីព្រាងនៃក្រមព្រហ្មទណ្ឌ និងក្របនីតិវិធីព្រហ្មទណ្ឌ ។ AFD និងប្រទេសជប៉ុន ឧបត្ថម្ភដល់សាលាភូមិន្ទរដ្ឋបាល សម្រាប់បណ្ដុះបណ្ដាលចៅក្រមជាច្រើន ។ ប្រទេសហូឡង់ ផ្ដល់ជំនួយក្នុងការពង្រឹងច្បាប់ ។<br>**វិមជ្ឈការ និងវិសហមជ្ឈការ ៖** DFID, DANIDA, EC ប្រទេសជប៉ុន GTZ ប្រទេសហូឡង់ SIDA UNDP និងធនាគារពិភពលោក ជួយអនុវត្តនូវ |

| | | |
|---|---|---|
| | សម្រាប់ គម្រោងហិរញ្ញវត្ថុរបស់ ADB (គម្រោងអភិវឌ្ឍន៍ជនបទនៅភាគពាយ័ព្យ)។ | ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ។ EC និង GTZ ក៏គាំទ្រដល់ដំណើរការធ្វើវិសហមជ្ឈការផងដែរ។ UNCEF គាំទ្រដល់ការបង្កើតរចនាសម្ព័ន្ធគោលនយោបាយមួយសម្រាប់ការធ្វើវិសហមជ្ឈការសារពើពន្ធ។ |
| **កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព** | **ការដឹកជញ្ជូន និងទូរគមនាគមន៍ :** ADB បាននិងកំពុងបង្កើនលទ្ធភាពតាមរយៈការស្តារឡើងវិញនូវផ្លូវជាតិ និងផ្លូវតាមខេត្តមិនសូវសំខាន់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងតាមរយៈការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងតាមស្ថាប័នរបស់រាជាយស្ម័យានកម្ពុជា។ ADB ក៏គាំទ្រផងដែរនូវការបង្កើតគោលនយោបាយ និងទំហំនៃកំហុសឆ្គងលើបទបញ្ញត្តិរបស់ភ្នាក់ងារដឹកជញ្ជូនតាមផ្លូវគោក។ កម្មវិធីមហាអនុតំបន់របស់ ADB បន្តគាំទ្រដល់ការព្រមព្រៀងគ្នា ចំពោះការធ្វើពាណិជ្ជកម្មឆ្លងដែន និងបទបញ្ញត្តិក្នុងការដឹកជញ្ជូន។ ការថែរក្សាប្រកបដោយនិរន្តរភាពតាមរយៈកម្មវិធីទូទាំងវិស័យទាំងអស់ និងទាក់ទងទៅនឹងបរិស្ថានដែលមានបទដ្ឋាន។ កម្មវិធីរបស់ប្រទេស ក៏ផ្តល់ការគាំទ្រផ្នែកជំនួយបច្ចេកទេស ដល់ការកែទម្រង់គោលនយោបាយ ក្នុងវិស័យទូរគមនាគមន៍ ដោយអនុវត្តបន្តពីការគាំទ្រដល់ប្រទេសមហាអនុតំបន់ទន្លេមេគង្គ នៅក្នុងតំបន់នេះ។<br><br>**ថាមពល :** ADB បានផ្តោតលើការពង្រីកការបង្កើតថាមពលប្រព័ន្ធតភ្ជាប់ នៅក្នុង ប្រទេស និងចែកចាយទៅកាន់តំបន់ជនបទ និងតំបន់ក្រីក្រ។ គម្រោងនេះត្រូវបានអនុវត្ត ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹងគម្រោងវិស័យថាមពលរបស់ប្រទេស នៅតាមមហា | **ការដឹកជញ្ជូន ទូរគមនាគមន៍ និងថាមពល :** AFD, AuAID សាធារណរដ្ឋប្រជាមានិតចិន (PRC) ប្រទេសជប៉ុន មូលនិធិ OPEC សាធារណរដ្ឋកូរ៉េ ប្រទេសថៃ USAID ប្រទេសវៀតណាម និងធនាគារពិភពលោក គាំទ្រដល់ការកសាង និងស្តារឡើងវិញនូវស្ពាន និងផ្លូវថ្នល់។ ប្រទេសជប៉ុន ក៏ធ្វើការសិក្សាលើការដឹកជញ្ជូនទាំងអស់ផងដែរ។ SIDA ក៏ឧបត្ថម្ភដល់ការសិក្សាលើការស្តារផ្លូវថ្នល់ឡើងវិញដែរ។ EC, KfW, WFP និងធនាគារពិភពលោក ឧបត្ថម្ភដល់ ការងារស្តារឡើងវិញនូវផ្លូវថ្នល់ តាមជនបទ។ ការផ្គត់ផ្គង់ក្បាលរថភ្លើង និងរទេះកង់បួន (AFD និង PRC) ការផ្គត់ផ្គង់ផ្លូវដែក (ប្រទេសម៉ាឡេស៊ី) ការសិក្សាពីផ្លូវដែក (MRC, PRC និងប្រទេសជប៉ុន) ការសិក្សាអំពីផ្លូវទឹកឆ្ងាយពីតំបន់ឆ្នេរ (Belgium) និងការស្តារឡើងវិញ និងការអភិវឌ្ឍកំពង់ផែ (ប្រទេសជប៉ុន)។ AFD និងប្រទេសជប៉ុន ឧបត្ថម្ភដល់ការផ្គត់ផ្គង់ថាមពល។ PRC ប្រទេសឥណ្ឌា និងជប៉ុនឧបត្ថម្ភដល់ការបង្កើតថាមពលវារីអគ្គិសនី។ ខ្សែបណ្តាញ តភ្ជាប់ថាមពល ត្រូវបានឧបត្ថម្ភដោយ KfW, JBIC និង NDF។ ធនាគារពិភពលោកគាំទ្រដល់ការបង្កើត និងការតភ្ជាប់បណ្តាញអគ្គិសនីនៅតាមតំបន់ជនបទ។ ការអភិវឌ្ឍទូរគមនាគមន៍ ត្រូវបានឧបត្ថម្ភដោយប្រទេសជប៉ុន។ |

| | | |
|---|---|---|
| | អនុតំបន់ទន្លេមេគង្គ ដើម្បីឱ្យមានតម្លៃទាប និងកំណើនសេដ្ឋកិច្ច។ ការងារនាពេលអនាគត ត្រូវបានរៀបចំគម្រោងស្តីពីថាមពលកើតថ្មី។<br>**ប្រេង និង ឧស្ម័ន :** ADB ចូលរួមនៅក្នុងការអនុវត្តជំនួយផ្នែកបច្ចេកទេស សម្រាប់ពង្រឹងស្ថាប័នរបស់អាជ្ញាធរជាតិប្រេងកាត នៅកម្ពុជា (CNPA)។ ADB កំពុងគ្រប់គ្រងកិច្ចប្រជុំសម្របសម្រួល ដល់ដៃគូផ្តល់ជំនួយមិនផ្លូវការស្តីពីប្រេង និងឧស្ម័ន។<br>**ទេសចរណ៍ :** ADB បានផ្តោតលើការកែលំអការដឹកជញ្ជូន (ផ្លូវថ្នល់) និងការអភិវឌ្ឍទីក្រុងឱ្យកាន់តែប្រសើរឡើង នៅតាមតំបន់ទេសចរណ៍សំខាន់ៗ ដែលត្រូវបានឧបត្ថម្ភដោយ ADB ដើម្បីគាំទ្រដល់ការលើកកម្ពស់វិស័យទេសចរណ៍នៅតាមតំបន់ ព្រមជាមួយនឹងប្រទេសមហាអនុតំបន់ទន្លេមេគង្គ។ ការគាំទ្រមិនផ្ទាល់ដល់វិស័យសេដ្ឋកិច្ចទេសចរណ៍ ត្រូវបានស្នើតាមរយៈការគាំទ្រដល់វិស័យកសិកម្ម និងការអភិវឌ្ឍជនបទ។<br>**កសិកម្ម :** ADB បានផ្តោតទៅលើ (១) ការកែលំអសមត្ថភាពរបស់កសិករក្នុងការបង្កើនផលិតផលកាន់តែប្រសើរឡើង ធ្វើឱ្យផលិតផលដែលមានតម្លៃខ្ពស់ មានភាពចម្រុះ និងភ្ជាប់ទំនាក់ទំនងទៅនឹងទីផ្សារ (២) កែលំអបរិស្ថានទីផ្សារឱ្យកាន់តែមានភាពប្រសើរឡើង ដើម្បីធ្វើឱ្យមានកំណើនសហគ្រាសឯកជនផ្នែកលើកសិកម្ម និង (៣) ពង្រឹងសមត្ថភាពរបស់ស្ថាប័ន ដើម្បីធ្វើពាណិជ្ជកម្មកសិកម្មដោយមានលក្ខណៈប្រកួតប្រជែង។ ជារួមមាន ការពង្រឹងការគាំទ្រកាន់តែច្រើនឡើងដល់ក្រុមកសិករ ការគាំទ្រដល់ការផ្តល់យោបល់ និងការលើកកម្ពស់ការនាំចេញសម្រាប់សហគ្រាសផ្នែកលើកសិកម្ម បទដ្ឋានគុណភាព និងសុវត្ថិភាពសម្រាប់ផលិតផលកសិកម្ម ព័ត៌មានស្តីពីតម្លៃ និងការអនុវត្តសម្បទានដី។ ការគាំទ្រជាបន្តចំពោះការបង្កើតប្រព័ន្ធធារាសាស្ត្រសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងទឹក ឱ្យបានកាន់តែប្រសើរឡើង ដើម្បីទទួលបានទិន្នផលធម្មជាតិ និងចំណូលថេរ និងដោះស្រាយបញ្ហាសុវត្ថិភាពអាហារ។ គម្រោងផ្តួចផ្តើមបឹងទន្លេសាប (TSI) របស់ ADB គឺជាគម្រោងផ្តួចផ្តើមនៃការអភិវឌ្ឍពហុវិស័យ តាមតំបន់ជនបទ ដែលចាប់ផ្តើមពីតំបន់អាងទន្លេសាបដែលក្រខ្សត់ រហូតដល់តំបន់វាលទំនាប ទីជម្រាល និងចុងក្រោយ គឺនៅតាម | **ប្រេង និង ឧស្ម័ន :** ដៃគូផ្តល់ជំនួយផ្សេងៗទៀត មានដូចជា AusAID, UNDP, Worl Bank, IMF, Norway និងប្រទេសជប៉ុន។<br>**កសិកម្ម :** ការអភិវឌ្ឍគោលនយោបាយក្នុងវិស័យកសិកម្ម (AFD, AusAID) ការវិភាគលើវិស័យកសិកម្ម (AusAID) ផលិតផលកសិកម្ម និងការកែលំអគុណភាព (AFD, AusAID, ជប៉ុន និងធនាគារពិភពលោក) ប្រព័ន្ធធារាសាស្ត្រ (AFD, EC, FAO, IFAD, AusAID, ប្រទេសឥណ្ឌា ប៉ាគីស្ថាន កូរ៉េ ជប៉ុន និងធនាគារពិភពលោក) ការពង្រីកវិស័យកសិកម្ម ការស្រាវជ្រាវ (AusAID) ទីផ្សារកសិកម្ម (AusAID, CIDA, GTZ, UNIDO) ការអភិវឌ្ឍវិស័យកសិកម្ម នៅក្នុងតំបន់ដែលទទួលរងផលប៉ះពាល់ដោយសារមីន ការអភិវឌ្ឍការដាំដើមកៅស៊ូលើដីតូចៗ ផលិតកម្មសូត្រ និងឧស្សាហកម្មដែលទាក់ទង (AFD)។<br>ការប្រកបរបរចិញ្ចឹមជីវិតនៅតាមតំបន់ជនបទ និងការគ្រប់គ្រងធនធានធម្មជាតិ (DANIDA ប្រទេសហ្វាំងឡង់ និង DIFD) ការគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងវិស័យកសិកម្ម និងសុវត្ថិភាពអាហារ ព្រមទាំងគោល |

| | | |
|---|---|---|
| | តំបន់ជីវៈចម្រុះ។ ដោយផ្អែកទៅលើការសិក្សាតាមបែបប្រព័ន្ធ ទៅលើដី ទឹក បច្ចេកទេស ហិរញ្ញវត្ថុ និងបញ្ហាទីផ្សារ ADB នឹងសំឡឹងរកមើលឱកាសវិនិយោគបន្ថែមទៀត សម្រាប់ការអភិវឌ្ឍជនបទ។ | នយោបាយ និងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម (FAO) និងការអភិវឌ្ឍជនបទ និងកសិកម្មរួមគ្នា (EC, IFAD, ប្រទេសជប៉ុន)។ ការគ្រប់គ្រង និងរដ្ឋបាលដីធ្លី ត្រូវបានឧបត្ថម្ភដោយ AFD, DFID, EC, ប្រទេសហ្វាំងឡង់ GTZ និងធនាគារពិភពលោក។ |
| **ការអភិវឌ្ឍវិស័យឯកជន** | ADB បន្តធ្វើឱ្យប្រសើរឡើងនូវបរិយាកាសសម្រាប់អភិវឌ្ឍវិស័យឯកជនតាមរយៈការរួមបញ្ចូលគ្នានូវការវិនិយោគយ៉ាងឆាប់រហ័ស និងតាមរយៈកំណែទម្រង់គោលនយោបាយស្ថាប័ន និងបទបញ្ញត្តិ។ ធនាគារ ADB នឹងគិតដោះស្រាយពីការកកស្ទះចរាចរណ៍ ដែលជាហេដ្ឋារចនាសម្ព័ន្ធសំខាន់ (ជាពិសេសការដឹកជញ្ជូន និងថាមពល) ដែលធ្វើឱ្យកើនឡើងនូវថ្លៃធ្វើជំនួញ ការអភិវឌ្ឍធនធានមនុស្ស ដើម្បីបង្កើតកម្លាំងពលកម្មកាន់តែច្រើនឡើង និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយតម្លៃ និងបង្កើនលទ្ធភាព ដើម្បីទទួលបានហិរញ្ញវត្ថុ ព្រមទាំងបង្កើតឱ្យមានបរិស្ថានជំរុញ សម្រាប់អភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម។<br>ADB ព្យាយាមបង្កើតបរិស្ថានអំណោយផលមួយ សម្រាប់វិស័យ SME ដោយផ្តោតលើទីផ្សារប្រកបដោយប្រសិទ្ធភាព តាមរយៈការបង្កើតឱ្យមានហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម កែលំអអភិបាលកិច្ច និងកំណែទម្រង់បទបញ្ញត្តិទាក់ទងនឹងសហគ្រាសធុនតូច និងមធ្យម ឱ្យកាន់តែប្រសើរឡើង បង្កើនលទ្ធភាពរបស់សហគ្រាសធុនតូច និងមធ្យម ក្នុងការទទួលបានហិរញ្ញវត្ថុ និងគាំទ្រដល់ការកសាងសមត្ថភាព សម្រាប់សេវាកម្មអភិវឌ្ឍការធ្វើពាណិជ្ជកម្ម និងលទ្ធភាពទៅកាន់ទីផ្សារ។<br>នៅក្នុងវិស័យហិរញ្ញវត្ថុ ADB បាននិងកំពុងលើកកម្ពស់ការបង្កើតប្រព័ន្ធហិរញ្ញវត្ថុ ផ្អែកលើទីផ្សារសមស្រប តាមរយៈការបង្កើតមូលនិធិសម្រាប់ឧស្សាហកម្មធនាគារ និងការធានារ៉ាប់រង និងទីផ្សារហិរញ្ញវត្ថុ។<br>ផ្អែកលើមូលដ្ឋានគ្រឹះនៃកម្មវិធីកំណែទម្រង់គោលនយោបាយសាធារណៈ ADB កំពុងលើកកម្ពស់កិច្ចប្រតិបត្តិការរបស់វិស័យឯកជន ឱ្យកាន់តែខ្លាំងឡើង ដូចជាគម្រោងរៀបចំខ្សែតភ្ជាប់ | ការគាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន តាមរយៈការគាំទ្រដល់កំណែទម្រង់សារពើពន្ធ និងការបង្កើតប្រព័ន្ធធនាគារ (IMF) ការផ្តល់ជំនួយដល់វិទ្យាស្ថានមីក្រូហិរញ្ញវត្ថុ (AFD) គោលការណ៍ឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម តាមរយៈធនាគារពាណិជ្ជកម្ម (GTZ និង USAID) ការបង្កើតសហគមន៍ពាណិជ្ជកម្ម (មូលនិធិអាស៊ី) ការស្តារឡើងវិញ នឹងលើកមកបង្ហាញពីការគ្រប់គ្រងវិស័យឯកជន-សាធារណៈនៃទីផ្សារនៅតាមទីក្រុង (AFD) ការសិក្សាលើការអភិវឌ្ឍតាមតំបន់នៃច្រករីកចម្រើនភ្នំពេញ-ក្រុងព្រះសីហនុ ការសិក្សាលើគោលនយោបាយសេដ្ឋកិច្ច និងការអភិវឌ្ឍកំពង់ផែក្រុងព្រះសីហនុ (ប្រទេសជប៉ុន) ការសម្របសម្រួលវេទិកាវិស័យឯកជន និងការគាំទ្រដល់សហគ្រាសធុនតូច (GTZ, IFC, ប្រទេសជប៉ុន MPDF, USAID, UNIDO) គម្រោងលើវិស័យវាយនភ័ណ្ឌ និងដំណោះស្រាយជម្លោះលើកម្លាំងពលកម្ម (ILO, USAID)។ ការឈានទៅកាន់ WTO (AuAID, EC, GTZ UNRSCAP, USAID) ការលើកកម្ពស់ពាណិជ្ជកម្ម និងការអភិវឌ្ឍវិស័យនាំចេញ (ICT ធនាគារពិភពលោក) ការសម្របសម្រួលផ្នែកពាណិជ្ជកម្ម (ប្រទេសជប៉ុន ធនាគារពិភពលោក) និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំង ការអភិវឌ្ឍសហគ្រាស (ប្រទេសឥណ្ឌា និងជប៉ុន)។ |

| | | |
|---|---|---|
| | ថាមពលរបស់ប្រទេសកម្ពុជា ដែលត្រូវបានយល់ព្រមនៅខែមិថុនា ឆ្នាំ២០០៧។ | |
| **ការអភិវឌ្ឍសង្គមរួម** | ការប្រកបរបរចិញ្ចឹមជីវិត កាន់តែប្រសើរឡើង និងការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការបង្កើនលទ្ធភាពរបស់ប្រជាជនក្រីក្រ ឱ្យទទួលបាននូវទ្រព្យសកម្ម (ទាំងទ្រព្យសកម្មជាក់ស្តែង ទាំងទ្រព្យសកម្មធម្មជាតិ) និងធនធានមនុស្ស។ ការគាំទ្រពិសេស មានទៅលើការអប់រំ ការផ្តល់សិទ្ធិអំណាចដល់ក្រុមមនុស្សដែលងាយរងគ្រោះ ដូចជា ស្ត្រី និងក្រុមជនជាតិភាគតិចជាដើម ការគ្រប់គ្រងជំងឺឆ្លង ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅតាមតំបន់ជនបទ។<br>**ការអប់រំ :** ADB បានផ្តោតលើ (១) ការគាំទ្រដល់ការអនុវត្តកំណែទម្រង់គោលនយោបាយ ដែលផ្តល់ឱកាសកាន់តែទូលំទូលាយដល់ប្រជាជនក្រីក្រ ឱ្យបានចូលរៀននៅសាលាបឋមសិក្សា មធ្យមសិក្សា និងក្រោយមធ្យមសិក្សា (២) ជួយសម្រួលដល់លទ្ធភាពក្នុងការឈានទៅកាន់ការអប់រំនៅកម្រិតមធ្យមសិក្សា តាមរយៈកម្មវិធីវិនិយោគចំគោលដៅ សម្រាប់បង្កើតឱ្យមានភាពងាយស្រួល (៣) ពង្រឹងកិច្ចខិតខំប្រឹងប្រែងឱ្យមានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ វិមជ្ឈការតាមរយៈមជ្ឈមណ្ឌលសិក្សារយៈវែងនៅតាមសហគមន៍ និងលើកទឹកចិត្តឱ្យមានភាពជាដៃគូ រវាងវិស័យសាធារណៈ-ឯកជន (៤) ផ្តល់កម្មវិធីលើកទឹកចិត្តក្នុងការអប់រំឱ្យចំគោលដៅ និងទូលំទូលាយដល់ប្រជាជនក្រីក្រ ដោយផ្តោតជាសំខាន់ទៅលើក្មេងស្រី និងជនជាតិភាគតិច (៥) ផ្តល់ការគាំទ្រដល់ការកសាងសមត្ថភាព សម្រាប់ការអប់រំតាមវិមជ្ឈការ ជាពិសេសនៅកម្រិតក្រោយមូលដ្ឋាន និងការអប់រំក្រៅប្រព័ន្ធ ក្រោមកម្មវិធីអភិវឌ្ឍវិស័យអប់រំបន្ត លើកទី២។ ADB ក៏បន្តគាំទ្រដល់គម្រោងរបស់ទីក្រុងភ្នំពេញ ដែលផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីជាន់ខ្ពស់របស់ GMS។ ADB នឹងផ្តោតកាន់តែខ្លាំងឡើងលើគម្រោងបង្កើនគុណភាពអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញផ្នែកបច្ចេកទេស។<br>**ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ :** ADB បានផ្តោតលើការធានាឱ្យមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ បង្កើតសេចក្តីណែនាំសម្រាប់ប្រតិបត្តិក្នុងការផ្គត់ផ្គត់ទឹកស្អាត និងអនាម័យ ការកៀងគរ និងការយល់ដឹងរបស់សហគមន៍ស្តីពីផលប៉ះពាល់ | **ការអប់រំ :** រចនាសម្ព័ន្ធនិយ័តកម្ម និងកំណែទម្រង់គោលនយោបាយ (UNICEF/Sida)។ ការបង្កើតឱ្យមានភាពងាយស្រួល (Belgium, JICA, ធនាគារពិភពលោក)។ ការបណ្តុះបណ្តាល និងការអភិវឌ្ឍគ្រូបង្រៀន (JICA, UNICEF/Sida USAID ធនាគារពិភពលោក)។ ការបង្កើតកម្មវិធីបង្រៀន និងសៀវភៅសិក្សា (JICA, USAID)។ ការផ្តល់សៀវភៅសិក្សា (JICA)។ ការអភិវឌ្ឍស្ថាប័ន និងសមត្ថភាព (EC, UNICEF/Sida, UNISCO, ធនាគារពិភពលោក)។ ការអប់រំក្រៅប្រព័ន្ធ និងបំណិនជីវិត (DFID, EC, UNESCO, UNFPA, UNICEF/Sida)។ កម្មវិធីអាហារូបករណ៍ និងការផ្តល់អាហារ នៅតាមសាលារៀន (Belgium, WFP)។ ការគ្រប់គ្រង ICT និងព័ត៌មានស្តីពីការអប់រំ ( Belgium, UNICEF/Sida, UNESCO)។ ការឧបត្ថម្ភថវិកា (EC)។ ការអប់រំកម្រិតខ្ពស់ (AUF, EC, JICA, ធនាគារ ពិភពលោក)<br>ការផ្គង់ផ្គង់ទឹកស្អាត និងអនាម័យ ត្រូវបានឧបត្ថម្ភដោយ UNICEF, WB, JICA ។ ការត្រួតពិនិត្យឡើងវិញលើការវិភាគ (DFID)។<br>ម្ចាស់ជំនួយក៏បានឧបត្ថម្ភដល់សុខភាព និងអាហារូបត្ថម្ភ (CIDA, |

| | | |
|---|---|---|
| | របស់ទឹក និងអនាម័យ មកលើសុខភាពសាធារណៈ។ គម្រោងផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទបឹងទន្លេសាប នឹងត្រូវអនុវត្តតាមរយៈការវិនិយោគកាន់តែច្រើនឡើង។<br>**សុខភាព :** ADB បានផ្លាស់ប្តូរចំណាប់អារម្មណ៍ទៅគាំទ្រលើវិស័យសុខភាពសាធារណៈដោយផ្ទាល់ និងគម្រោងផ្តួចផ្តើមការគ្រប់គ្រងជំងឺឆ្លង នៅក្នុងមហាអនុតំបន់ទន្លេមេគង្គវិញ។ | UNICEF, WFP) ទឹកបរិភោគមានសុវត្ថិភាព និងអនាម័យ (EC) និងការផ្គត់ផ្គង់ទឹកនៅទីក្រុង (ប្រទេសជប៉ុន ធនាគារពិភពលោក)។ ប្រទេសជប៉ុន UNICEF និង WHO ឧបត្ថម្ភដល់កម្មវិធីធ្វើឱ្យមានភាពស៊ាំទៅនឹងមេរោគ។ ម្ចាស់ជំនួយក៏បានឧបត្ថម្ភដល់ការប្រយុទ្ធប្រឆាំងនឹងជំងឺរបេង (ប្រទេសជប៉ុន និង WHO) ការគ្រប់គ្រងឱសថ (CIDA, UNCDP) ការធានារ៉ាប់រងលើសុខភាព (GTZ) និងគោលនយោបាយចំនួនប្រជាជន (UNFPA)។ |
| **ការទ្រទ្រង់បរិស្ថាន** | ការគាំទ្របរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ មានគោលបំណងលើកកម្ពស់ការប្រកបរបរចិញ្ចឹមជីវិតនៅតាមជនបទ និងធ្វើឱ្យប្រាក់ចំណូលនៅតាមជនបទ មានភាពប្រសើរឡើង ដោយសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ប្រព័ន្ធគ្រប់គ្រងផ្អែកលើសហគមន៍ និងការកសាងសមត្ថភាពរបស់ស្ថាប័នក្នុងតំបន់ នឹងត្រូវបានលើកកម្ពស់។ ទោះបីមានការផ្តោតចំណាប់អារម្មណ៍ទៅលើអាងទន្លេមេគង្គក៏ដោយ ក៏ការទ្រទ្រង់បរិស្ថាន នឹងត្រូវបានផ្តោតការយកចិត្តទុកដាក់ តាមរយៈគម្រោងគ្រប់គ្រងបរិស្ថានទន្លេសាប គម្រោងប្រកបរបរចិញ្ចឹមជីវិតនៅតាមទន្លេសាបប្រកបដោយនិរន្តរភាព ព្រមទាំងគម្រោងទាក់ទងទៅនឹងច្រកផ្លូវទឹក និងជីវៈចម្រុះ នាថ្ងៃអនាគត។ | CIDA ឧបត្ថម្ភដល់ការកសាងសមត្ថភាពសម្រាប់គ្រប់គ្រងសកម្មភាពកំចាត់មីន។ ប្រទេសជប៉ុន SIDA និង UNDP ឧបត្ថម្ភដល់ការបោសសម្អាតមីន។ DANIDA ឧបត្ថម្ភដល់ការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថាននៅតំបន់ឆ្នេរ។ ការប្រកបរបរចិញ្ចឹមជីវិតនៅតាមជនបទ (DFID) ការគ្រប់គ្រងសម្បទានព្រៃឈើ និងការការពារបរិស្ថាន (ធនាគារបរិស្ថាន)។ អ្នកផ្តល់ជំនួយផ្សេងៗទៀត បានចូលរួមនៅក្នុង : ការអភិរក្សជីវៈចម្រុះរួមបញ្ចូលគ្នា ការគ្រប់គ្រង និងការអភិរក្សព្រៃឈើ (EC)។ ការគ្រប់គ្រងធនធានធម្មជាតិ (FAO) ការប្រកបរបរចិញ្ចឹមជីវិតនៅតាមទន្លេសាបប្រកបដោយនិរន្តរភាព (ប្រទេសហ្វាំងឡង់) ការគ្រប់គ្រង និងការតាមដានព្រៃឈើ ការគ្រប់គ្រងបរិស្ថាននៅតាមទន្លេ (UNDP-GEF) និងធនធានបម្រុងទុក ជីវៈចម្រុះទន្លេសាប (UNESCO) ការគ្រប់គ្រងព្រៃឈើ និងធនធានបរិស្ថាន (ប្រទេសជប៉ុន និង GTZ) ព្រមទាំងប្រព័ន្ធធារាសាស្ត្រ ការការពារទឹកជំនន់ និងប្រព័ន្ធលូបង្ហូរទឹកស្អុយ ការកសាងសមត្ថភាព សម្រាប់វិស័យព្រៃឈើ (ប្រទេសជប៉ុន)។ |
| **យេនឌ័រ និងការអភិវឌ្ឍ** | យុទ្ធសាស្ត្រវិស័យយេនឌ័ររបស់ ADB នឹងបន្តផ្តោតការយកចិត្តទុកដាក់លើការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងកាត់បន្ថយគម្លាតយេនឌ័រតាមរយៈការពិភាក្សា និងសកម្មភាពគោលនយោបាយ | ម្ចាស់ជំនួយកំពុងឧបត្ថម្ភដល់ការរៀបចំ និង/ឬការអនុវត្តយុទ្ធសាស្ត្រយេនឌ័រ និងផែនការសកម្មភាព នៅក្នុងក្រសួងសំខាន់ៗ (UNDP, UNDPA, |

| | | |
|---|---|---|
| | ដើម្បីជំរុញឱ្យស្ត្រីចូលរួមកាន់តែច្រើនឡើងនៅក្នុងគម្រោង និងកម្មវិធីរបស់ ADB នៅក្នុងដំណាក់កាលធ្វើផែនការអនុវត្ត និងតាមដាន។ កាន់តែពិសេសជាងនេះទៀត ADB នឹង (១) ចូលរួមចំណែកធ្វើឱ្យមានសមភាព និងការផ្តល់សិទ្ធិអំណាចយេនឌ័រតាមរយៈការអនុវត្តផែនការសកម្មភាពយេនឌ័រ/ការបញ្ជ្រាបយេនឌ័រ នៅក្នុងវិស័យអប់រំ កសិកម្ម អភិវឌ្ឍន៍ជនបទ ការគ្រប់គ្រងធនធានទឹក ទឹកនិងអនាម័យ វិសហមជ្ឈការ ផ្លូវតាមខេត្ត និងគម្រោងបង្កើតសហគ្រាសធុនតូចនិងមធ្យម (២) កសាងសមត្ថភាពដល់បុគ្គលិកគម្រោង និងដៃគូផ្សេងៗទៀត នៅក្នុងគោលនយោបាយដែលងាយនឹងប៉ះពាល់ដល់យេនឌ័រ និងការរៀបចំផែនការកម្មវិធី (៣) បង្កើតឱ្យមានយន្តការតាមដានលំអិត ដើម្បីតាមដាន និងធ្វើរបាយការណ៍ស្តីពីជោគជ័យទាក់ទងនឹងយេនឌ័រ (៤) រៀបចំឯកសារស្តីពីការអនុវត្តដែលប្រសើរជាងគេ ទាក់ទងនឹងការបញ្ជ្រាបយេនឌ័រ (៥) ពង្រឹងសមត្ថភាពក្នុងការវិភាគគោលនយោបាយ និងការតស៊ូមតិរបស់ក្រសួងកិច្ចការនារី ក្នុងការអនុវត្ត និងតាមដានការបញ្ជ្រាបយេនឌ័រ ទៅក្នុងផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ (NSDP) ឆ្នាំ២០០៦-២០១០ (៦) ជំរុញឱ្យមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការតាមតំបន់ជាមួយប្រទេសមហាអនុតំបន់ទន្លេមេគង្គផ្សេងៗទៀត ជាពិសេស នៅក្នុងតំបន់ដែលមានការជួញដូរមនុស្ស ការធ្វើចំណាកស្រុក និងការគ្រប់គ្រងជំងឺឆ្លងឆ្លងកាត់ព្រំដែន និង (៧) ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងម្ចាស់ជំនួយផ្សេងៗទៀត ដើម្បីធ្វើបច្ចុប្បន្នភាពលើការវាយតម្លៃយេនឌ័រនៅក្នុងប្រទេស។ | WB, UNIFEM) គាំទ្រដល់ការបង្កើតកម្មវិធីបង្កើតថវិកា ដើម្បីឆ្លើយតបទៅនឹងយេនឌ័រ (UNDP) តាមដាន និងគាំទ្រដល់ការអនុវត្ត NSDP រួមទាំងការគាំទ្រដល់ការការបញ្ជ្រាបយេនឌ័រនៅក្នុងវិមជ្ឈការ និងវិសហមជ្ឈការ (UNDP, UNFPA, PSDD, JICA) ជំរុញ និងគាំទ្រឱ្យស្ត្រីចូលរួមបានកាន់តែច្រើន (UNDP, UNFPA, UNIFEM) ជំរុញ និងគាំទ្រឱ្យមានការបង្កើតសហគ្រាសធុនតូច តូចល្មម និងធម្យមសម្រាប់ស្ត្រី (MSME) និងសកម្មភាពបង្កើតប្រាក់ចំណូល (UNDP, GTZ, FAO, USAID, ILO, ស្ថានទូតជប៉ុន) គាំទ្រ និងតាមដានដល់ការអនុវត្តផែនការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ (UNIFEM, UNFPA, GTZ) គាំទ្រដល់ការកែតម្រូវ ការអនុម័ត និងការអនុវត្តច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ (GTZ/CIM, UNICEF, USAID, IOM) |
| **កិច្ចសហប្រតិបត្តិការតាមតំបន់** | ADB បានវិនិយោគលើការភ្ជាប់ទំនាក់ទំនងលើការដឹកជញ្ជូន ការតភ្ជាប់បណ្តាញអគ្គិសនី វិស័យទេសចរណ៍ និងទូរគមនាគមន៍ក្នុងតំបន់ ជាមួយប្រទេសមហាអនុតំបន់ទន្លេមេគង្គ ប្តូរការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការគ្រប់គ្រងជំងឺឆ្លង ជីវតន្ទនៈ ជីវៈចម្រុះ ការគ្រប់គ្រង និងការកាត់បន្ថយទឹកជំនន់ ព្រមទាំងពាណិជ្ជកម្ម និងភស្តុភារ។ ភាពកំសោយសមត្ថភាពរបស់ស្ថាប័នត្រូវបានគិតគូរដោះស្រាយផងដែរ ដើម្បីធានានូវនិរន្តរភាពនៃអត្ថប្រយោជន៍របស់គម្រោង។ | ម្ចាស់ជំនួយ បាននឹងកំពុងជំរុញ និងគាំទ្រដល់ការអនុម័ត និងអនុវត្តគោលនយោបាយចំណាកស្រុកឆ្លើយតបទៅនឹងយេនឌ័រ និងការរៀបចំអនុសាសន៍ខាងផ្លូវច្បាប់ពាក់ព័ន្ធនានា (IOM, GTZ/CIM, UNIFEM) ជំរុញ និងគាំទ្រដល់ការអភិវឌ្ឍការយល់ពីច្បាប់ និងចំណេះដឹងខាងផ្លូវច្បាប់ ស្តីពីសិទ្ធិរបស់ស្ត្រី (UNIFEM, GTZ/ CIM) គាំទ្រ សម្របសម្រួល និងតាមដានការរស់នៅក្នុងគ្រួសារប្រកបដោយសុខភាពល្អ តាមរយៈផែនការទប់ស្កាត់ (សុខភាពបន្តពូជ អាហារូបត្ថម្ភ មេរោគអេដស៍-ជំងឺអេដស៍របស់ស្ត្រី) (UNFPA, UNICEF, |

| | | |
|---|---|---|
៦. ផលបត្រ័ (Portfolio) និងជំនួយឥតសំណងសរុប បានកើនឡើងរហូតដល់២១,៨លានដុល្លា (១០,៧ភាគរយ) បើប្រៀបធៀបទៅនឹងកម្រិត ដែលបានកំណត់នៅពេលធ្វើសេចក្តីសម្រេចនៃ COBP នេះ កាលពីខែធ្នូ ឆ្នាំ២០០៦ ប៉ុន្តែការកើនឡើងនេះ មានចំនួនច្រើន ដោយសារតែជំនួយ GMS បន្ថែមដែលមានទឹកប្រាក់ចំនួន២០លានដុល្លា ក្នុងឆ្នាំ២០០៩[5] ។ ការផ្លាស់ប្តូរសំខាន់៧ចំពោះផែនការនេះ មាន៤សំខាន់ៗ ចាប់តាំងពីពេលដែល COBP ត្រូវបានឯកភាពនៅខែធ្នូ ឆ្នាំ២០០៦។ ទី១ គម្រោងថ្មី៧ចំនួន៣ ត្រូវបានផ្តល់មូលនិធិ ដូចជា : គម្រោងគ្រប់គ្រងផ្លូវថ្នល់ (ADB បានបែងចែកទឹកប្រាក់ចំនួន៦លានដុល្លា ជាមួយសហហិរញ្ញប្បទាន ចំនួន៣៨ដុល្លា ពីធនាគារពិភពលោក និងរដ្ឋាភិបាលអូស្ត្រាលី) គម្រោងប្រកបរបរចិញ្ចឹមជីវិត នៅខេត្តសៀមរាប (៥លានដុល្លា) និងគម្រោងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គម្រោងអភិវឌ្ឍជនបទ (១១,៨លានដុល្លា។ ទី២ គម្រោង GMS គម្រោងកែលម្អផ្លូវថ្នល់នៅតាមបណ្តាខេត្តភាគពាយ័ព្យ នៃប្រទេសកម្ពុជា (២០លានដុល្លា) បាននឹងកំពុងស្នើសុំ អាស្រ័យទៅតាមមូលនិធិដែលមាន។ ទី៣ ការបែងចែកទឹកប្រាក់ ចំនួន២០លានដុល្លាដែលបានស្នើសុំសម្រាប់ការគ្រប់គ្រងធនធានទឹក (វិស័យ) បាននឹងកំពុងកាត់បន្ថយទឹកប្រាក់ ចំនួន១៥លានដុល្លា ដូចដៃគូអភិវឌ្ឍដទៃទៀត ដូចជា ទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍ (AFD) និងមូលនិធិ OPEC សម្រាប់ការអភិវឌ្ឍអន្តរជាតិ (OFID) បានយល់ព្រមទៅលើគម្រោងហិរញ្ញប្បទាន។ ទី៤ គម្រោង ច្រកសមុទ្រភាគខាងត្បូង GMS ត្រូវបានកាត់បន្ថយទឹកប្រាក់ពីចំនួន១៣លានដុល្លា មកនៅត្រឹម៧លានដុល្លា ដើម្បីផ្តល់មូលនិធិ សម្រាប់គម្រោងគ្រប់គ្រងផ្លូវថ្នល់។ ថវិកាជំនួយបច្ចេកទេសប្រហាក់ប្រហែលសរុប មានចំនួន១៣,៩លានដុល្លា សម្រាប់ឆ្នាំ២០០៧- ២០០៩ គឺកើនឡើងចំនួន២,៣លានដុល្លា (១៩,៨ភាគរយ) ខ្ពស់ជាងអ្វីដែលបានព្រមព្រៀងនៅខែធ្នូ ឆ្នាំ២០០៦ ដែលឆ្លុះបញ្ចាំង ឱ្យឃើញពីការកើនឡើងនូវចំនួនដែលបានស្នើឡើងនៅក្នុងកម្មវិធីមិនមែនកម្ចី ដែលបានស្នើឡើងនៅអំឡុងពេលដែល CPS ដែលនៅសេសសល់សម្រាប់ឆ្នាំ២០០៧-២០០៩។ គម្រោងជំនួយបច្ចេកទេសមិនមែនកម្ចីថ្មីមានចំនួន៦ ដែលក្នុងនោះមានគម្រោង ចំនួន៣ ត្រូវធ្លាក់ទៅលើកម្មវិធី GMS ដែលបានប្តូរទិសដៅ។

**ឃ. តម្រូវការធនធានផ្ទៃក្នុង**

៧. ធនធានបុគ្គលិកជំនាញខាងក្នុងដែលត្រូវការសំរាប់កម្មវិធីកម្ពុជា ឆ្នាំ២០០៨ ត្រូវបានរំពឹងថា នឹងមានចំនួនសរុប១៤-១៥នាក់ ក្នុងរយៈពេលគម្រោង។ លើសពីនេះទៀត ដើម្បីពង្រឹងជំនាញដែលបានកំណត់ដើម្បីបំពេញលើការផ្តោតទៅលើវិស័យឯកជនដែល បានកើនឡើង ក្នុងការធានាឱ្យនូវការបែងចែកកម្មវិធីប្រតិបត្តិឱ្យបានទាន់ពេលវេលា ក្រោមផែនការអាជីវកម្មដែលបានស្នើឡើង ក្នុងនោះ មុខតំណែងថ្មីទាំង៥ដែលត្រូវការរួមមាន : (១) មន្ត្រីអនុវត្តគម្រោង (កសិកម្ម និងធនធានធម្មជាតិ)

---

4 គម្រោងបណ្តាញតភ្ជាប់ថាមពលនៅប្រទេសកម្ពុជា ដោយនាយកដ្ឋានប្រតិបត្តិការវិស័យឯកជន (PSOD) និងប្រតិបត្តិការវិស័យឯកជនដំបូងគេបង្អស់របស់ ADB នៅប្រទេសកម្ពុជា ត្រូវបានឯកភាពនៅខែមិថុនា ឆ្នាំ២០០៧ ស្តីពីមូលដ្ឋានមិនពឹងផ្អែក។

5 ទឹកប្រាក់១,៨លានដុល្លា តំណាងឱ្យការកែតម្រូវចំពោះការបែងចែកពីរដងក្នុងឆ្នាំ២០០៧/២០០៨ អាស្រ័យទៅតាមជំនួយឥតសំណង ADF/IDA ។

(២) អ្នកជំនាញ ខាងការអភិវឌ្ឍជនបទ ចេញពីបុគ្គលិកជំនាញទីស្នាក់ការ ADB (៣) មន្ត្រីទំនាក់ទំនងផ្នែកខាងក្រៅ (៤) ជំនួយការបច្ចេកវិទ្យា ព័ត៌មាន និង (៥) ជំនួយការរដ្ឋបាល។ មុខតំណែងចំនួន២ដំបូង ឆ្លុះបញ្ចាំងឱ្យឃើញពីការផ្តោតលើកម្មវិធីត្រួសៗស្តីពីកសិកម្ម និងការអភិវឌ្ឍជនបទ និងការគ្រប់គ្រងហានិភ័យដែលចេះតែកើនឡើង។ បេសកកម្មប្រចាំប្រទេសមានបំណងបង្កើតកម្មវិធីរួម មួយបញ្ចូលស្តីពីកសិកម្ម និងការអភិវឌ្ឍជនបទ និងរំពឹងទុកថា រដ្ឋបាលមានគម្រោងជាច្រើនទៀត នឹងត្រូវផ្ទេរចេញពីផ្នែកធនធានកសិកម្ម បរិស្ថាន និងធនធានធម្មជាតិ នៃនាយកដ្ឋានអាស៊ីអាគ្នេយ៍ នៅទីបញ្ជាការទៅកាន់បេសកកម្មប្រចាំប្រទេស។ មុខតំណែងមន្ត្រីទំនាក់ទំនងបរទេសខាងក្រៅ មានភាពចាំបាច់ដើម្បីគាំទ្របេសកកម្មប្រចាំប្រទេស ក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការយល់ពីប្រតិបត្តិការរបស់ខ្លួននៅប្រទេសកម្ពុជា។គាត់/នាងនឹងផ្តោតទៅលើប្រព័ន្ធផ្សព្វផ្សាយទទួលខុសត្រូវ ការរៀបចំសន្និសីទតាមទូរស័ព្ទ វីដេអូ ប្រព័ន្ធរដ្ឋបាល ថែរក្សាសំភារៈ កុំព្យូទ័រ ការបញ្ចុះបញ្ចូលបុគ្គលិក IT ប្រព័ន្ធបណ្ណសារ និងយុទ្ធសាស្ត្រផ្នែក្រៅ ព្រមទាំងសកម្មភាពទំនាក់ទំនង គោលនយោបាយសាធារណៈ។ តម្រូវការសម្រាប់សកម្មភាពនេះត្រូវបានគាំទ្រ តាមរយៈទាំងការប្រជុំប្រចាំឆ្នាំនៃបេសកកម្មប្រចាំប្រទេសក្នុង ឆ្នាំ២០០៧ និងតាមរយៈបេសកកម្មចំពោះ ប្រទេសកម្ពុជាឆ្នាំ២០០៧ ដើម្បីពិនិត្យឡើងវិញរំលឹកឡើងវិញនូវ តម្រូវការទំនាក់ទំនងផ្នែកខាងក្រៅ បេសកកម្ម ប្រចាំប្រទេស អន្តរជាតិ។ ជំនួយការបច្ចេកវិទ្យាព័ត៌មាន នឹងដើរតួជា អ្នកសម្របសម្រួលខាងបច្ចេកវិទ្យាព័ត៌មាន និងផ្តល់នូវការគាំទ្រផ្នែក ភស្តុភារដល់បេសកកម្មចំពោះប្រទេសកម្ពុជា។ គាត់/នាង នឹងត្រូវទទួលខុសត្រូវទៅលើ ការធ្វើសិក្ខាសាលាតាមទូរស័ព្ទ និងតាម វីដេអូ ការថែទាំនិងរដ្ឋបាលប្រព័ន្ធ ការថែទាំ ហាដវែរ៍(Hardware) និងការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មានដល់បុគ្គលិក។ ការគាំទ្រផ្នែក IT ដែលបានលើកឡើងនេះ នឹងទ្រទ្រង់ដល់ការបង្កើត និងថែទាំប្រព័ន្ធទុកដាក់ឯកសារដែល នឹងត្រូវដាក់ចេញឱ្យប្រើប្រាស់ជាផ្លូវការជាបន្តបន្ទាប់នៅទូទាំងនាយកដ្ឋានថ្នាក់តំបន់ អាស៊ីអាគ្នេយ៍ និងបេសកកម្មប្រចាំប្រទេសរបស់ខ្លួននៅឆ្នាំ ២០០៧ និង ២០០៨។ ជំនួយរដ្ឋបាលបន្ថែម ក៏ត្រូវការ ដើម្បីគាំទ្រដល់ការកើនឡើងនូវចំនួនបុគ្គលិកជំនាញ និងមន្ត្រី ថ្នាក់ជាតិ។

**ង. ការត្រួតពិនិត្យតាមដានផ្អែកលើលទ្ធផល**

៨. ភាពរីកចម្រើនទៅលើលទ្ធផលតាមវិស័យ ត្រូវបានត្រួតពិនិត្យតាមដាននៅក្នុងការរំលឹកឡើងវិញរយៈពេលខ្លីនេះ ដែល ផ្ទុយទៅនឹងសូចនាករក្នុងក្របខ័ណ្ឌលទ្ធផល[6]។ ផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យតាមដាននេះ ការកែសម្រួលត្រូវបានធ្វើឡើង សម្រាប់ឆ្នាំ ២០០៧-២០០៩ និងក្នុងតម្រូវការនាពេលអនាគត ដើម្បីដោះស្រាយនូវហានិភ័យអភិបាលកិច្ច និងអំពើពុករលួយ។ការកែតម្រូវចំពោះក្របខ័ណ្ឌលទ្ធផលនេះត្រូវបានលើកឡើងយ៉ាងច្បាស់នៅក្នុងក្របខ័ណ្ឌលទ្ធផល។

---

[6] ដោយផ្អែកទៅលើក្របខ័ណ្ឌលទ្ធផល ២០០៦-២០១០ ដែលមានលើកឡើងនៅក្នុងផែនការអាជីវកម្មប្រតិបត្តិការប្រចាំប្រទេស២០០៧-២០០៩ ដែលត្រូវបានរៀបចំសម្រាប់ប្រទេសកម្ពុជានៅខែធ្នូ ឆ្នាំ២០០៦។

## សកម្មភាព និងស្ថានភាពអនុវត្តផលប័ត្រ

### តារាងក៧.១ : សូចនាករ ផលប័ត្រ(Portfolio)-ចំនួនផលប័ត្រ និងការចាត់ថ្នាក់

( កម្ចីវិស័យសាធារណៈ នៅថ្ងៃទី៣១ មីនា ឆ្នាំ២០០៧)

| | | | | | ការចាត់ថ្នាក់[ក] | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ខ្ពស់ | | គួរសម | | | | | | សក្តានុពល | | | |
| | ប្រាក់កម្ចីសរុប | | សរុប | | ពេញចិត្ត | | ពេញចិត្ត | | ពេញចិត្ត | | មិនពេញចិត្ត | | បញ្ហា[ខ] | | ហានិភ័យ[គ] | |
| វិស័យ | លានដុល្លា | % | No. | % | No. | % | No. | % | No. | % | No. | % | No. | % | No. | (%) |
| កសិកម្ម និងធនធានធម្មជាតិ | ៦២,៨២ | ១៣,២៤ | ៤ | ១៩,០៥ | 0 | 0,00 | ៤ | ១00,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| ការអប់រំ | ៦៥,៤៣ | ១៣,៧៩ | ៣ | ១៤,២៩ | 0 | 0,00 | ៣ | ១00,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| ថាមពល | ៨៨,៤៤ | ១៨,៦៤ | ៣ | ១៤,២៩ | 0 | 0,00 | ៣ | ១00,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| ហិរញ្ញវត្ថុ | ១០,២១ | ២,១៥ | ១ | ៤,៧៦ | 0 | 0,00 | ១ | ១00,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| សុខភាព អាហារូបត្ថម្ភ និងការការពារសង្គម | ២២,៦៤ | ៤,៧៧ | ១ | ៤,៧៦ | 0 | 0,00 | ១ | ១00,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| ឧស្សាហកម្ម និងពាណិជ្ជកម្ម | ៣៧,៦៨ | ៧,៩៤ | ២ | ៩,៥២ | 0 | 0,00 | ១ | ៥0,00 | ១ | ៥0,00 | 0 | 0,00 | 0 | 0,00 | ១ | ៥0,00 |
| ច្បាប់ ការគ្រប់គ្រងសេដ្ឋកិច្ច និងគោលនយោបាយសាធារណៈ | ១១,១៨ | ២.៣៦ | ១ | ៤,៧៦ | 0 | 0,00 | ១ | ១00,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| ការដឹកជញ្ជូន និងគមនាគមន៍ | ៩៩,៥៣ | ២០.៩៧ | ២ | ៩,៥២ | 0 | 0,00 | ១ | ៥0,00 | ១ | ៥0,00 | 0 | 0.00 | 0 | 0,00 | ១ | ៥0,00 |
| ការផ្គត់ផ្គង់ទឹក អនាម័យ និងការគ្រប់គ្រងកាកសំណល់ | ២៧,៦៧ | ៥.៨៣ | ២ | ៩,៥២ | 0 | 0,00 | ២ | ១00,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វិស័យចំរុះ | | ៤៨.៩៤ | ១០,៣១ | ២ | ៩,៥២ | 0 | 0,00 | ២ | ១០០,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| | **សរុប** | **៤៧៤,៩៤** | **១០០,00** | **២១** | **១០០,00** | 0 | 0,00 | **១៩** | **៩០,៤៨** | **២** | **៩,៥២** | 0 | 0,00 | 0 | 0,00 | **២** | **៩,៥២** |

No. = ចំនួន

[ក] ការចាត់ថ្នាក់មួយសម្រាប់ភាពរីកចំរើននៃការអនុវត្ត និងគោលបំណងនៃការការអភិវឌ្ឍ គឺផ្អែកលើការចាត់ថ្នាក់ដែលទាបជាងនិមួយៗ

[ខ] ប្រាក់កម្ចីដែលចោទជាបញ្ហាសក្តានុពល គឺកម្ចីដែលមានការពេញចិត្ត ប៉ុន្តែកម្ចីនេះមានកត្តាហានិភ័យ៤ ឬច្រើនជាងនេះ ដែលទាក់ទងផ្អែកខ្លះទៅនឹងការអនុវត្តដោយពេញចិត្ត និងមិនពេញចិត្ត

[គ] កម្ចីនឹង "ជួបប្រទះនូវហានិភ័យ" ប្រសិនបើកម្ចីជាបញ្ហាពេកចិត្ត មិនពេញចិត្ត ឬបញ្ហាសក្តានុពល

ប្រភព ធនាគារអភិវឌ្ឍន៍អាស៊ី គម្រោងផ្អែកសម្របសម្រួល និងលទ្ធកម្ម

## តារាង៧.២ ៧ សូចនាករផលប័ត្រ(Portfolio) - ការបើកប្រាក់ចំណាយ និងការផ្ទេរធនធានសរុប

( កម្ចីវិស័យសាធារណៈ គិតត្រឹមថ្ងៃទី៣១ មីនា ឆ្នាំ២០០៧ )

| ការចេញប្រាក់ចំណាយ និងការផ្ទេរ | OCR | ADF | សរុប |
|---|---|---|---|
| **ការចេញប្រាក់ចំណាយ**[ក] | | | |
| មូលនិធិសរុបដែលមានសម្រាប់ដកប្រាក់ ( លានដុល្លា) | 0,00 | ៨៤៨,១ | ៨៤៨,១ |
| ចំនួនប្រាក់ដែលត្រូវបើក ( លានដុល្លា លក្ខណៈប្រមូលផ្តុំ) | 0,00 | ៦២៨,៩ | ៦២៨,៩ |
| ការបើកប្រាក់ជាភាគរយ ( ចំនួនដែលបានបើក/ទឹកប្រាក់ដែលមាន) | 0,00 | ៧៤,២ | ៧៤,២ |
| ការចេញប្រាក់ចំណាយ ( លានដុល្លា ឆ្នាំ២០០៦ដូចឆ្នាំចុងក្រោយ) | 0,00 | ៥៤,៦ | ៥៤,៦ |
| អនុបាតការចេញប្រាក់ចំណាយ (%[ខ] ឆ្នាំ២០០៦ដូចឆ្នាំចុងក្រោយ) | 0,00 | ២០,៣ | ២០,៣ |
| **ការផ្ទេរធនធានសរុប ( លានដុល្លា)** | | | |
| ១៩៩៩ | 0,00 | ២៤,៩ | ២៤,៩ |
| ២០០០ | 0,00 | ៤៩,៣ | ៤៩,៣ |
| ២០០១ | 0,00 | ៤៦,៤ | ៤៦,៤ |
| ២០០២ | 0,00 | ៧៦,៤ | ៧៦,៤ |
| ២០០៣ | 0,00 | ៦៨,៤ | ៦៨,៤ |
| ២០០៤ | 0,00 | ៧០,៩ | ៧០,៩ |
| ២០០៥ | 0,00 | ៧៦,៧ | ៧៦,៧ |
| ២០០៦ | 0,00 | ៤៥,១ | ៤៥,១ |
| ៣១ មីនា ២០០៧ | 0,00 | ៧,៤ | ៧,៤ |

ADF = មូលនិធិអភិវឌ្ឍន៍អាស៊ី OCR = ធនធានមូលធនសាមញ្ញ

[ក] រាប់បញ្ចូលទាំងកម្ចីបន្តបន្ទាប់ និងកម្ចីដែលចេញប្រាក់ចំណាយនៅឆ្នាំ២០០៧

[ខ] អនុបាតនៃការចេញប្រាក់ចំណាយអំឡុងពេលឆ្នាំបន្ទាប់ៗទៀត តុល្យភាពកម្ចីសរុបមិនបានបែងចែកនៅដើមឆ្នាំដែលមិនសូវមានការលុបចោលនៅក្នុងឆ្នាំ ត្រូវបានបូកបន្ថែមទៀតទៅក្នុងតុល្យភាពនៅខាងដើមនៃទឹកប្រាក់ដែលមិនបានចេញ។

ប្រភព :  ធនាគារអភិវឌ្ឍន៍អាស៊ី គម្រោងផ្នែកសម្របសម្រួល និងលទ្ធកម្ម

**តារាង៧.៣ :ស្ថានភាពអនុវត្តផលប័ត្រ(Portfolio)សកម្ម**

( ប្រាក់កម្ចី និងជំនួយឥតសំណងវិស័យសាធារណៈ គិតត្រឹមថ្ងៃទី៣១ មីនា ២០០៧)

| វិស័យ | លេខ ជំនួយឥតសំណង ឬប្រាក់កម្ចី | ចំណងជើង | ប្រាក់កម្ចី ឬជំនួយឥតសំណងសរុប (លានដុល្លា) | ប្រាក់ចំណាយដែលបន្ថែម (លានដុល្លា) | ថ្ងៃអនុម័ត ថ្ងៃ/ខែ/ឆ្នាំ | ថ្ងៃមានប្រសិទ្ធភាព ថ្ងៃ/ខែ/ឆ្នាំ | ថ្ងៃបិទបញ្ជី ដើម ថ្ងៃ/ខែ/ឆ្នាំ | ថ្ងៃបិទបញ្ជី កែសម្រួល ថ្ងៃ/ខែ/ឆ្នាំ | វិវត្តនៃការចេញប្រាក់ចំណាយ (% បញ្ចប់) |
|---|---|---|---|---|---|---|---|---|---|
| AG | L1939 | គម្រោងគ្រប់គ្រងបរិស្ថានទន្លេសាប | ១២,២៨៤ | ៧,២៨១ | ២១ វិច្ឆិកា ០២ | ២៧ មីនា ០៣ | ៣០ មិថុនា ០៨ | - | ៥៩ |
| AG | L2022 | កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម (ASDP) | ២៦,៦៤១ | ១៥,០០០ | ២៦ វិច្ឆិកា ០៣ | ០២ ធ្នូ ០៤ | ៣០ មិថុនា ០៧ | ៣១ ធ្នូ ០៧ | ៥៦ |
| AG | L2023 | គម្រោងអភិវឌ្ឍន៍វិស័យកសិកម្ម | ៤,៩៧៣ | ០,៨១៤ | ២៦ វិច្ឆិកា ០៣ | ០២ ធ្នូ ០៤ | ៣០ មិថុនា០៩ | - | ១៦ |
| AG | L2035 | គម្រោងវិស័យធារាសាស្ត្រភាគពាយ័ព្យ | ១៨,៩៥៥ | ១,៨៩៩ | ០៩ ធ្នូ ០៣ | ០២ កុម្ភៈ ០៥ | ៣១ ធ្នូ ១០ | - | ១០ |
| AG | G0034/0035 | គម្រោងរបរចិញ្ចឹមជីវិតប្រកបដោយចីរភាពនៅទន្លេសាប | ១៥,០០០ | ០,២៤១ | ២១ ធ្នូ ០៥ | ១៩ មិថុនា០៦ | ៣០ មិថុនា ១០ | - | ២ |
| | | **សរុបតាមផ្នែកកសិកម្ម និងធនធានធម្មជាតិ** | **៧៧,៨១៧** | **២៥,២៣៥** | | | | | |
| ED | L1865 | គម្រោងអភិវឌ្ឍន៍វិស័យអប់រំ | ២០,៣៥៦ | ១៨,៩៨៧ | ០៤ ធ្នូ ០១ | ១២ មេសា ០២ | ៣០ មិថុនា ០៧ | ៣១ ធ្នូ ០៧ | ៩៣ |
| ED | L2121 | កម្មវិធីអភិវឌ្ឍវិស័យអប់រំទី២ | ១៩,៩៩៨ | ១២,៤៤១ | ០៩ ធ្នូ ០៤ | ៣១ សីហា ០៥ | ៣០ មិថុនា ០៨ | - | ៦២ |
| ED | L2122 | គម្រោងអភិវឌ្ឍវិស័យអប់រំទី២ | ២៥,០៧៨ | ៤,៦៩៧ | ០៩ ធ្នូ ០៤ | ៣១ សីហា ០៥ | ៣០ មិថុនា ១០ | - | ១៩ |
| | | **សរុបតាមផ្នែកការអប់រំ** | **៦៥,៤៣២** | **៣៦,១២៥** | | | | | |
| EN | L1794 | គម្រោងផ្គត់ផ្គង់ទឹកតាមខេត្ត | ២១,៣៣២ | ១៩,៣៥៤ | ០៥ ធ្នូ ០០ | ០១ សីហា ០១ | ៣១ ធ្នូ ០៤ | ៣១ ធ្នូ ០៦ | ៩១ |
| EN | L2052 | GMS: គម្រោងតភ្ជាប់បណ្តាញថាមពល | ៤៦,៦៩៤ | ២,៦៣៤ | ១៩ ធ្នូ ០៣ | ២៥ មីនា ០៥ | ៣១ ធ្នូ ០៨ | - | ៦ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| EN | L2261 | គម្រោងតភ្ជាប់ និងចែកចាយថាមពលទី២ | ២០,៤១៦ | 0,000 | 0៤តុលា 0៥ | - | ៣១ ធ្នូ ១0 | - | 0 |
| | | **សរុបរួមផ្នែកថាមពល** | **៨៨,៤៤២** | **២១,៩៨៨** | | | | | |
| FI | L2185 | កម្មវិធីវិស័យហិរញ្ញវត្ថុ ( អនុកម្មវិធី៣ ) | ១0,២១៣ | 0,000 | ២៩ កញ្ញា 0៥ | ១១ មករា 0៦ | ៣0 មិថុនា 0៧ | ៣0 កញ្ញា 0៧ | 0 |
| | | **សរុបរួមផ្នែកកសិកម្ម និងធនធានធម្មជាតិ** | **១0,២១៣** | **0,000** | | | | | |
| HL | L1940 | គម្រោងគាំទ្រវិស័យសុខាភិបាល | ២២,៦៤១ | ៩,៨0៨ | ២១ វិច្ឆិកា 0២ | ២៨ កុម្ភៈ 0៣ | ៣0 មិថុនា 0៨ | - | ៤៣ |
| HL | G0025 | GMS: គម្រោងទប់ស្កាត់ជំងឺឆ្លងថ្នាក់តំបន់ | ៩,000 | 0,៣១៩ | ២១ ធ្នូ 0៥ | 0៧ មីនា 0៦ | ៣0 មិថុនា ១0 | - | ៤ |
| | | **សរុបរួមផ្នែកសុខភាព អាហាររូបត្ថម្ភ និងការ ការពារសង្គម** | **៣១,៦៤១** | **១0,១២៧** | | | | | |
| IN | L1969 | GMS: គម្រោងអភិវឌ្ឍន៍វិស័យទេសចរណ៍នៅទន្លេមេគង្គ | ១៧,៧៣៧ | ៣,៣២១ | ១២ ធ្នូ 0២ | 0៦ សីហា 0៣ | ៣0 មិថុនា 0៨ | - | ១៩ |
| IN | L2129 | កម្មវិធីអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម | ១៩,៩៣៨ | ១៤,៩00 | ១៤ ធ្នូ 0៤ | 0៦ មេសា 0៥ | ៣១ ធ្នូ 0៧ | - | ៧៥ |
| | | **សរុបរួមផ្នែកឧស្សាហកម្ម និងពាណិជ្ជកម្ម** | **៣៧,៦៧៥** | **១៨,២២១** | | | | | |
| LW | L1953 | គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំសង្កាត់ | ១១,១៧៩ | ១0,៣៣២ | 0៣ ធ្នូ 0២ | ១៣ មីនា 0៣ | ៣១ សីហា 0៦ | ៣១ ធ្នូ 0៦ | ១00 |
| LW | G0066 | គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំសង្កាត់ ॥ | ៧,៨00 | 0,000 | ១២ ធ្នូ 0៦ | | ៣១ ធ្នូ 0៩ | | - |
| | | **សរុបរួមផ្នែកច្បាប់ ការគ្រប់គ្រងសេដ្ឋកិច្ច និងគោលនយោបាយសាធារណៈ** | **១៨,៩៧៩** | **១0,៣៣២** | | | | | |
| MS | L1753 | គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ និងធារាសាស្ត្រនៅស្ទឹងជីនិត | ១៧,៦0៧ | ១២,១0៧ | 0៥ កញ្ញា 00 | ២៨ កុម្ភៈ 0១ | ៣0 មិថុនា 0៧ | ៣0 មិថុនា 0៧៨ | ៦៩ |
| MS | L1862 | គម្រោងអភិវឌ្ឍន៍ជនបទភាគពាយ័ព្យ | ៣១,៣៣២ | ២១,២១២ | ២៧ វិច្ឆិកា 0១ | 0៣ កញ្ញា 0២ | ៣១ ធ្នូ 0៧ | - | ៦៨ |
| | | **សរុបរួមតាមពហុវិស័យ** | **៤៨,៩៣៩** | **៣៣,៣១៩** | | | | | |
| TC | L1945 | GMS: គម្រោងអភិវឌ្ឍន៍ផ្លូវថ្នល់នៅប្រទេសកម្ពុជា | ៥៦,៨២៩ | ១១,៥0៨ | ២៦ វិច្ឆិកា 0២ | ២0 ឧសភា 0៣ | ៣0 មិថុនា 0៧ | ៣១ មីនា 0៩ | ២0 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| TC | L2288 | GMS: គម្រោងស្តារផ្លូវអោយស្ទ័យយាន្តនៅកម្ពុជា | ៤២,៧០៤ | ០,០០០ | ១៣ ធ្នូ ០៦ | - | ៣០ មិថុនា ១០ | - | ០ |
| | | **សរុបរួមផ្នែកការដឹកជញ្ជូន និងគមនាគមន៍** | **៩៩,៩៣៣** | **១១,៥០៨** | | | | | |
| WS | L1725 | គម្រោងកែលំអទីរួមខេត្ត | ២០,៩៧០ | ១៩,៤៤០ | ១៧ ធ្នូ ៩៩ | ១១ មេសា ០០ | ៣១ ធ្នូ ០៥ | ៣១ មីនា ០៧ | ៩៣ |
| WS | L2013 | គម្រោងកែលំអទីរួមខេត្ត | ៦,៦៩៨ | ៦,៥១២ | ២៨ តុលា ០៣ | ០២ មករា ០៤ | ៣០ មិថុនា ០៦ | ៣១ មិនា ០៧ | ៩៧ |
| WS | G0018 | គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យនៅទីជនបទបឹងទន្លេសាប | ១៨,០០០ | ១,២៦៧ | ២០ តុលា ០៥ | ០២ កុម្ភៈ ០៦ | ៣០ មិថុនា ១២ | | ៧ |
| | | **សរុបរួមការផ្គត់ផ្គង់ទឹក អនាម័យ និងការគ្រប់គ្រងកាកសំណល់** | ៤៥,៦៦៨ | ២៧,២១៩ | | | | | |
| | | **សរុប** | **៥២៤,៣៣៩** | **៣៦០,៩២៩** | | | | | |

AG = កសិកម្ម និងធនធានធម្មជាតិ, ED = ការអប់រំ, EN = ថាមពល, FI = ហិរញ្ញវត្ថុ, HL = សុខាភិបាល, អាហាររូបត្ថម្ភ និងការការពារសង្គម, IN = ឧស្សាហកម្ម និងពាណិជ្ជកម្ម, LW = ច្បាប់ និងការគ្រប់គ្រងវិស័យសាធារណៈ, MS = ពហុវិស័យ, TC = ការដឹកជញ្ជូន និងទូរគមនាគមន៍, និង WC = ការផ្គត់ផ្គង់ទឹក និងការគ្រប់គ្រងកាកសំណល់ ។

**តារាងក៧.៤: រង្វាយតម្លៃចំណាត់ថ្នាក់តាមវិស័យ កម្មវិស័យសាធារណ**

(១៩៩៦-២០០៦)

| វិស័យ | ជោគជ័យខ្លាំង | | ជោគជ័យ | | ជោគជ័យផ្នែកខ្លះ | | មិនជោគជ័យ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | No. | % | No. | % | No. | % | No. | % | No. | % |
| កសិកម្ម និងធនធានធម្មជាតិ | 0 | 0,00 | ១ | ២៥ | 0 | 0,00 | 0 | 0,00 | ១ | ២៥ |
| ការអប់រំ | 0 | 0,00 | ១ | ២៥ | 0 | 0,00 | 0 | 0,00 | ១ | ២៥ |
| ថាមពល | 0 | 0,00 | ១ | ២៥ | 0 | 0,00 | 0 | | ១ | ២៥ |
| ហិរញ្ញវត្ថុ | 0 | 0,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| សុខភាព អាហារូបត្ថម្ភ និងការ ការពារសង្គម | 0 | 0,00 | 0 | 0 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| ឧស្សាហកម្ម និងពាណិជ្ជកម្ម | 0 | 0,00 | 0 | 0 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| ច្បាប់ ការគ្រប់គ្រងសេដ្ឋកិច្ច និងគោលនយោបាយសាធារណៈ | 0 | 0,00 | 0 | 0 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| ការដឹកជញ្ជូន និងគមនាគមន៍ | 0 | 0,00 | 0 | 0 | 0 | 0,00 | 0 | 0.00 | 0 | 0,00 |
| ការផ្គត់ផ្គង់ទឹក អនាម័យ និង ការគ្រប់គ្រងកាកសំណល់ | 0 | 0,00 | 0 | 0 | 0 | 0,00 | 0 | 0,00 | 0 | 0,00 |
| វិស័យចំរុះ | 0 | 0,00 | ១ | ២៥ | 0 | 0,00 | 0 | 0,00 | ១ | ២៥ |
| **សរុប** | **0** | **0,00** | **៤** | **១00** | **0** | **0,00** | **0** | **0,00** | **៤** | **១00** |

ប្រភព :ធនាគារអភិវឌ្ឍន៍អាស៊ី ។ របាយការណ៍ផ្នែកវាយតម្លៃប្រតិបត្តិការ/ប្រពន្ធ័ព័តិមានវាយតម្លៃក្រោយ

## យុទ្ធសាស្ត្រប្រចាំប្រទេស និងក្របខណ្ឌលទ្ធផលកម្មវិធី (២០០៦-២០១០)[ក]

| របៀបវារៈអភិវឌ្ឍន៍ រយៈពេលមធ្យមរបស់រដ្ឋាភិបាល[ខ] | | ការផ្តោតជាយុទ្ធសាស្ត្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី | | អន្តរាគមន៍របស់ ADBទៅ លើលទ្ធផលនៃការគាំទ្រ | ហានិភ័យ |
|---|---|---|---|---|---|
| គោលដៅជាយុទ្ធសាស្ត្រ[គ] | ប្រឈមសំខាន់ៗ[ឃ] | លទ្ធផល/សូចនាករលទ្ធផល[ង] | សូចនាករតាមដាន/ការ រំពឹងទុក[ច] | | |
| **សសរទី១ : កំណើនសេដ្ឋកិច្ចគាំទ្រជនក្រីក្រប្រកបដោយចីរភាព** | | | | | |
| កាត់បន្ថយសមាមាត្រនៃចំនួនប្រជាជនដែលស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ ថ្នាក់ជាតិឱ្យបាន ២៥ ភាគរយ នៅឆ្នាំ២០១០ ដែលនៅឆ្នាំ ១៩៩៤ មានចំនួន ៣៤ ភាគរយ។<br><br>កាត់បន្ថយការកើនឡើងនូវភាពក្រីក្រនៅជនបទ ដែលមានចំនួន ៣៩.២ ភាគរយ នៅឆ្នាំ២០០៤ | កំណើនសេដ្ឋកិច្ចដ៏ចង្អៀត ពឹងផ្អែក និងផ្តោតទៅលើតំបន់ជនបទ<br><br>កង្វះពាណិជ្ជភាវូបនីយកម្មនៃកសិកម្ម ផលិតកម្មទាប និងកំណើននៃលទ្ធផលទាបក្នុងវិស័យកសិកម្ម<br><br>**កង្វះការគ្រប់គ្រងអាងទន្លេ ឱ្យបានទូលំទូលាយ**<br>**ធនធានធម្មជាតិនៅអាងទន្លេសាប ស្ថិត នៅក្រោមការគាបសង្កត់ ដោយ** | បង្កើនផលិតកម្មកសិកម្ម ទិន្នផលស្រូវបានកើនឡើងពី ២.០តោន/ហ.ត នៅឆ្នាំ ២០០៥ រហូតដល់ ២.៤តោន / ហ.ត នៅត្រឹមឆ្នាំ២០១០<br><br>ដីកសិកម្មស្ថិតនៅក្រោមប្រព័ន្ធធារាសាស្ត្រ (រួមទាំងធារាសាស្ត្រ ជំនួស) បានកើនឡើងពី២០ភាគរយ នៅឆ្នាំ ២០០៥ ដល់ ២៥ភាគរយនៅឆ្នាំ២០១០ | នៅត្រឹមឆ្នាំ២០០៨ កសិករប្រមាណ៧០,០០០នាក់ នឹងទទួលផលប្រយោជន៍ពីការផ្សព្វផ្សាយកសិកម្ម និងសកម្មភាពគាំទ្រដទៃទៀត<br><br>គម្រោងធារាសាស្ត្រដែលបានស្តារដែលគ្របដណ្តប់លើបរិបទនៃដីកសិកម្ម ស្ថិតនៅក្រោមគម្រោងរបស់ ADB ចាប់ពី៣.០០០ ហិកតា នៅឆ្នាំ២០០៥ ដល់ ៣៥.០០០ នៅឆ្នាំ ២០១០ ដោយមានការចូលរួមលើគម្រោងបែបនេះ | **សកម្មភាពកំពុងបន្ត**<br>កម្មវិធី/គម្រោងអភិវឌ្ឍវិស័យ កសិកម្ម<br><br>TA :<br>ការគាំទ្រគោលនយោបាយ និងកំណែទម្រង់តាមស្ថាប័ន នៅក្នុងវិស័យកសិកម្ម<br><br>ធារាសាស្ត្រនិងហេដ្ឋារចនាសម្ព័ន្ធស្ទឹង ជីនិត | កង្វះការប្តេជ្ញាចិត្ត ផ្នែកនយោបាយលើកំណើនសហគ្រាស ផ្អែកលើកសិកម្មឯកជន<br><br>បង្កើនគោលដៅផលិតកម្ម កសិកម្ម ដែលមិនគាំទ្រដោយការបែងចែកថវិកាគ្រប់គ្រាន់<br><br>អង្គភាពផ្អែកលើសហគមន៍ មិនត្រូវបានផ្តល់អំណាចឱ្យ |

| | | | | | |
|---|---|---|---|---|---|
| រក្សាកំណើននៃ **GDP** នៅត្រឹម៦ភាគរយប្រចាំឆ្នាំ អំឡុងឆ្នាំ២០០៦-២០១០ | **សារកង្វះជម្រើសនៃការប្រកបរបរចិញ្ចឹមជីវិត**<br>**ការរួបបញ្ចូលការអភិវឌ្ឍវិស័យចម្រុះដែលស្ថិតនៅក្រោមគោលនយោបាយទូលំទូលាយ និងការរៀបចំតាមស្ថាប័ននៅមានការខ្វះខាតនៅឡើយ**<br><br>**អភិបាលកិច្ចនៃការអភិវឌ្ឍជនបទ ក្រសួងពាក់ព័ន្ធនៅខ្សោយ ហើយសមត្ថភាពស្ថាប័ននៅតាមមូលដ្ឋាន និងផ្តោតលើសហគមន៍ នៅខ្សោយ ដែលជាហេតុធ្វើឱ្យអ្នកទាំងនោះ គ្មានសមត្ថភាព ក្នុងការគ្រប់គ្រងធនធានធនធានធម្មជាតិប្រកបដោយចីរភាព** | លើកកម្ពស់បរិយាកាសទីផ្សារសម្រាប់កំណើនសហគ្រាសផ្នែកលើកសិកម្មឯកជន។<br><br>ការគ្រប់គ្រង និងការអភិរក្សធនធានធម្មជាតិ ប្រកបដោយចីរភាព<br><br>វិសាលភាពនៃព្រៃឈើ រក្សាបាននៅត្រឹម៦០ភាគរយ នៃផ្ទៃសរុបរវាងឆ្នាំ២០០៥- ២០១០<br><br>ចំនួនការធ្វើនេសាទនៅសហគមន៍បានកើនឡើងពី ៣៧៥ នៅឆ្នាំ ២០០៥ ដល់៤៦៤ នៅឆ្នាំ២០១០<br><br>**ការគ្រប់គ្រងធនធានធម្មជាតិស្ថិតនៅក្រោមការធ្វើផែនការអាងទន្លេ និងការអភិវឌ្ឍវិធីសាស្ត្រដែលបានជ្រើសរើស** | ក៏បានធ្វើឱ្យកើនឡើងពី១៥.០០០ ហិកតា នៅឆ្នាំ ២០០៥ ដល់ ៣៥.០០០ ហិកតា នៅឆ្នាំ ២០១០<br><br>**នៅត្រឹមឆ្នាំ២០១០ យ៉ាងហោចណាស់គម្រោងធារាសាស្ត្រចំនួន ១៥ នឹងត្រូវអនុវត្តគម្រោង ការចូលរួមគ្រប់គ្រងប្រកបដោយនិរន្តរភាព**<br><br>នៅត្រឹមឆ្នាំ២០០៧ ការលុបបំបាត់ចោលការផលិតកៅស៊ូកាន់កាប់ដោយរដ្ឋក្រុមហ៊ុនផលិតកសិកម្ម និងជួញដូរត្រី នឹងត្រូវបានបញ្ចប់ ដោយយោងទៅតាមផែនការលុបបំបាត់ដែលបានព្រមព្រៀង<br><br>នៅត្រឹមឆ្នាំ២០០៨ ការអនុវត្តនីតិកម្មសម្រាប់ច្បាប់គ្រប់គ្រង | វិស័យធារាសាស្ត្រភាគពាយ័ព្យ/<br>គម្រោងអភិវឌ្ឍភាគពាយ័ព្យ<br><br>ការគ្រប់គ្រងបរិស្ថានទន្លេសាប/<br>ការប្រកបរបរចិញ្ចឹមជីវិតនៅ<br>ទន្លេសាបប្រកបដោយនិរន្តរភាព<br><br>**ការស្នើឡើង**<br>គម្រោងវិស័យគ្រប់គ្រងធនធានទឹក<br><br>គម្រោងធ្វើឱ្យមានស្ថិរភាពតំបន់<br>ទំនាបបឹងទន្លេសាប<br><br>TA : | គ្រប់គ្រាន់ដល់ការអភិវឌ្ឍដើម្បីជំរុញសហគមន៍<br><br>ការទទួលមូលនិធិសហគមន៍ដែលគាំទ្រដោយក្រុម ដែលសម្បូរដោយធនធាន<br><br>អ្នកមានអំណាច បន្តដណ្តើមដីធ្លីឬព្យាយាមធ្វើជាម្ចាស់ លើធនធានធម្មជាតិ |

| | | | | | |
|---|---|---|---|---|---|
| | ទឹកជំនន់ និងគ្រោះរាំងស្ងួត ធ្វើឲ្យខាតបង់ផ្នែកសេដ្ឋកិច្ច និងបាត់បង់ជីវិតមនុស្ស | នៅក្នុងក្របខ័ណ្ឌអាងទន្លេសាប<br><br>លើកកម្ពស់ការប្រកបរបរចិញ្ចឹមជីវិតនៅជនបទដើម្បីកាត់បន្ថយសម្ពាធទៅលើធនធានអាងទន្លេសាប<br><br>ដែនជម្រកត្រីនៅតំបន់ស្នូលទ្រទ្រង់ជីវៈដែន ដែលត្រូវបានគ្រប់គ្រងនៅក្រោមការទ្រទ្រង់ជីវៈដែន<br><br>ការកាត់បន្ថយការខាតបង់ផ្នែកសេដ្ឋកិច្ច និងការបាត់បង់ជីវិតមនុស្សពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត | ធនធានទឹក នឹងត្រូវបានអនុម័តនៅឆ្នាំ២០០៧<br>នៅត្រឹមឆ្នាំ២០០៧ ការអនុម័ត និងការអនុវត្តការគ្រប់គ្រងធនធានទឹកចម្រុះ នៅក្នុងបរិបទអាងទន្លេ ដែលបានអនុម័តយ៉ាងហោចណាស់អាងទន្លេតូចៗចំនួន៨ នៅអាងទន្លេសាប<br><br>នៅត្រឹមឆ្នាំ២០១០ ប្រព័ន្ធគ្រប់គ្រងថ្មីសម្រាប់តំបន់ស្នូលទ្រទ្រង់ជីវៈដែនអាងទន្លេសាប ត្រូវបានបង្កើតឡើង<br><br>នៅត្រឹមឆ្នាំ២០០៨ ការបង្កើតការរៀបចំតាមស្ថាប័នសម្រាប់គោលនយោបាយអភិវឌ្ឍន៍វិស័យចម្រុះ ការបង្កើត និងការតាមដាន | ការបង្កើតស្ថាប័នគ្រប់គ្រង អាងទន្លេសាប ៣-៤<br><br>**TA:**<br>ការអភិរក្សតំបន់ជីវៈចម្រុះ GSM<br><br>ការប្រកបរបរចិញ្ចឹមជីវិត នៅខេត្តសៀមរាប<br><br>ការគ្រប់គ្រង/ការកាត់បន្ថយ<br>គ្រោះមហន្តរាយគ្រោះទឹកជំនន់<br>និងគ្រោះរាំងស្ងួត GSM | |

| | | | | | |
|---|---|---|---|---|---|
| | | | នៅត្រឹមឆ្នាំ២០០៨ ការអនុម័តការតាំងចិត្ត លើការអនុវត្តគណនេយ្យភាព ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលធ្វើឡើងដោយ MAFF, MOWRAM និង MRD<br>ត្រឹមឆ្នាំ២០០៨ សហគមន៍ចំនួន ៩០ ដែលរស់នៅក្នុងខេត្តចំនួន៥ជុំវិញបឹងទន្លេសាប នឹងត្រូវរៀបចំផែនការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍<br>នៅត្រឹមឆ្នាំ២០០៧ សហគមន៍ចំនួន៤០ នឹងទទួលបានមូលនិធិអភិវឌ្ឍន៍សហគមន៍ ដើម្បីអនុវត្តសកម្មភាពប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ។ នៅឆ្នាំ២០០៩ សកម្មភាពនេះ នឹងពង្រីកយ៉ាងហោចណាស់រហូតដល់ ៧០ សហគមន៍ | | |

| | | | | | |
|---|---|---|---|---|---|
| | | | **នៅឆ្នាំ២០០៩ ការកាត់បន្ថយគ្រោះទឹកជំនន់ក្នុងលក្ខណៈទូលំទូលាយ និងការគ្រប់គ្រងផែនការជំនួយ នឹងត្រូវបានរៀបចំ** | | |
| | ឧបសគ្គរបស់ SMEs គឺកង្វះការអនុវត្តប្រកបស្ថេរភាព នៃគោលនយោបាយ<br>កង្វះអំណោយផលនៃបរិយាកាសអាជីវកម្ម<br>ការទទួលបានហិរញ្ញវត្ថុមានកម្រិត<br>ជំនាញសហគ្រាសនៅខ្សោយ ។<br>ការទទួលបានព័ត៌មាន និងបច្ចេកវិទ្យាទីផ្សារ នៅមានកម្រិត | លើកកម្ពស់បរិយាកាសច្បាប់ និងនីតិកម្ម សម្រាប់ការអភិវឌ្ឍ SME<br><br>បង្កើនចំនួនការចុះឈ្មោះសហគ្រាសប្រចាំឆ្នាំ ទាំងនៅតំបន់ទីក្រុង និងជនបទ (តំបន់មូលដ្ឋាន : ១២៩/ខែ នៅឆ្នាំ២០០៥)<br><br>លើកកម្ពស់ការទទួលបានហិរញ្ញវត្ថុរបស់ SME<br>បង្កើនប្រាក់កម្ចី MFI ទៅដល់ SME (ទិន្នន័យមូលដ្ឋាន : ៥១លានដុល្លា នៅឆ្នាំ២០០៥) | នៅឆ្នាំ២០០៧ ក្របខ័ណ្ឌអភិវឌ្ឍ SME ថ្នាក់ជាតិ ត្រូវបានអនុម័ត សកម្មភាពគោលនយោបាយជំហានទី១ ត្រូវបានអនុវត្ត ហើយក្របខ័ណ្ឌ ដើម្បីពិចារណាទៅលើភាពរីកចម្រើននៃកំណែទម្រង់ត្រូវបានធ្វើបច្ចុប្បន្នភាព<br><br>នៅត្រឹមឆ្នាំ២០០៧ ការចុះឈ្មោះតាមបែបវិមជ្ឈការត្រូវបានណែនាំឱ្យប្រើប្រាស់<br><br>នៅត្រឹមឆ្នាំ២០០៧ ដើម្បីសម្របសម្រួលការ ទទួលបានហិរញ្ញវត្ថុ | **សកម្មភាពកំពុងបន្ត**<br>កម្មវិធីអភិវឌ្ឍ SME<br><br>TA:<br>ការកសាងសមត្ថភាពសម្រាប់ការអភិវឌ្ឍ SME<br><br>TA:<br>ការកសាងសមត្ថភាពសម្រាប់ការអភិវឌ្ឍ SME ២<br><br>**ការស្នើសុំ :**<br>កម្មវិធីអភិវឌ្ឍន៍ SME ២ | កង្វះយន្តការជាក់លាក់សម្រាប់ការតាមដានប្រសិទ្ធភាពគោលនយោបាយ<br><br>បរាជ័យនៃការសម្រេចបានការផ្សព្វផ្សាយក្នុងលក្ខណៈទូលំទូលាយ ក្នុងការចែកចាយលទ្ធផលកំណែទម្រង់ |

| | | | | | |
|---|---|---|---|---|---|
| | | ក្របខ័ណ្ឌច្បាប់សម្រាប់ការជួលផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការត្រូវបានបង្កើតឡើង ហើយការអនុវត្តនីតិកម្ម ត្រូវបានចេញឱ្យប្រើប្រាស់នៅ ឆ្នាំ២០០៧ | គោលការណ៍គណនេយ្យ SME គោលការណ៍បំពេញពន្ធដែលត្រូវបានកែសម្រួលទម្រង់បទដ្ឋានត្រូវបានបង្កើតឡើង និងអនុម័ត<br><br>នៅត្រឹមឆ្នាំ ២០០៧សហគ្រាសចំនួន ១០០០ត្រូវបានបណ្ដុះបណ្ដាលលើផ្នែកគណនេយ្យ | | |
| | ការទទួលបាននៅមានកម្រិត និងសេវាហិរញ្ញវត្ថុ មានតម្លៃថ្លៃ<br><br>ការអាចរកបាននូវហិរញ្ញវត្ថុរយៈពេលវែងនៅមានកម្រិត ស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារ ស្ថិតក្រោមការអភិវឌ្ឍ ហើយចំនួននៃផលិតផល និងសេវានៅមានកម្រិត | បង្កើតប្រព័ន្ធហិរញ្ញវត្ថុផ្អែកលើទីផ្សារ ដើម្បីគាំទ្រការកៀងគរធនធាន និងអន្តរកម្មហិរញ្ញវត្ថុ<br><br>ឥណទានផ្ដល់ដល់វិស័យឯកជនបានកើនឡើងពី១២,៥ភាគរយនៃ GDP នៅឆ្នាំ ២០០៥ ដល់ ១៧ ភាគរយនៅឆ្នាំ ២០១០ | នៅត្រឹមឆ្នាំ២០០៨ នីតិកម្មប្រកបដោយភាពប្រុងប្រយ័ត្ន ត្រូវបានលើកកម្ពស់ ទៅកាន់អ្នកចូលរួមសំខាន់ៗនៅ បាសែល១<br><br>នៅត្រឹមឆ្នាំ២០០៨ ច្បាប់ប្រតិបត្តិការប្រកបដោយការធានាត្រូវបានអនុម័ត និងអនុវត្តទាំងស្រុង ហើយ | **សកម្មភាពកំពុងបន្ត**<br>កម្មវិធីប្រាក់កម្ចីហិរញ្ញវត្ថុ<br><br>TA:<br>លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធស្របច្បាប់នៅក្នុងវិស័យ ហិរញ្ញវត្ថុ | គ្មានជំនួយបច្ចេកទេសសំខាន់ ឆន្ទះក្នុងការធ្វើកំណែទម្រង់នៅខ្សោយ<br><br>រាជរដ្ឋាភិបាល អាចមិនអនុញ្ញាតឱ្យ |

| | | | | | |
|---|---|---|---|---|---|
| | | ល្បឿនអត្រាការប្រាក់បានថយចុះពី១១,៧ភាគរយនៅឆ្នាំ ២០០៥ ដល់៩ភាគរយ នៅឆ្នាំ២០១០ ។ ប្រាក់ធានារ៉ាប់រង/អត្រា GDP បានកើនឡើងពី០,២ ភាគរយ នៅឆ្នាំ២០០៥ ដល់ ១,០ភាគរយ នៅឆ្នាំ២០១០ ។ | ការចុះឈ្មោះប្រតិបត្តិការប្រកបដោយការធានាតាមរយៈអ៊ិនធើណេត ត្រូវបានបង្កើត<br><br>នៅត្រឹមឆ្នាំ២០០៨ ការត្រួតពិនិត្យប្រព័ន្ធច្បាប់ក្នុងលក្ខណៈទូលំទូលាយ ត្រូវបានធ្វើឡើងឱ្យស្របគ្នាជាមួយនឹងការអនុវត្តដ៏ប្រសើរជាលក្ខណៈអន្តរជាតិ និងស៊ីគ្នាទៅនឹងផែនការវិស័យហិរញ្ញវត្ថុថ្មី (២០០៦-២០១៥)<br><br>ប្រព័ន្ធទូទាត់តាមបែបអេឡិចត្រូនិចថ្នាក់ជាតិត្រូវបានបង្កើតឡើងដំបូងជាមួយធនាគារ (២០០៨) និងបានពង្រីកទៅ កាន់ MFIs (២០១០) | TA:<br>ការអនុវត្តកម្មវិធីវិស័យហិរញ្ញវត្ថុ<br><br>TA:<br>ការធ្វើបច្ចុប្បន្នភាពលើវិស័យហិរញ្ញវត្ថុ<br><br>**ការស្នើសុំ :**<br>កម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (ក្រុមទី១)<br><br>**កម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (ក្រុមទី២)** | ស្ថាប័ន និងសមាគមវិស័យឯកជន ទទួលខុសត្រូវលើដំណើរការនីតិកម្ម និងកំណែទម្រង់ |
| | ក្រុមធំ មិនអាចទទួលអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ច ដោយសារចំណាយថ្លៃខ្ពស់ហេដ្ឋារចនាសម្ព័ន្ធមិនមានគ្រប់គ្រាន់ និងមានលក្ខណៈទន់ខ្សោយ | **លើកកម្ពស់ការទទួលបាននៅជនបទ ការកើនការទុកចិត្តទៅលើបណ្តាញធ្វើដំណើរតាមផ្លូវថ្នល់ និងផ្លូវដែក លើកកម្ពស់ការតភ្ជាប់អនុតំបន់** | **ភាគរយនៃផ្លូវថ្នល់នៅជនបទ នឹងមានលក្ខណៈល្អប្រសើរដោយការកើនឡើងពី១៦ភាគរយ នៅឆ្នាំ២០០៥ ដល់២៥ភាគរយ នៅឆ្នាំ២០១០** | **សកម្មភាពកំពុងបន្ត**<br>គម្រោងកែលំអផ្លូវនៅប្រទេស កម្ពុជា<br><br>ការស្តារផ្លូវដែក GSM | **ការពន្យារមូលនិធិបដិភាគរបស់រដ្ឋាភិបាល ពន្យារសម្បទានអ្នកប្រតិបត្តិការ** |

| | | | | | |
|---|---|---|---|---|---|
| | ការចំណាយលើការធ្វើដំណើរខ្ពស់ និងកង្វះភាពប្រកួតប្រជែងរវាងមធ្យោបាយធ្វើដំណើរ<br><br>ហេដ្ឋារចនាសម្ព័ន្ធមិនមាននិរន្តរភាព ដោយសារខ្វះយន្តការប្រកបដោយប្រសិទ្ធភាព និងមូលនិធិសម្រាប់ការថែរក្សា<br><br>ការគ្រប់គ្រងចរាចរ និងការប្រតិបត្តិនីតិកម្មចរាចរនៅខ្សោយ<br><br>កង្វះមូលដ្ឋានច្បាប់សម្រាប់ដោះស្រាយបញ្ហាការពារសង្គម | លើកកម្ពស់ប្រសិទ្ធភាពការធ្វើដំណើរតាមរយៈការធ្វើកំណែទម្រង់ និងការពង្រឹងផ្លូវថ្នល់ និងស្ថាប័នអនុក្រុមផ្លូវដែក ជាមួយនឹងការចូលរួមផ្នែកវិស័យឯកជនដែលមានលក្ខណៈកាន់តែទូលំទូលាយ<br><br>លើកកម្ពស់និរន្តរភាពនៃវិស័យធ្វើដំណើរ : លើកកម្ពស់យន្តការសម្រាប់រក្សាហេដ្ឋារចនាសម្ព័ន្ធធ្វើដំណើរ<br><br>លើកកម្ពស់សុវត្ថិភាពផ្លូវថ្នល់<br><br>ការពារសុខុមាលភាពប្រជាជនដែលរងគ្រោះដោយគម្រោងហេដ្ឋារចនាសម្ព័ន្ធ | នៅត្រឹមឆ្នាំ២០១០ តម្លៃឈ្នួលការធ្វើដំណើរ នឹងត្រូវបានកាត់បន្ថយ នៅត្រឹម១០ភាគរយ ពីឆ្នាំ២០០៥<br><br>នៅត្រឹមឆ្នាំ២០០៨ ការបង្កើតគោលការណ៍ណែនាំសង្គម និងបច្ចេកទេសមិនគិតពីប្រភពហិរញ្ញប្បទាន<br><br>ភាគរយនៃផ្លូវថ្នល់ដែលរក្សាបានល្អនឹងកើនឡើងពី៣០ភាគរយ នៅឆ្នាំ២០០៥ ដល់៤០ភាគរយ នៅឆ្នាំ២០១០<br><br>ការកាត់បន្ថយការខូចខាតនូវចំនួនផ្លូវថ្នល់ពីការខូចខាតចំនួន ១២ដង ក្នុងយានយន្តចំនួន ១,០០០ ទៅការខូចខាតចំនួន ៧ | នៃ<br>គម្រោងនៅប្រទេសកម្ពុជា<br>TA:<br>ការបញ្ច្រាបការរក្សាផ្លូវថ្នល់ ផ្អែកលើកម្លាំងពលកម្មទៅលើ បណ្តាញផ្លូវជាតិ<br><br>TA:<br>ការសាងសង់ឡើងវិញនូវផ្លូវដែកនៃប្រទេសកម្ពុជា<br><br>ការលើកកម្ពស់ក្របខ័ណ្ឌច្បាប់<br>នៃការតាំងទីលំនៅ និងសមត្ថភាពតាមស្ថាប័ន<br><br>**ការស្នើសុំ :**<br>គម្រោងគ្រប់គ្រងទ្រព្យ | **ផ្លូវដែកឯកជន**<br>កង្វះការតាំងចិត្តក្នុងការអនុវត្តប្រព័ន្ធគ្រប់គ្រងថែរក្សាផ្លូវថ្នល់ប្រកបដោយនិរន្តរភាព<br><br>កង្វះមូលនិធិសម្រាប់ការអនុវត្តយុទ្ធនាការអប់រំចរាចរណ៍<br><br>កង្វះការកសាងសមត្ថភាពប្រកបដោយប្រសិទ្ធភាពក្នុងការតាមដាន និងអនុវត្តច្បាប់ និងនីតិកម្ម |

| | | | | | |
|---|---|---|---|---|---|
| | | | ដង ក្នុងយានយន្តចំនួន ១,000 នៅឆ្នាំ២០១០<br><br>នៅឆ្នាំ២00៨ អនុក្រឹត្យ នីតិកម្ម និងគោលការណ៍ណែនាំ ពាក់ព័ន្ធ នឹងការតាំងទីលំនៅសាជាថ្មី នឹង ត្រូវបានបង្កើតឡើង | **សម្បត្តិ ផ្លូវថ្នល់**<br><br>GSM:<br>គម្រោងតំបន់ឆ្នេរសមុទ្រ ភាគខាងត្បូង<br><br>**TA:**<br>**ការកែលម្អផ្លូវខេត្តភាគ ពាយ័ព្យនៅប្រទេសកម្ពុ ជា GSM**<br><br>**ការជំនួស TA សម្រាប់ការ សាងសង់ផ្លូវដែកនៅប្រ ទេស កម្ពុជា** | |
| | កង្វះការភ្ជាប់អគ្គិសនី និងឱកាស សេដ្ឋកិច្ច និងការអភិវឌ្ឍន៍សង្គម ត្រូវចំណាយថវិកាច្រើន | លើកកម្ពស់ការទទួលបានការ ផ្គត់ផ្គង់ថាមពលប្រកបដោយ ការជឿទុកចិត្ត និងអាច លៃលកបាន | ការសាងសង់ និងការភ្ជាប់បណ្តាញ ផ្លូវពីព្រំដែនវៀតណាម ទៅទីក្រុង ភ្នំពេញ (នៅត្រឹមឆ្នាំ ២00៨)និង ការផ្គត់ផ្គង់ការភ្ជាប់អគ្គិសនីទៅភូមិ ចំនួន ២0ត្រូវបញ្ចប់នៅឆ្នាំ២00៨ | **សកម្មភាពកំពុងបន្ត :**<br>GSM:<br>គម្រោងការភ្ជាប់បណ្តាញ ការភ្ជាប់ថាមពលលើកទី ២ និង គម្រោងការបែងចែក | ការផ្គត់ផ្គង់អគ្គិសនី ដែលមានស្រាប់ពីវៀត ណាម នៅក្រោម កម្រិតដែលបានធ្វើ គម្រោង |

| | | | | | |
|---|---|---|---|---|---|
| | កង្វះបុគ្គលិករដ្ឋាភិបាលដែលមានជំនាញក្នុងវិស័យប្រេង និងឧស្ម័ន ក្នុងកម្រិតធ្ងន់ធ្ងរ | បណ្តាញផ្លូវកើនឡើងពី ១២៨,៧គ.ម ទៅ២២៨,០គ.ម នៅត្រឹមឆ្នាំ២០១០<br><br>ការប្រើប្រាស់អគ្គិសនីក្នុងមនុស្សម្នាក់ កើនឡើងពី ៥៤ គីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០០៦ ដល់ ៨៩ គីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១០<br><br>អគ្គិសនីកម្ពុជា (EDC) ត្រូវបានធ្វើឱ្យមាននិរន្តរភាព តាមរយៈការផ្តល់ហិរញ្ញវត្ថុ ហើយប្រសិទ្ធភាព និងការអនុវត្តការងារត្រូវបាន លើកកម្ពស់<br><br>**សាច់ប្រាក់របស់ EDCនឹងសម្រេច**បាននៅឆ្នាំ ២០០៨ នឹងត្រូវបានរក្សាចាប់តាំងពី ពេលនេះតទៅ<br><br>លក្ខណៈល្អប្រសើរនៃការទាញ | នៅត្រឹមឆ្នាំ២០១០ ការសាងសង់បណ្តាញអគ្គិសនី ពីខេត្តកំពត ទៅក្រុងព្រះសីហនុ និងការងារផ្គត់ផ្គង់ការបែងចែកត្រូវបញ្ចប់<br><br>ការខាតបង់អគ្គិសនី ត្រូវបានរក្សាឱ្យនៅក្រោម១៦ភាគរយ ផ្អែកលើមូលដ្ឋានប្រចាំឆ្នាំពីឆ្នាំ ២០០៥តទៅ ការអនុវត្តផែនការសកម្មភាពហិរញ្ញវត្ថុ និងបច្ចេកទេសដែលបានព្រមព្រៀង តាមរយៈ EdC ត្រូវបានបញ្ចប់នៅឆ្នាំ២០១០<br><br>គោលនយោបាយ ច្បាប់ និងសកម្មភាពដ៏សមស្រប ដែលជំរុញឱ្យមានការវិនិយោគនៅលើវិស័យ ដែលត្រូវបាន អនុម័ត នៅត្រឹម ឆ្នាំ ២០០៩ | **TA**<br>សម្រាប់ការពង្រឹងតាមស្ថាប័ននៃអាជ្ញាធរជាតិប្រេង<br>ឥន្ធនៈនៃប្រទេសកម្ពុជា<br><br>គម្រោងបណ្តាញតភ្ជាប់ថាមពល<br>នៅប្រទេសកម្ពុជា<br>(ប្រតិបត្តិការវិស័យឯកជន)<br><br>ការស្នើសុំ :<br>**TA:**<br>ការអភិវឌ្ឍជីវៈឥន្ធនៈ<br>**GSM** | អតិថិជនមិនមានបំណងបង់ថ្លៃការភ្ជាប់អគ្គិសនី<br><br>ការតាំងចិត្តកម្រិតទាបដើម្បីអនុវត្តផែនការសកម្មភាពហិរញ្ញវត្ថុរបស់ EdC និងការសងបំណុលដែលចេះតែកើនឡើងរបស់ទីភ្នាក់ងាររដ្ឋាភិបាល<br><br>ការវិភាគមិនគ្រប់គ្រាន់នៃតុល្យភាពរវាងថាមពលកកើតឡើងវិញ និងផលិតកម្មកសិកម្ម និងបទដ្ឋានគោលនយោបាយ |

| | | | | | |
|---|---|---|---|---|---|
| | | យកប្រយោជន៍ពីធនធានប្រេង និងឧស្ម័ន ហើយសមត្ថភាពនៃ **CNPA** ដើម្បីគ្រប់គ្រង ប្រតិបត្តិការវិស័យប្រេងឥន្ធនៈ | | | មិនមានប្រសិទ្ធភាព<br><br>ការពន្យារពេលការ អនុម័តនីយ័តកម្ម<br><br>ការសម្របសម្រួល សកម្មភាពរដ្ឋាភិបាល និងម្ចាស់ជំនួយ នៅក្នុងវិស័យមិនមាន លក្ខណៈគ្រប់គ្រាន់<br><br>បុគ្គលិកបដិភាគមិន គ្រប់គ្រាន់ |
| **II. ការអភិវឌ្ឍសង្គមដោយមានការចូលរួម** | | | | | |
| សិស្សានុសិស្សទាំងអស់ ត្រូវបញ្ចប់ការរៀន បឋមសិក្សានៅត្រឹមឆ្នាំ ២០១០ និងការរៀនជា មូលដ្ឋានត្រឹមថ្នាក់ទី៩ នៅឆ្នាំ២០១៥ | ការទទួលបានការអប់រំនៅកម្រិត បឋមសិក្សា និងមធ្យមសិក្សា មិន មានសមធម៌<br><br>គុណភាព និងប្រសិទ្ធភាពផ្ទៃក្នុង នៅខ្សោយ | អត្រាចុះឈ្មោះសរុបនៅក្នុង ការអប់រំកម្រិតបឋមសិក្សា កើនឡើងពី៩១,៩ភាគរយ នៅឆ្នាំ២០០៥ ដល់១០០ភាគ រយ នៅឆ្នាំ២០១០ | សិស្សចំនួន៣៨០នាក់ រៀនមិនចប់ ថ្នាក់បឋមសិក្សា នៅក្នុងខេត្ត ជន ជាតិភាគតិច និងនៅតំបន់ដាច់ ស្រយាលចំនួន៦កន្លែង នឹងត្រូវ បញ្ចប់នៅឆ្នាំ ២០០៩ | **សកម្មភាពកំពុងបន្ត :** ការវិនិយោគវិស័យអប់រំ<br><br>TA:<br>លើកកម្ពស់ការចូលរៀន នៅកម្រិតបឋមសិក្សា នៅឃុំ | ការប្តេជ្ញាចិត្តដើម្បី រក្សាថវិកាសម្រាប់ ការអប់រំឱ្យបានគ្រប់ គ្រាន់ នៅមាន លក្ខណៈខ្សោយ |

| | | | | | |
|---|---|---|---|---|---|
| ការលុបបំបាត់ការបែងចែកយេនឌ័រក្នុងការអប់រំកម្រិតមូលដ្ឋាន ៩ឆ្នាំ និងកាត់បន្ថយការបែងចែកយេនឌ័រ នៅក្នុងការអប់រំកម្រិតមធ្យមសិក្សា ជាពិសេស នៅត្រឹមឆ្នាំ២០១០ | កង្វះធនធានគ្រប់គ្រាន់ដើម្បីគាំទ្រការចំណាយផ្សេងៗ | នៅត្រឹម២០១០ គ្រូថ្មីៗចំនួន ១០,០០០ នាក់ នឹងត្រូវយកទៅបណ្តុះបណ្តាលនៅគ្រប់កម្រិតក្នុងមួយឆ្នាំ ចាប់ពីកម្រិតបច្ចុប្បន្ន ចំនួន ៥,០០០ នាក់ ក្នុងមួយឆ្នាំ<br><br>អត្រាក្មេងស្រី និងក្មេងប្រុស នៅកម្រិតអប់រំអនុវិទ្យាល័យ កើនឡើងពី៧៧ភាគរយ នៅឆ្នាំ២០០៥ ដល់ ១០០ ភាគរយ នៅឆ្នាំ២០១០ | ការធ្វើផែនការបែបវិមជ្ឈការ និងប្រព័ន្ធគ្រប់គ្រងសម្រាប់ផ្សព្វផ្សាយការអប់រំ (រួមទាំង ការគ្រប់គ្រងសាលារៀន ការអនុវត្ត និងការតាមដានគ្រូបង្រៀន) ត្រូវបានពង្រឹងរវាងឆ្នាំ២០០៦ ដល់២០១០<br><br>រវាងឆ្នាំ២០០៦ និង២០១០ ការចំណាយផ្សេងៗប្រចាំឆ្នាំទៅលើការអប់រំ ត្រូវរក្សាឱ្យនៅដដែល ឬបង្កើន នៅពេលដែលសមាមាត្រនៃចំណាយផ្សេងៗរបស់ រដ្ឋាភិបាលសរុប មានទំនាក់ទំនងទៅនឹងឆ្នាំខាងមុខ<br>នៅឆ្នាំ២០១០ សមត្ថភាព បណ្តុះបណ្តាលគ្រូបង្រៀនតាមស្ថាប័ន ការបង្កើតកម្មវិធីសិក្សា និង ការរៀបចំសៀវភៅអាន នឹងត្រូវបានពង្រឹង ហើយប្រព័ន្ធនៃការប្រលងនឹងត្រូវធ្វើកំណែទម្រង់ | ដែលជួបការលំបាក<br><br>កម្មវិធី/គម្រោង<br><br>TA: កំណែទម្រង់នីតិកម្ម និងអភិបាលកិច្ចសម្រាប់វិមជ្ឈការ<br><br>TA:<br>ជំនួយគោលដៅសម្រាប់ការអប់រំក្មេងស្រី និងក្មេងៗ នៅតំបន់ជនជាតិភាគតិច<br><br>**ការស្នើសុំ :**<br><br>**លើកកម្ពស់គម្រោងគុណភាព អប់រំ** | ភាពស្ទាក់ស្ទើរក្នុងការតាំងចិត្ត និងកង្វះកិច្ចព្រមព្រៀងក្នុងចំណោមមន្ទីរ រដ្ឋាភិបាល សម្រាប់កំណែទម្រង់តាមស្ថាប័ន |

| | | | | | |
|---|---|---|---|---|---|
| លើកកម្ពស់គុណភាព និងប្រសិទ្ធភាពផ្ទៃក្នុងនៃការអប់រំនៅប្រទេសកម្ពុជា ដោយធ្វើឱ្យការអប់រំកម្រិតមធ្យមសិក្សា និងប្រព័ន្ធគ្រប់គ្រងការអប់រំនៅប្រទេសកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព | ភាពជាដៃគូក្នុងការអប់រំវិស័យឯកជន-សាធារណៈ នៅខ្សោយ<br><br>កង្វះក្របខ័ណ្ឌគោលនយោបាយសម្រាប់ការអប់រំគ្រូបង្រៀន និងការគ្រប់គ្រងគ្រូបង្រៀន<br><br>មុខងារ និងអង្គភាព MOEYS មិនទាន់បានកែសម្រួល | លើកកម្ពស់ក្របខ័ណ្ឌនីយ័តកម្ម និងនីតិកម្ម សម្រាប់ការធានាបាននូវគុណភាពនៃសេវាអប់រំ<br><br>ការធ្វើផែនការ ការគ្រប់គ្រង និងរដ្ឋបាលអប់រំ មានលក្ខណៈវិមជ្ឈការ និងវិសហមជ្ឈការ | សេចក្តីព្រាងច្បាប់អប់រំ ត្រូវបានអនុម័តដោយរដ្ឋសភា នៅចុងឆ្នាំ២០០៧<br><br>ច្បាប់នៃការអប់រំត្រូវបានផ្សព្វផ្សាយនៅក្នុងខេត្តទាំង ៦<br><br>ការធ្វើផែនការ និងការកសាងសមត្ថភាពគ្រប់គ្រងមាន លក្ខណៈវិមជ្ឈការ ត្រូវពង្រឹង នៅត្រឹមឆ្នាំ ២០១០<br><br>ក្របខ័ណ្ឌគោលនយោបាយសម្រាប់ការអប់រំគ្រូបង្រៀន និងការគ្រប់គ្រងគ្រូបង្រៀនត្រូវបញ្ចប់នៅចុងឆ្នាំ២០០៨<br><br>មុខងារ និងអង្គភាពនៃ MOEYS | សកម្មភាពកំពុងបន្ត :<br><br>កម្មវិធីអភិវឌ្ឍវិស័យអប់រំ<br><br>ការស្នើសុំ :<br>ការលើកកម្ពស់គម្រោងគុណភាពអប់រំ | ពន្យារពេលក្នុងការអនុម័តច្បាប់ស្តីពីការអប់រំពីរដ្ឋសភាជាតិ<br><br>ការបែងចែក និងភាពដែលអាចមាននៃធនធានធម្មជាតិមានលក្ខណៈមិនគ្រប់គ្រាន់ ដើម្បីគាំទ្រលើកំណែទម្រង់ក្នុង វិស័យ<br><br>កង្វះយន្តការជាក់លាក់សម្រាប់តាមដានប្រសិទ្ធភាពនៃគោលនយោបាយ |

| | | | | | |
|---|---|---|---|---|---|
| | | | ត្រូវធ្វើបច្ចុប្បន្នភាព នៅចុងឆ្នាំ២០០៨ | | |

| របៀបវារៈនៃការអភិវឌ្ឍរយៈពេលមធ្យមរបស់រដ្ឋាភិបាល[ខ] | | ការផ្តោតជាយុទ្ធសាស្ត្ររបស់ ADB | | អន្តរាគមន៍របស់ ADB ដើម្បីគាំទ្រលទ្ធផល | ហានិភ័យ |
|---|---|---|---|---|---|
| គោលដៅជាយុទ្ធសាស្ត្រ[គ] | ឧបសគ្គចម្បង[ឃ] | លទ្ធផល/សូចនាកររបស់លទ្ធផល[ង] | សូចនាករសម្រាប់តាមដាន/ ព្រឹត្តិការណ៍សំខាន់ៗ | | |
| សុខភាព និងស្ថានភាពរស់នៅរបស់ប្រជាជននៅតាមជនបទ មានភាពប្រសើរជាងមុន ស្របតាមទិសដៅរបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ក្នុងការទទួលបាននូវទឹកមានសុវត្ថិភាព និង អនាម័យ | ផ្លាស់ប្តូរគោលនយោបាយ (គោលនយោបាយថ្នាក់ជាតិ RWSS) ឱ្យទៅជាវិធានការ ។<br>កង្វះខាតវិធានច្បាស់លាស់ និងប្រកបដោយតម្លាភាពស្តីពីយន្តការក្នុងការវិនិយោគ ហិរញ្ញប្បទាន និងការទទួលបានតម្លៃមកវិញ នៅក្នុងវិស័យ ។<br>គ្រឹះស្ថានដែលមានភាពទន់ខ្សោយនៅក្នុងវិស័យ RWSS ។<br>សមត្ថភាពទន់ខ្សោយរបស់ទីភ្នាក់ងារ អនុវត្តដែលពាក់ព័ន្ធ នៅថ្នាក់កណ្តាល និងថ្នាក់តំបន់ ។<br>ការចូលរួមរបស់សហគមន៍ ដែល | លទ្ធភាពប្រកបដោយនិរន្តរភាពរបស់សហគមន៍ តាមជនបទទាំងអស់ ក្នុងការទទួលបានទឹកស្អាតដែលមានសុវត្ថិភាព និងអនាម័យកាន់តែប្រសើរជាងមុន ព្រមទាំងអនាម័យខ្ពស់ ។<br>ភាពងាយស្រួលក្នុងការទទួលបានទឹកស្អាត និងអនាម័យ នៅតាមជនបទ ក្នុងខេត្តចំនួន៥នៃអាងទន្លេសាប កាន់តែមានភាពប្រសើរជាងមុន ។<br>គ្រឹះស្ថានក្នុងវិស័យ RWSS នៅកម្រិត ជាច្រើន មានភាពប្រសើរជាងមុន ។<br>សហគមន៍ ត្រូវបានផ្តល់អំណាចតាមរយៈក្រុមអ្នកប្រើប្រាស់ទឹកស្អាត និងអនាម័យតាមភូមិ ។ | នៅត្រឹមឆ្នាំ២០១០ ការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត នឹងមានរហូតដល់៤០ភាគរយនៃចំនួនប្រជាជនតាមជនបទ ។<br>នៅត្រឹមឆ្នាំ២០១០ ការផ្តល់សេវាកម្មអនាម័យ នៅតាមជនបទ នឹងមានរហូតដល់២០ភាគរយនៃចំនួនប្រជាជនតាមជនបទ ។<br>សម្រាប់ខេត្តទាំង៥នៃអាងទន្លេសាប សេវាកម្មផ្គត់ផ្គង់ទឹកស្អាតដែលមានសុវត្ថិភាព នឹងមានរហូតដល់៥០ភាគរយនៃចំនួនប្រជាជន នៅតាមជនបទ និងការកែលំអអនាម័យ នឹងត្រូវបានអនុវត្តឱ្យបាន៥០ភាគរយនៃចំនួនប្រជាជន នៅតាមជនបទ នៅត្រឹមឆ្នាំ២០១១ ។ | **កំពុងបន្ត**<br>គម្រោងផ្គត់ផ្គង់ទឹកស្អាត និង អនាម័យនៅតាមជនបទទន្លេសាប ។<br>**ការស្នើសុំ :**<br>គម្រោងទី២ ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតាមជនបទ | |

| | | | | | |
|---|---|---|---|---|---|
| | **គាំទ្រដល់ការគ្រប់គ្រងវិស័យ RWSS ប្រកបដោយនិរន្តរភាព។** | **ការបង្កើត និងសេចក្ដីណែនាំរបស់យុទ្ធសាស្ត្រជាតិ សម្រាប់កម្មវិធីរបស់វិស័យ RWSS ។** | | | |
| ការកាត់បន្ថយអត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ ដើម្បីឆ្លើយតបទៅនឹងទិសដៅរបស់ CMDG | ហានិភ័យកើនឡើងដោយយោងតាមការភ្ជាប់ទំនាក់ទំនង និងការធ្វើដំណើរឆ្លងកាត់ព្រំដែនរបស់ប្រជាជនមានភាពប្រសើរជាងមុន ។ | អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងចំណោមយុវជនដែលមានអាយុ១៥-៤៩ ឆ្នាំ ត្រូវបានថែរក្សា និងកាត់បន្ថយ (តម្លៃមូលដ្ឋាន គឺ១,៩ភាគរយ នៅឆ្នាំ២០០៥) | ការផ្សព្វផ្សាយល្ខោននិយាយតាមវិទ្យុ ស្ដីពីការអប់រំក្នុងការទប់ស្កាត់មេរោគអេដស៍/ ជំងឺអេដស៍ ត្រូវបានធ្វើឡើងកាន់តែទូលំទូលាយជាងមុន ដើម្បីរួមបញ្ចូលក្រុមជនជាតិភាគតិចផងដែរ នៅត្រឹមឆ្នាំ២០០៧។<br>ការរៀបចំគម្រោងសម្រាប់ភាពងាយរងគ្រោះរបស់ GIS ក្នុងកិច្ចប្រតិបត្តិការនៃមេរោគអេដស៍/ ជំងឺអេដស៍ នៅត្រឹមឆ្នាំ២០០៧។ | **កំពុងបន្ត**<br>GSM :កាត់បន្ថយភាពងាយរងគ្រោះ និងហានិភ័យក្នុងចំណោមជនជាតិភាគតិច តាមរយៈយុទ្ធសាស្ត្រទំនាក់ទំនង។<br>**ការស្នើសុំ :**<br>**TA : ការទប់ស្កាត់មេរោគឆ្លង នៅ GSM ។** | បរាជ័យក្នុងការទាក់ទងទៅកាន់ប្រជាជននៅតំបន់ដាច់ស្រយាលតាមជនបទ។ |
| **៣. អភិបាលកិច្ចល្អ និងការចែកចាយសេវាកម្មសាធារណៈដែលបានកែលំអហើយ** | | | | | |
| ការកាត់បន្ថយភាពក្រីក្រកាន់តែមានភាពប្រសើរឡើង តាមរយៈអភិបាលកិច្ចតាមតំបន់ ដែលកាន់តែមានការចូលរួម ប្រកបដោយតម្លាភាព និងគណនេយ្យភាព។ | ក្រុមប្រឹក្សាឃុំខ្វះហេដ្ឋារចនាសម្ព័ន្ធគ្រឹះ សមត្ថភាពខាងរដ្ឋបាល និងធនធានហិរញ្ញវត្ថុ (ពីរដ្ឋាភិបាលថ្នាក់កណ្ដាល រួមទាំងកង្វះខាតសិទ្ធិអំណាចក្នុងការប្រមូលពន្ធ) ដើម្បីជំរុញឱ្យមានការអភិវឌ្ឍក្នុងតំបន់របស់គេរៀងខ្លួន។ | សមត្ថភាពរបស់រដ្ឋបាលសាធារណៈប្រចាំតំបន់ កាន់តែមានភាពប្រសើរឡើង ដើម្បី (១) គ្រប់គ្រងដល់ការបង្កើតលទ្ធិប្រជាធិបតេយ្យ ក្នុងសហគមន៍ (២) ធ្វើឱ្យកាន់តែមានប្រសិទ្ធភាព ប្រៀបដូចជាយន្តការគ្រឹះមួយ ដើម្បីពង្រឹងគណនេយ្យភាព ការឆ្លើយតប និងតម្លាភាពរបស់រដ្ឋបាលសាធារណៈ និង (៣) ធ្វើឱ្យប្រសិទ្ធភាព | ហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងឃុំចំនួន៥១៩ ត្រូវបានកសាងឡើងឱ្យរួចរាល់ នៅត្រឹមឆ្នាំ២០០៦ និងហេដ្ឋារចនាសម្ព័ន្ធបន្ថែមនៅក្នុងឃុំចំនួន២៣៥ ទៀត ត្រូវបានកសាងឡើងឱ្យរួចរាល់ នៅត្រឹមឆ្នាំ២០០៩។<br>៨៥ភាគរយនៃចំនួនប្រជាជន បានចុះឈ្មោះ គិតត្រឹមចុងឆ្នាំ២០០៦ ហើយប្រព័ន្ធប្រតិបត្តិការចុះឈ្មោះតាមម៉ាស៊ីនកុំព្យូទ័រប្រកបដោយនិរន្តរភាព | **កំពុងបន្ត**<br>គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ<br>**ការស្នើសុំ :**<br>**គម្រោងអភិវឌ្ឍន៍ ក្រុមប្រឹក្សាឃុំលើកទី២**<br>**TA : គាំទ្រដល់កម្មវិធី វិសហមជ្ឈការ ។** | ធនធានគ្រប់គ្រាន់ មិនអាចផ្ដល់ដល់មន្ត្រីតាមតំបន់បានទេ។<br>សមត្ថភាពរបស់រដ្ឋបាលក្នុងតំបន់ នៅមានភាពទន់ខ្សោយ។ |

| | | | | | |
|---|---|---|---|---|---|
| | ក្រុមប្រឹក្សា និងបុគ្គលិកពាក់ព័ន្ធភាគច្រើន មិនសូវយល់ច្បាស់ពីប្រព័ន្ធគ្រប់គ្រង តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលថ្នាក់តំបន់។<br>ប្រជាពលរដ្ឋភាគច្រើន មិនសូវយល់ដឹងពីសារៈសំខាន់របស់រដ្ឋាភិបាលប្រជាធិបតេយ្យថ្នាក់តំបន់ទេ ហើយអ្នកទាំងនោះ ក៏មិនដឹងច្បាស់ពីតួនាទី និងមុខងាររបស់ក្រុមប្រឹក្សា ដែលត្រូវបានបោះឆ្នោតជ្រើសរើសដែរ។ | និងការទទួលមានការផ្តល់សេវាកម្មសាធារណៈ (តាមរយៈការវាយតម្លៃទស្សនៈសាធារណៈ ការស្ទាបស្ទង់គំរូ និងការសិក្សាផលប៉ះពាល់)។ | ត្រូវបានធ្វើ គិតត្រឹមឆ្នាំ២០០៩។<br>ចន្លោះឆ្នាំ២០០៦ និង២០០៩ វគ្គបណ្តុះបណ្តាលស្តីពីនីតិវិធី និងការគ្រប់គ្រងប្រតិបត្តិការរបស់ឃុំសង្កាត់ ដល់ក្រុមប្រឹក្សា ស្មៀន និងមន្ត្រីរដ្ឋាភិបាលតាមតំបន់ ព្រមទាំងមានយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈស្តីពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ និងការអភិវឌ្ឍតំបន់ ព្រមទាំងបញ្ហាសង្គមផងដែរ (ឧទាហរណ៍ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ សិទ្ធិកុមារ និងការអប់រំ ព្រមទាំងបញ្ហាសុខភាពដែលប៉ះពាល់ដល់ស្ត្រី និងកុមារ) | | |
| ការកែលំអការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) | កង្វះខាតប្រព័ន្ធព័ត៌មាន និងការធ្វើរបាយការណ៍ដែលគ្មានប្រសិទ្ធភាព ទាន់ពេលវេលា និងត្រឹមត្រូវ បង្កឱ្យមានបរិយាកាសមួយដែលខ្វះខាតការគ្រប់គ្រង។<br><br>**ការគ្រប់គ្រងហិរញ្ញវត្ថុ និង** | កាត់បន្ថយផលធៀបរវាងបំណុល/ ប្រាក់ចំណូលរបស់ NPV ពី១៨២.២ភាគរយ នៅឆ្នាំ២០០៥ មកនៅត្រឹម១៧០ ភាគរយ ត្រឹមឆ្នាំ២០១០។<br>• ពង្រឹងមុខងារគ្រប់គ្រងបំណុលសាធារណៈ (ការទាយទុកជាមុន ការវិភាគហិរញ្ញវត្ថុ និងការគ្រប់គ្រងប្រាក់ចំណាយ) ត្រឹមឆ្នាំ២០០៧។<br>• លំហូរទិន្នន័យស្តីពីបំណុលសាធារណៈកាន់តែប្រសើរឡើង នៅឆ្នាំ២០០៧។ | ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ (រួមមានគោលការណ៍ណែនាំគតិយុត្តិ និងការប្រកាសពីតួនាទី និងការទទួលខុសត្រូវ ការរួមបញ្ចូលគ្នានូវបំណុលដែលទាក់ទងទៅនឹងលំហូរទិន្នន័យ និងការអភិវឌ្ឍស្ថាប័ន និងសមត្ថភាព) ត្រឹមឆ្នាំ២០០៧។<br>ប្រព័ន្ធគ្រប់គ្រងបំណុលតាមកុំព្យូទ័រ (CBDMS) និងការអភិវឌ្ឍសមត្ថភាព ក្នុងការវិភាគការទ្រទ្រង់បំណុល ការគ្រប់គ្រងហានិភ័យ និងដំណើរការទិន្នន័យ សម្រាប់ CBDMS ដែល | **កំពុងបន្ត**<br>**TA : ការគាំទ្រដល់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។**<br><br>**ការស្នើសុំ :**<br>**TA : ការគាំទ្រដល់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ** | ការតាំងចិត្តរបស់រដ្ឋាភិបាលចំពោះកម្មវិធីកំណែទម្រង់ PFM ក្នុងភាពកំសោយផ្នែកនយោបាយជាយូរមកហើយ។ |

| | | | | | |
|---|---|---|---|---|---|
| | សមត្ថភាពសវនកម្មផ្ទៃក្នុងទន់ខ្សោយ នៅក្នុងគ្រឹះស្ថានរដ្ឋាភិបាល ។<br>កង្វះសមត្ថភាពរបស់ NAA ក្នុងការដឹកនាំសវនកម្មគ្រប់ប្រភេទទាំងអស់ រួមមានសវនកម្មការងារប្រចាំឆ្នាំ និងការយល់ព្រមចំពោះរដ្ឋបាល ដែលកើនឡើងយ៉ាងឆាប់រហ័ស | ថវិកាដែលគួរទុកចិត្តបាន នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ មានការកើនឡើង（MRD, MOWRAM, MAFF）<br>សវនកម្មផ្ទៃក្នុង នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានបុគ្គលិកគ្រប់គ្រាន់ និងមានសមត្ថភាព។<br>សមត្ថភាពរបស់ NAA ក្នុងការធ្វើសវនកម្មផ្ទៃក្រៅ និងការផ្សព្វផ្សាយលទ្ធផលដែលទទួលបានជាសាធារណៈ។<br>ប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញវត្ថុ មានការរីកចម្រើន និងកំពុងដំណើរការ។ | បង្កើតឡើងត្រឹម ឆ្នាំ២០០៧។<br>ការផ្តល់អំណាចក្នុងការរៀបចំ និងការអនុវត្តថវិកាពី MEF ទៅក្រសួងអភិវឌ្ឍន៍ជនបទ នឹងត្រូវបានកើនឡើង។<br>ផលិតកម្មសាកល្បងរបស់របាយការណ៍សវនកម្មផ្ទៃក្នុង ដែលធ្វើឡើងដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ នឹងត្រូវចាប់ផ្តើម នៅឆ្នាំ២០០៩។<br>ការងារបច្ចេកទេសជំនាញខាងធ្វើតេស្តសាកល្បង（ការធ្វើសវនកម្មការងារប្រចាំឆ្នាំ និងការតាមដានការចំណាយ）របស់ NAA នឹងត្រូវចាប់ផ្តើមនៅឆ្នាំ២០០៩។ | សាធារណៈ។<br>ការស្នើសុំ :<br>ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់អភិវឌ្ឍជនបទ។ | |

CBDMS = ប្រព័ន្ធគ្រប់គ្រងបំណុលតាមកុំព្យូទ័រ CMDGs = គោលដៅអភិវឌ្ឍន៍សហស្សវត្សរកម្ពុជា CNPA = អាជ្ញាធរប្រេងកាតជាតិកម្ពុជា CSP = យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស EDC = អគ្គិសនីកម្ពុជា GDP = ផលិតផលក្នុងស្រុកសរុប GIS = ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ GMS = មហាអនុតំបន់ទន្លេមេគង្គ HIV/AIDS = មេរោគអេដស៍/ជំងឺអេដស៍ Kwh = គីឡូវ៉ាត់ម៉ោង MFI = វិទ្យាស្ថានមីក្រូហិរញ្ញវត្ថុ MoEYS = ក្រសួងអប់រំ យុវជន និងកីឡា MRD = ក្រសួងអភិវឌ្ឍន៍ជនបទ MOWRAM = ក្រសួងធនធានទឹក និងឧត្តុនិយម MAFF = ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ MEF = ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ NPV = តម្លៃសរុបនាពេលបច្ចុប្បន្ន NAA = អាជ្ញាធរជាតិសវនកម្ម NR = ផ្លូវជាតិ O & M = ប្រតិបត្តិការ និងការថែរក្សា PFM = ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ SME = សហគ្រាសធុនតូច និងធម្យម t/ha = តោនក្នុងមួយហិកតា TA = ជំនួយផ្នែកបច្ចេកទេស

ក. ទោះបីរយៈពេល CSP មានចាប់ពី២០០៥-២០០៩ រយៈពេលជាក់លាក់នៃរចនាសម្ព័ន្ធរបស់លទ្ធផល ត្រូវបានកែលំអ ដើម្បីឱ្យស្របតាមផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាល（NSDP）២០០៦-២០១០។ រយៈពេលនេះ អាចមានការកែប្រែឡើងវិញ។

ខ. ផ្នែកដែលត្រូវបានជ្រើសរើសនៃរបៀបវារៈក្នុងការអភិវឌ្ឍរយៈពេលមធ្យម ដែលស្របទៅតាមអាទិភាពជាយុទ្ធសាស្ត្ររបស់ ADB នៅកម្ពុជា។

គ. គោលដៅយុទ្ធសាស្ត្ររបស់ NSDP និង CMDGs។

ឃ. ដូចដែលបានកំណត់ នៅក្នុង NSDP យុទ្ធសាស្ត្រចតុកោណ និងការវាយតម្លៃលើវិស័យ និងប្រធានបទ ដែលអនុវត្តដោយ ADB និងដៃគូអភិវឌ្ឍន៍។

ង. ការសម្រេចនូវលទ្ធផលទាំងនេះ គឺជាការទទួលខុសត្រូវរួមបញ្ចូលគ្នារបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍របស់រដ្ឋាភិបាល រួមមាន ADB វិស័យឯកជន សង្គមស៊ីវិល និងទីភ្នាក់ងារផ្តល់ជំនួយអភិវឌ្ឍន៍ផ្សេងទៀត។

ច. សូចនាករសម្រាប់តាមដានភាពជោគជ័យនៃការអនុវត្តឆ្ពោះទៅកាន់លទ្ធផលដែលរំពឹងទុក។ មូលដ្ឋានគ្រឹះ ទិសដៅចង្អុលបង្ហាញ និងសូចនាករសម្រាប់តាមដានពីការរីកចម្រើន ត្រូវបានកំណត់ និងត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់។